# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកោះកុង**

# របាយការណ៍

# ស្តីពី

# ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង

# ប្រចាំខែធ្នូ ឆ្នាំ២០២៤

ព.ស.២៥៦៨ ឆ្នាំ២០២៤

# មាតិកានុក្រម

ទំព័រ


សេចក្តីផ្តើម ........................................ ១
ផ្នែកទី១៖សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ........................................ ២
១.១-ការងាររដ្ឋបាល ........................................ ២
១.១.១-ការងាររបៀប និងឯកសារ ........................................ ២
១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន ........................................ ២
១.១.៣-ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ........................................ ៣
១.១.៤-ការងារសរុប និងព័ត៌មាន ........................................ ៣
១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា ........................................ ៤
១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា ........................................ ៤
១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ........................................ ៥
១.២-ការងារផែនការ និងវិនិយោគ ........................................ ៦
១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ........................................ ៦
១.២.២-ការគាំទ្រមូលដ្ឋាន ........................................ ៧
១.២.៣-ការវិនិយោគ ........................................ ៩
១.២.៤-ការងារសេវាសង្គម ........................................ ៩
១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប. ........................................ ៩
១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា ........................................ ១០
១.៣-ការគ្រប់គ្រងធនធានមនុស្ស ........................................ ១០
១.៣.១-ការងារគ្រប់គ្រងបុគ្គលិក ........................................ ១០
១.៣.២-ការងារកសាងសមត្ថភាព ........................................ ១១
១.៤-ការងារអន្តរវិស័យ ........................................ ១២
១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច ........................................ ១២
១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ ........................................ ១៣
១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ........................................ ១៣
១.៤.៤-ការងារគ្រប់គ្រងកាកសំណល់ ........................................ ១៤
១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ ........................................ ១៤
១.៦-ការងារការិយាល័យប្រជាពលរដ្ឋ(សម្រុះសម្រួលដោះស្រាយបណ្តឹង) ........................................ ១៥
១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត ........................................ ១៥
១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន ........................................ ១៥
១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ ........................................ ១៥
១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន ........................................ ១៥
១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ) ........................................ ១៥
១.៨.៤-ការផ្លាស់ប្តូរទំនិញ ........................................ ១៦
១.៨.៥-កិច្ចសហប្រតិបត្តិការ ........................................ ១៦
១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ ........................................ ១៦

១.៩.១-ការងារហិរញ្ញវត្ថុ ........ ១៦
១.៩.២-ការងារគណនេយ្យ ........ ១៧
១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ ........ ១៧
១.១០-ការងារលទ្ធកម្ម ........ ១៧
១.១១-ការងារសុខាភិបាល ........ ១៨
១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល ........ ១៩
១.១៣-ការងារផ្សេងៗ ........ ១៩
ផ្នែកទី២៖សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ ........ ១៩
២.១-ផ្នែកសេដ្ឋកិច្ច ........ ១៩
២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ១៩
២.១.២-ការងារធនធានទឹក និងឧតុនិយម ........ ២២
២.១.៣-ការងារអភិវឌ្ឍជនបទ ........ ២៣
២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ........ ២៣
២.១.៥-ការងាររ៉ែ និងថាមពល ........ ២៣
២.១.៦-ការងារពាណិជ្ជកម្ម ........ ២៤
២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ ........ ២៤
២.១.៧.១-ការងារហិរញ្ញវត្ថុ ........ ២៤
២.១.៧.២-ការងារពន្ធដារ ........ ២៥
២.១.៧.៣-ការងារគយ និងរដ្ឋាករ ........ ២៥
២.១.៨-ការងារទេសចរណ៍ ........ ២៥
២.១.៩-ការងារផែនការ ........ ២៦
២.១.១០-ការងារផ្សេងៗ ........ ២៦
២.១.១០.១-ការងារសាខាធនាគារជាតិ ........ ២៦
២.១.១០.២-ការងាររតនាគារ ........ ២៦
២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ........ ២៧
២.២-ផ្នែកសង្គមកិច្ច ........ ២៧
២.២.១-ការងារអប់រំ យុវជន និងកីឡា ........ ២៧
២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ៣០
២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ........ ៣១
២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ ៣១
២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម ........ ៣១
២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ ........ ៣២
២.២.៥-ការងារព័ត៌មាន ........ ៣២
២.២.៦-ការងារកិច្ចការនារី ........ ៣៣
២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ........ ៣៤
២.២.៨-ការងារធម្មការ និងសាសនា ........ ៣៤
២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ៣៤

២.២.១០-ការងារមុខងារសាធារណៈ ...................................................................................................... ៣៥
២.២.១១-ការងារផ្សេងៗ.......................................................................................................................... ៣៧
២.២.១១.១-ការងារសាលាដំបូងខេត្ត ................................................................................................ ៣៧
២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ..................... ៣៧
២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ............................................... ៣៧
២.៣.២-ការងារបរិស្ថាន ............................................................................................................ ៣៨
២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន ................................................................................ ៣៨
២.៣.៤-ការងារផ្សេងៗ .............................................................................................................. ៣៩
២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ.................................................................................. ៣៩
២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ........................................... ៣៩
២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ .................................................. ៤១
២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត ................................................................................. ៤២
២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ ......................................................................................... ៤៣
២.៤.៥-ការងារផ្សេងៗ ........................................................................................................... ៤៤
ផ្នែកទី៣៖បញ្ហាប្រឈម និងសំណើដោះស្រាយ........................................................................................... ៤៤
ផ្នែកទី៤៖ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់.......................................................................... ៤៥
ឧបសម្ព័ន្ធ
ឧបសម្ព័ន្ធទី១៖ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំខែធ្នូ ឆ្នាំ២០២៤
ឧបសម្ព័ន្ធទី២៖ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំខែធ្នូ ឆ្នាំ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**

លេខ ០២២/២៥រ.ប.ក

ថ្ងៃ សុក្រ១១រោច ខែ បុស្ស ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

ខេត្តកោះកុង ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥

# របាយការណ៍

# ស្តីពី

# ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង ប្រចាំខែធ្នូ ឆ្នាំ២០២៤

## សេចក្តីផ្តើម

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៩០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប ១០.០៤៥,៥៨គ.ម$^{២}$ មានក្រុង១ ស្រុក៦ ឃុំ២៦ សង្កាត់៣ និងមានភូមិសរុបចំនួន១១៩ភូមិ។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងព្រះរាជក្រឹត្យលេខ នស/រកត/០៦២៤/៥៨៤ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ត្រាស់បង្គាប់ទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៤។ ក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៤ មានសមាសភាព១៩រូប ស្រី៣រូប ប្រធាន១រូបប្រុស និងមាន គណៈកម្មាធិការ ជាកាតព្វកិច្ចចំនួន៣រួមមាន៖ ១).គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ២).គណៈកម្មា-ធិការសម្របសម្រួលបច្ចេកទេស និង៣).គណៈកម្មាធិការលទ្ធកម្ម។

ដោយមានស្ថានភាពភូមិសាស្ត្រអំណោយផលពីធម្មជាតិ នាំឱ្យខេត្តកោះកុង មានសក្តានុពលដ៏សម្បូរបែបអាចបម្រើដល់វិស័យជាច្រើន ជាពិសេសវិស័យទេសចរណ៍ រួមមាន ៖ តំបន់ធម្មជាតិដ៏ស្រស់ត្រកាលគ្របដណ្តប់ដោយព្រៃភ្នំជ្រលងជងអូរ តំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំ១២.០០០ហិកតា តំបន់ព្រំដែនមានសណ្ឋាគារលំដាប់ផ្កាយ៥ជាប់មាត់សមុទ្រ តំបន់សេដ្ឋកិច្ចពិសេសកោះកុង តំបន់កោះទាំង២៣ មានប្រជុំកោះ៩ ដែលមានផ្កាថ្មដ៏ស្រស់ស្អាត និងតំបន់ឆ្នេរសមុទ្រមានប្រវែង២១៧គីឡូម៉ែត្រ លាតសន្ធឹងពីចំណុចជ្រោយស្វាយ ស្រុកស្រែអំបិល រហូតដល់ចំណុចចាំយាម ស្រុកមណ្ឌលសីមា ស្មើនឹង៤៩% នៃប្រវែងឆ្នេរសមុទ្រ៤៤០គីឡូម៉ែត្រ នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់វិស្សមកាលតារាសាគរកោះស្តេចដែលមានទីលានវាយកូនហ្គោលខ្នាតអន្តរជាតិ តំបន់កសិ-ឧស្សាហកម្មចម្រុះ និងទំនប់វារីអគ្គិសនីចំនួន៤កន្លែង។ ក្រៅពីនេះខេត្តកោះកុង មានដៃព្រែកធំៗចំនួន៥ បានរួមចំណែកក្នុងការរុញច្រានកំណើនសេដ្ឋកិច្ចខេត្ត រួមមាន ព្រែកកោះប៉ោះ ព្រែកតាតៃ ព្រែកត្រពាំងរូង ព្រែកអណ្តូងទឹក និងព្រែកស្រែអំបិល។

ក្រុមប្រឹក្សាខេត្ត រួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០២០-២០២៤) ក្នុងការលើកកម្ពស់អភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិនានា ដោយផ្តោតលើគោលដៅអភិវឌ្ឍន៍ដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ លូ ស្ពាន សួនច្បារ សួនកម្សាន្ត សំណង់អគាររមណីយដ្ឋានទេសចរណ៍ អគ្គិសនី ទឹកស្អាត វប្បធម៌ សាសនា និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

# ផ្នែកទី១÷សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត

## ១.១-ការងាររដ្ឋបាល

### ១.១.១-ការងាររបៀប និងឯកសារ

- បានរៀបចំកែសម្រួលបញ្ជីទុកដាក់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការណែនាំរបស់គណៈអភិបាលខេត្ត
- បានកត់ត្រា និងដំណើរការចរន្តឯកសាររដ្ឋបាល ជូនថ្នាក់ដឹកនាំ និងមន្ទីរ អង្គភាពពាក់ព័ន្ធបានល្អប្រសើរ
- បានទំនាក់ទំនង សម្របសម្រួល និងតាមដានរាល់លិខិតចេញ ចូលរបស់រដ្ឋបាលខេត្តជាប់ជាប្រចាំ។

តារាងទី១៖លិខិតបទដ្ឋាន និងឯកសារប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | ៤៧ | ០ | ៤៧ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៦៨ | ១៦ | ៨៤ |
| ៣ | លិខិតដែលបានដាក់ចេញ | ៣.៨៧២ | ៤២៧ | ៤.២៩៩ |
| ៤ | លិខិតចូល | ៣.១៨៤ | ៣១៧ | ៣.៥០១ |
| ៥ | ឯកសារដែលបានធ្វើនីត្យានុកូលកម្ម | ៣៣ | ១០ | ៤៣ |
| ៦ | អនុស្សរណៈឬកិច្ចព្រមព្រៀង | ០ | ០ | ០ |
| ៧ | សៀវភៅគ្រួសារ | ៧១៩ | ៣២ | ៧៥១ |
| ៨ | អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ | ១៥.៦៤៨ | ១.២៥៨ | ១៦.៩០៦ |

### ១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន

- ស្រាវជ្រាវពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬខូច ដោយយថាហេតុ តាមការស្នើសុំរបស់សាមីខ្លួន ចំនួន១១នាក់ (ក្រុងខេមរភូមិន្ទចំនួន៤នាក់ និងស្រុកមណ្ឌលសីមាចំនួន៧នាក់)
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈ មេឃុំ ចៅសង្កាត់ បានចំនួន៣០នាក់ (ក្រុងខេមរភូមិន្ទចំនួន១០នាក់ ស្រុកមណ្ឌលសីមាចំនួន១៩នាក់ និងស្រុកបូទុ-មសាគរចំនួន១នាក់)
- បានបញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.crdepartment.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋបានចំនួន១៦ច្បាប់។

តារាងទី២៖ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | គ្រួសារសរុប | ៣៦.៥២២ | |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៤.៨៦៤ | |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១.៦៥៨ | |
| ៤ | ស្ត្រីជាមេគ្រួសារ | ៧.២១៩ | |
| ៥ | ប្រជាពលរដ្ឋសរុប | ១៥៥.៤១១ | ៧៩.២៣៤ |
| ៦ | កុមារអាយុក្រោម៦ឆ្នាំ | ១៧.៦៦១ | ៩.០១៥ |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៧ | កុមារអាយុពី៦ឆ្នាំដល់ក្រោម១៨ឆ្នាំ | ៣៨.២៨២ | ១៩.៣៣១ |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៩៩.៤៦៨ | ៥០.៨៨៨ |
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | ៥.៣៤១ | ១.៩៥១ |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | ១.៦០១ | ៥៩១ |

តារាងទី៣៖អត្រានុកូលដ្ឋាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ស្ថិតិចុះបញ្ជីកំណើត | ១.៨០៦ | ១៧៥ | ១.៩៨១ |
| ២ | បញ្ជាក់កំណើត | ២.២១៩ | ១៦៣ | ២.៣៨២ |
| ៣ | បញ្ជីមរណភាព | ៤៧០ | ៤២ | ៥១២ |
| ៤ | អាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ២.៦៩១ | ១៧២ | ២.៨៦៣ |
| ៥ | អាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | ១៤ | ០ | ១៤ |

### ១.១.៣-ការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលជូនសភាពាណិជ្ជកម្មខេត្ត ចូលរួមព្រឹត្តការណ៍ការកសាងសមត្ថភាព និងសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ នៃច្រករបៀងសេដ្ឋកិច្ចខាងកើត នៅខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៏។

តារាងទី៤៖ការងារទំនាក់ទំនងសាធារណៈ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សាធារណជនមកទំនាក់ទំនងនៅសាលាខេត្ត | ៣.១៧១ | ១៥៨ | ៣.៣២៩ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ១៣ | ២ | ១៥ |

### ១.១.៤-ការងារសរុប និងព័ត៌មាន

- បានរៀបចំរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២៤ សម្រាប់ដាក់ជូនគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តអនុម័តមុនផ្ញើទៅក្រសួងមហាផ្ទៃ
- បានប្រមូលផ្តុំព័ត៌មានអំពីមតិសាធារណៈ និងហេតុការណ៍ផ្សេងៗសម្រាប់ជាមូលដ្ឋានរៀបចំព័ត៌មានជូន ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តដើម្បីធ្វើការដោះស្រាយទាន់ពេលវេលា
- បានធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពការងាររបស់គណៈអភិបាលខេត្ត សមិទ្ធផលនានា សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្ត និងលិខិតបទដ្ឋានគតិយុត្តនានាជាប្រចាំដល់សាធារណជន តាមរយៈfacebook page channel telegram និងwebsite ផ្លូវការរបស់រដ្ឋបាលខេត្ត
- បានចូលរួមរាល់គ្រប់សកម្មភាពរបស់ថ្នាក់ដឹកនាំ ដើម្បីចងក្រងជាឯកសារ រូបភាព វីដេអូ និងបានរៀបចំសម្របសម្រួល កិច្ចការបច្ចេកទេសព័ត៌មានវិទ្យានៅក្នុងកិច្ចប្រជុំសំខាន់ៗ របស់ថ្នាក់ដឹកនាំ។

តារាងទី៥៖ការផ្សព្វផ្សាយព័ត៌មាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | វិទ្យុ | ២៨៣ | ១៧ | ៣០០ |
| ២ | ទូរទស្សន៍ | ៣៤៩ | ២៥ | ៣៧៤ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ២៩ | ៣ | ៣១ |

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ៤ | បណ្ដាញសង្គម (គេហទំព័ររដ្ឋបាលខេត្ត) | ៨.៦៦៧ | ១.០៦៥ | ៩.៧៣២ |
| ៥ | ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្ដី និងសារព័ត៌មាន | ០ | ០ | ០ |

## ១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា

- បានសម្របសម្រួលដំណើរការកិច្ចប្រជុំ និងរៀបចំសេចក្ដីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី៧ របស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំសេចក្ដីប្រកាសព័ត៌មានស្ដីពីកិច្ចប្រជុំសាមញ្ញលើកទី៧ អាណត្តិទី៤របស់ក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលកិច្ចប្រជុំសាមញ្ញលើកទី៤ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត
- បានរៀបចំសេចក្ដីព្រាងរបៀបវារៈ និងលិខិតអញ្ជើញសម្រាប់កិច្ចប្រជុំសាមញ្ញលើកទី៧ របស់ក្រុមប្រឹក្សាខេត្ត
- បានចាត់ចែងទុកដាក់ និងថែរក្សារាល់ឯកសារដែលបានអនុម័តរួចដោយក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលរាល់លិខិត និងឯកសារនានាដែលចរាចរចេញ ចូលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាខេត្ត បានទាន់ពេលវេលា។

តារាងទី៦៖ការរៀបចំវេទិកា

| ល.រ | ឈ្មោះវេទិកា | កាលបរិច្ឆេទ | អ្នកចូលរួម | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកស្រែអំបិល | ៩.១២.២០២៤ | ២៨៣ | ៦១ |
| ២ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកបូទុមសាគរ | ៩.១២.២០២៤ | ១៨៥ | ៤០ |
| ៣ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកកោះកុង | ១០.១២.២០២៤ | ៣០៥ | ៨៥ |
| ៤ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកគិរីសាគរ | ១១.១២.២០២៤ | ២២២ | ៨១ |
| ៥ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកថ្មបាំង | ១២.១២.២០២៤ | ២៣១ | ៨០ |
| ៦ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកមណ្ឌលសីមា | ១៣.១២.២០២៤ | ២៤៦ | ៨៦ |
| ៧ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅក្រុងខេមរភូមិន្ទ | ១៣.១២.២០២៤ | ២៥១ | ១០៧ |
| **សរុប** | | | **១.៧២៣** | **៥៤០** |

## ១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា

## ក)-ការងារគណៈអភិបាល

### ១. អភិបាល នៃគណៈអភិបាលខេត្ត

- បានចូលរួមជាអធិបតី គណៈអធិបតី និងភ្ញៀវកិត្តិយសក្នុងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន២៤លើក។

## ២. អភិបាលរង នៃគណៈអភិបាលខេត្ត

- បានចូលរួមជាអធិបតី គណៈអធិបតី និងភ្ញៀវកិត្តិយសក្នុងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន៨៩លើក។

តារាងទី៧៖កិច្ចប្រជុំគណៈអភិបាល

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ៨ | ១ | ៩ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ០ | ១ | ១ |
| ៣ | កិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាល | ២២ | ៣ | ២៥ |

### ខ)-ការងារគណៈកម្មាធិការនានា

តារាងទី៨៖កិច្ចប្រជុំគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ៤ | ១ | ៥ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ | ៥ | ១ | ៦ |
| ៣ | កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ៤ | ១ | ៥ |
| ៤ | កិច្ចប្រជុំក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ៩ | ១ | ១០ |
| ៥ | ផ្សេងៗ...... | | | |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ៩ | ០ | ៩ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ១១ | ១ | ១២ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ១១ | ១ | ១២ |

### ១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

### ១.១.៧.១-ការងារក្រុមប្រឹក្សា

- បានដំណើរការកិច្ចប្រជុំសាមញ្ញលើកទី៧ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- បានពិនិត្យ និងអនុម័តលើឯកសារពាក់ព័ន្ធនានាតាមរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី៧ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត។

### ១.១.៧.២-ការងារគណៈកម្មាធិការនានា

- **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**
  - បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៧ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
  - បានដឹកនាំកិច្ចប្រជុំសាមញ្ញលើកទី៥ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ដែលមានសមាជិកចូលរួមចំនួន១៥នាក់ ស្រី១៤នាក់ លើសមាជិកសរុបចំនួន១៩នាក់ ស្រី១៥នាក់
  - បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ៩ខែឆ្នាំ២០២៤ របស់គ.ក.ស.ក ខេត្ត គ.ក.ស.ក ស្រុកបូទុមសាគរ និងគ.ក.ស.ក ស្រុកកោះកុង ដែលមានអ្នកចូលរួមចំនួន៧៥នាក់ ស្រី៥៤នាក់ នៅសាលប្រជុំសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង។

- **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**
  - បាននិងកំពុងប្រមូលធាតុចូល ដើម្បីកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០២៥-២០២៩) ពីទីចាត់ការ អង្គភាព និងមន្ទីរជំនាញជុំវិញខេត្ត
  - បានចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (២០២៥-២០២៧)។
- **គណៈកម្មាធិការលទ្ធកម្ម**
- បានប្រជុំរៀបចំនីតិវិធីចរចាថ្លៃលទ្ធកម្មសំណង់ចំនួន៣គម្រោង រួមមាន ៖
  - **គម្រោងទី១** ជួសជុលសួនច្បារក្រាលការ៉ូក្រានីតទំហំ២.៥០០ម$^{2}$ ខឿនជុំវិញបេតុងប្រវែង៤៧១ម និងដំឡើងបង្កាន់ដៃប្រឡាយប្រវែង១៥០ម ចាក់បេតុងសសរបង្គោលបង្កាន់ដៃកម្ពស់១,៣ម ជុំវិញប្រឡាយប្រវែង១៥០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ជនមានពិការភាពប្រវែង៣១៧ម ទីតាំងស្ថិតនៅមុខចំណតរថយន្តឈ្នួល ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
  - **គម្រោងទី២** ជួសជុលសួនច្បារចិញ្ចើមផ្លូវក្រាលការ៉ូក្រានីតចំនួន១កន្លែង ទំហំសរុប៣.៧០០ម$^{2}$ ខឿនបេតុងចិញ្ចើមផ្លូវប្រវែង៨៥០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ជនមានពិការភាពប្រវែង៨៥០ម ទីតាំងចាប់ពីកែងមុខសាលាបឋមសិក្សាទីរួមខេត្តឆ្ពោះទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
  - **គម្រោងទី៣** ជួសជុលសួនច្បារចិញ្ចើមផ្លូវចាក់បេតុងចំនួន១កន្លែង ប្រវែង២៩៥ម ទទឹង៣៤ម កម្រាស់ ០,១៥ម ចាក់បេតុងខឿនប្រវែង៣៣៥ម និងរៀបជញ្ជាំងទប់ដីប្រវែង២៨០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ ជនមានពិការភាពប្រវែង២៩៥ម ចាប់ពីកែងចំណតរថយន្តឆ្ពោះមកសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

តារាងទី៩៖កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១១ | ១ | ១២ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ២ | ០ | ២ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ៣ | ០ | ៣ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ៩ | ១ | ១០ |
| ៦ | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | ៧ | ០ | ៧ |
| ៧ | ផ្សេងៗ............ | ០ | ០ | ០ |

## ១.២-ការងារផែនការ និងវិនិយោគ

### ១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

- បានគាំទ្រ និងសម្របសម្រួលសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៥-២០២៧)នៅថ្នាក់ក្រុង ស្រុក ដែលមានអ្នកចូលរួមសរុបចំនួន២៨០នាក់ ស្រីចំនួន ៤៦នាក់។

តារាងទី១០៖ការអនុវត្តគម្រោងវិនិយោគ(មានការគាំទ្រ បានអនុវត្តបញ្ចប់១០០% ដូចទិន្នន័យក្នុងតារាងខាងក្រោម)

| ល.រ. | ផ្នែក | សរុប | តម្លៃគម្រោង (លានរៀល) | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|---|
| | | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ៨ | ១៣.៨៣២,២០ | ០ | ០ | ៨ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | សង្គមកិច្ច | ១៥ | ៩៥២,៦០ | ០ | ០ | ១៥ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ១ | ២០២,០០ | ០ | ០ | ១ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២ | ២៥៣,០០ | ០ | ០ | ២ |
| **សរុប** | | **២៦** | **១៥.២៣៩,៨០** | **០** | **០** | **២៦** |

### ១.២.២-ការគាំទ្រមូលដ្ឋាន

### ១.២.២.១-ការគាំទ្ររដ្ឋបាលក្រុង ស្រុក

តារាងទី១១៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក

| ល.រ | ការបរិយាយ | ចំនួនក្រុង ស្រុក | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ៧ | ០ |
| ២ | ជំហានទី២ | ៧ | ០ |
| ៣ | ជំហានទី៣ | ០ | ៧ |

តារាងទី១២៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងក្រុង ស្រុក

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ១១ | ១១ | ១១ | ១១ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ០ | ០ | ០ | ០ |
| **សរុប** | | **១១** | **១១** | **១១** | **១១** |

### ១.២.២.២-ការគាំទ្ររដ្ឋបាលឃុំ សង្កាត់

➢ **ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង**

- បានចុះពិនិត្យ និងវាយតម្លៃបញ្ចប់ការងារ១០០%នៃផែនការការងារគម្រោងសាងសង់ផ្លូវបេតុងប្រើប្រាស់៖
  - មូលនិធិឃុំជ្រោយប្រស់ឆ្នាំ២០២៤ ចំនួន៣ខ្សែ ប្រវែងសរុប០,៤៤០គ.ម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅក្នុងភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - មូលនិធិឃុំស្រែអំបិលឆ្នាំ២០២៤ ចំនួន១ខ្សែ ប្រវែង០,៦៨៩គ.ម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិវាលជើង ឃុំស្រែអំបិល ស្រុកស្រែអំបិល។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - មូលនិធិឃុំជីផាតឆ្នាំ២០២៤ ចំនួន១ខ្សែ ប្រវែង០,៣៧៩គ.ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតនៅក្នុងភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំង។ ជាលទ្ធផល ការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការមានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស។
- បានចុះពិនិត្យ និងវាយតម្លៃបញ្ចប់ការងារ១០០%នៃផែនការការងារគម្រោងប្រើប្រាស់មូលនិធិឃុំតានូនឆ្នាំ២០២៤ ចំនួន២គម្រោង ស្ថិតនៅឃុំតានូន ស្រុកបូទុមសាគរ ៖

- ○ គម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ ប្រវែង០,៤៤៤គ.ម ទទឹង៥ម កម្រាស់១៥០ម.ម នៅភូមិព្រែកខ្យង
- ○ គម្រោងសាងសង់លូមូលកាត់ផ្លូវទោល០,៨ម ប្រវែង៩ម ចំនួន២កន្លែង នៅភូមិទួលពោធិ៍

ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស។

- បានចុះពិនិត្យ និងវាយតម្លៃបញ្ចប់ការងារ៥០%នៃផែនការការងារគម្រោងសាងសង់ផ្លូវបេតុងប្រើប្រាស់៖
  - ○ មូលនិធិសង្កាត់ស្ទឹងវែងឆ្នាំ២០២៤ ចំនួន៥ខ្សែ ប្រវែងសរុប០,៩៥៥គ.ម ទទឹង៤ម កម្រាស់១៥០ម.ម ស្ថិតនៅក្នុងភូមិព្រែកស្វាយ និងភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - ○ មូលនិធិសង្កាត់ស្មាច់មានជ័យឆ្នាំ២០២៤ចំនួន២ខ្សែ ប្រវែងសរុប០,៧៩៥គ.ម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅក្នុងភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - ○ មូលនិធិឃុំជីខលើឆ្នាំ២០២៤ ចំនួន១ខ្សែប្រវែង១,០៣០គ.ម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - ○ មូលនិធិឃុំជីខក្រោមឆ្នាំ២០២៤ ចំនួន១ខ្សែប្រវែង០,៥៦០គ.ម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិនាពិសី ឃុំជីខក្រោម ស្រុកស្រែអំបិល។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស
  - ○ មូលនិធិឃុំបឹងព្រាវឆ្នាំ២០២៤ លើគម្រោងសាងសង់ផ្លូវបេតុងអាមេចំនួន១ខ្សែ ប្រវែង១,០០៦គ.ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល។ ជាលទ្ធផលការអនុវត្តគម្រោងរបស់ក្រុមហ៊ុនអ្នកទទួលការ មានគុណភាពល្អ ស្របតាមបទដ្ឋានបច្ចេកទេស។
- បានចុះពិនិត្យ និងវាយតម្លៃការធានារយៈពេល៦ខែនៃកិច្ចសន្យាគម្រោងប្រើប្រាស់មូលនិធិឃុំព្រែកខ្សាច់ ឆ្នាំ២០២៣ លើការសាងសង់ផ្លូវបេតុងមានជើង១ខ្សែ ប្រវែង០,៣៣០គម ទទឹង៣ម កម្ពស់៣,២ម កម្រាស់៨០ម.ម និងស្លាកសញ្ញាគម្រោង១កន្លែង ស្ថិតនៅក្នុងភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ។ ជាលទ្ធផលគម្រោងមានគុណភាពល្អ និងត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋជាប្រចាំ។

➢ **ការចុះកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់**

- បានរៀបចំកិច្ចសន្យាគម្រោងមូលនិធិឃុំថ្មសឆ្នាំ២០២៤ ចំនួន៣គម្រោង ស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ៖
  - ○ គម្រោងសាងសង់ផ្លូវក្រាលក្រួសធម្មជាតិចំនួន៤ខ្សែ ប្រវែងសរុប៥,១៧០គ.ម ៖
    - **ខ្សែទី១** ប្រវែង០,៤៧២គ.ម ទទឹង៦ម កម្រាស់១៥០ម.ម នៅភូមិថ្មស
    - **ខ្សែទី២** ប្រវែង០,៣៥០គ.ម ទទឹង៦ម កម្រាស់១៥០ម.ម និងលូមូលភ្លោះកាត់ផ្លូវ១កន្លែង នៅភូមិថ្មស
    - **ខ្សែទី៣** ប្រវែង០,៥១៤គ.ម ទទឹង៦ម កម្រាស់១៥០ម.ម និងលូមូលទោលកាត់ផ្លូវ១កន្លែង នៅភូមិស្រែថ្មី
    - **ខ្សែទី៤** ប្រវែង៣,៨៣៤គ.ម ទទឹង៦ម កម្រាស់១៥០ម.ម នៅភូមិចម្លងគោ
  - ○ គម្រោងសាងសង់លូជ្រុងភ្លោះ៣មx១,៥ម ប្រវែង៦ម ចំនួន១កន្លែង ស្ថិតនៅភូមិស្រែត្រាវ
  - ○ គម្រោងសាងសង់អគារសាលប្រជុំ១កន្លែង បណ្តោយ១០ម ទទឹង៩ម សាងសង់ជើងទ្រធុងទឹកជ័រសម្រាប់ស្តុកទឹក៥.០០០លីត្រ ប្រក់ដំបូលស័ង្កសី ខួងអណ្តូងដាក់ម៉ូទ័រ និងសាងសង់របងសាលាឃុំប្រវែងសរុប ១៥៥ម៉ែត្រ នៅភូមិថ្មស ឃុំថ្មស ស្រុកបូទុមសាគរ។

តារាងទី១៣៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

| ល.រ. | ការបរិយាយ | ចំនួនឃុំ សង្កាត់ | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |

| | | | |
|---|---|---|---|
| ១ | ជំហានទី១ | ២៩ | ០ |
| ២ | ជំហានទី២ | ២៩ | ០ |
| ៣ | ជំហានទី៣ | ០ | ២៩ |

តារាងទី១៤៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ៤៧ | ៤៧ | ៤៧ | ៤៧ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ០ | ០ | ០ | ០ |
| **សរុប** | | **៤៧** | **៤៧** | **៤៧** | **៤៧** |

### ១.២.៣-ការវិនិយោគ

- ពុំមាន។

### ១.២.៤-ការងារសេវាសង្គម

- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៥របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ដែលមានសមាជិកចូលរួមចំនួន១៥នាក់ ស្រី១៤នាក់លើសមាជិកសរុបចំនួន១៩នាក់ ស្រី១៥នាក់
- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារ៩ខែឆ្នាំ២០២៤ របស់គ.ក.ស.ក ខេត្ត គ.ក.ស.ក ស្រុកបូទុមសាគរ និងគ.ក.ស.កស្រុកកោះកុង ដែលមានអ្នកចូលរួមចំនួន៧៥នាក់ ស្រី៥៤នាក់ នៅសាលប្រជុំសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង។

### ១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប

- បានរៀបចំរបាយការណ៍វឌ្ឍនភាពការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជូន គ.ជ.អ.ប។

តារាងទី១៥៖លទ្ធផលសម្រេចបាន

| ល.រ | ឈ្មោះលទ្ធផល | ស្ថានភាព | % សម្រេច | % ចំណាយ |
|---|---|---|---|---|
| ១ | ការពង្រឹងយន្តការដឹកនាំកំណែទម្រង់ ដើម្បីបន្តជំរុញកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការរីកចំរើនទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | កំពុងអនុវត្ត | ១០០% | ១០០% |
| ២ | ការផ្សព្វផ្សាយចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | កំពុងអនុវត្ត | ១០០% | ១០០% |
| ៣ | ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | កំពុងអនុវត្ត | ១០០% | ១០០% |
| ៤ | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង/ស្រុក ឃុំ/សង្កាត់ | កំពុងអនុវត្ត | ១០០% | ១០០% |
| ៥ | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | កំពុងអនុវត្ត | ៩០% | ៩០% |

| | | | | |
|---|---|---|---|---|
| ៦ | ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីឈានដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ១០០% | ១០០% |
| ៧ | ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | កំពុងអនុវត្ត | ១០០% | ១០០% |
| ៨ | ការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ១០០% | ១០០% |
| ៩ | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ១០០% | ១០០% |
| ១០ | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ១០០% | ១០០% |
| ១១ | ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែន ការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹងនិងកំណត់យ៉ាងច្បាស់លាស់ | កំពុងអនុវត្ត | ១០០% | ១០០% |
| ១២ | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ១០០% | ១០០% |
| ១៣ | ការពិនិត្យ កែលម្អ និងពង្រឹង ការអនុវត្តយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឈានដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | កំពុងអនុវត្ត | ១០០% | ១០០% |
| ១៤ | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | កំពុងអនុវត្ត | ១០០% | ១០០% |
| ១៥ | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | កំពុងអនុវត្ត | ១០០% | ១០០% |

**១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា**

- **ការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ខេត្តកោះកុង**
  - បានផ្តល់ការហ្វឹកហ្វឺនដល់ក្រុមការងារស្រុកកោះកុង ស្រុកបូទុមសាគរ ស្រុកថ្មបាំង និងក្រុមខេមរភូមិន្ទ លើប្រធានបទ កិច្ចការងារត្រូវណែនាំ និងគាំទ្រឃុំ ដើម្បីត្រៀមចូលរួមសិក្ខាសាលាសមាហរណកម្មផែនការឃុំ សង្កាត់ នៅថ្នាក់ស្រុក និងកិច្ចត្រៀមសម្រាប់ការវាយតម្លៃឆមាសទី២ ឆ្នាំ២០២៤។
  - បានតាមដានត្រួតពិនិត្យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមទ្រទ្រង់សុខភាពភូមិ នៃស្រុកមណ្ឌលសីមា និងស្រុកបូទុមសាគរ។ ជាលទ្ធផល ក្រុមទ្រទ្រង់សុខភាពភូមិ យល់ដឹងបន្ថែមអំពីការកំណត់លក្ខណៈក្មេងដែលខ្វះអាហារូបត្ថម្ភ និងការបញ្ជូនកុមារទាំងនោះទៅនៅមណ្ឌលសុខភាព។

## ១.៣-ការគ្រប់គ្រងធនធានមនុស្ស

**១.៣.១-ការងារគ្រប់គ្រងបុគ្គលិក**

- បានរៀបចំបេសកកម្មជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីសាលាខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត ក្នុងខែធ្នូ ឆ្នាំ២០២៤ សរុបចំនួន២២២លេខ។
- បានរៀបចំដីកាលេខ ០៤០/២៤ ដក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តឱ្យចូលនិវត្តន៍ តាមកាលកំណត់ ចំនួន១រូប។
- បានរៀបចំដីកាលេខ ០៤១/២៤ ដក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១រូប។

- បានរៀបចំដីកាលេខ ០០៩/២៤ ដក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការអនុញ្ញាតឱ្យបង្កើត និងជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាសគ្រឹះស្ថាន អនុញ្ញាតឱ្យលោកស្រី មីន ឈុនដារី នាយិកា សាខាធនាគារកាណាឌីយ៉ា ខេត្តកោះកុងជ្រើសរើសសន្តិសុខឯកជន ចំនួន៦នាក់។
- បានរៀបចំលិខិតលេខ ៦៧២/២៤ សជណ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការផ្តល់ទិន្នន័យបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកោះកុង សម្រាប់ឆ្នាំ២០២៤ ជូនអគ្គនាយកធនធានមនុស្ស ក្រសួងមហាផ្ទៃ។

តារាងទី១៦៖ស្ថិតិក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា(ចំនួនក្រុមប្រឹក្សាដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត) | ១៩ | ៣ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៤ | អភិបាល | ១ | ១ |
| ៥ | អភិបាលរង | ១០ | ២ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ៤ | ១ |
| ៨ | នាយកទីចាត់ការ/ប្រធានអង្គភាព | ៧ | ០ |
| ៩ | ប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ១ | ០ |
| ១០ | នាយករងទីចាត់ការ/អនុប្រធានអង្គភាព | ១៤ | ៤ |
| ១១ | អនុប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ២ | ១ |
| ១២ | ប្រធានការិយាល័យ | ១៥ | ៣ |
| ១៣ | អនុប្រធានការិយាល័យ | ១៤ | ៦ |
| ១៤ | មន្ត្រីការិយាល័យ | ១៣ | ៦ |
| ១៥ | បុគ្គលិកកិច្ចសន្យា | ៣៩ | ២៣ |

- **ស្ថិតិការិយាល័យប្រជាពលរដ្ឋខេត្ត**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ១ |
| ៣ | ប្រធានផ្នែក | ២ | ០ |
| ៤ | អនុប្រធានផ្នែក | ៤ | ០ |
| ៥ | មន្ត្រី | ០ | ០ |

- **ស្ថិតិបុគ្គលិកមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**

| ល.រ | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានមជ្ឈមណ្ឌល | ១ | ០ |
| ២ | មន្ត្រីជាប់កិច្ចសន្យា | ១ | ១ |

## ១.៣.២-ការងារកសាងសមត្ថភាព

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៍ បែបបទ និងនីតិវិធី នៃការគ្រប់គ្រងធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដល់រដ្ឋបាលក្រុង ស្រុក មន្ទីរសុខាភិបាល និងអ្នកពាក់ព័ន្ធ។
- បានរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស ស្តីពីការគ្រប់គ្រងរដ្ឋបាល ក្រុង ស្រុក តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ជូនក្រុមប្រឹក្សាក្រុង ស្រុក អាណត្តិទី៤ ឆ្នាំ២០២៤។

- បានបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ២០២៤ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល និងតម្រូវការអភិវឌ្ឍន៍សមត្ថភាពឆ្នាំ២០២៥ ជូនសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ។

តារាងទី១៧៖ការកសាងសមត្ថភាព

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | គោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ២ | ៨០ | ១៨ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស |
| ២ | ការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ | ២ | ៩៨ | ២០ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស សហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ |
| **សរុប** | | **៤** | **១៧៨** | **៣៨** | |

## ១.៤-ការងារអន្តរវិស័យ

### ១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច

- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់អង្គការយូអរស៊ី(URC) ស្នើសុំលិខិតគាំទ្រពីមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ដើម្បីបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិជាមួយក្រសួងសុខាភិបាល។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទាខេត្តកំពង់ស្ពឺ ស្នើសុំចុះផ្តល់សេវាពិនិត្យ និងជួលជុលអវយវៈសិប្បនិម្មិត រណប រទេះរុញ ឧបករណ៍ទ្រទ្រង់រាងកាយ និងបម្លាស់ទី ក្នុងភូមិសាស្ត្រស្រុកថ្មបាំង ស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងក្រុងខេមរភូមិន្ទ។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីរបាយការណ៍របស់រដ្ឋបាលស្រុកមណ្ឌលសីមា ស្តីពីស្ថិតិប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកស្អាត និងបណ្តាញអគ្គិសនី ក្នុងភូមិសាស្ត្រស្រុកមណ្ឌលសីមា។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ឈ្មោះ ស្តើង ស្រីមុំ ស្នើសុំសាងសង់ផ្ទះសំណាក់ខ្នាតតូច និងអាហារដ្ឋាន ស្ថិតនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្នើសុំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រចាំឆ្នាំ២០២៤។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រុមហ៊ុន អ៊ីវូលីង ខូអិលធីឌី ស្នើសុំសាងសង់បង្គោលអង់តែនទូរស័ព្ទចល័ត ចំនួន១កន្លែង កម្ពស់៣០ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុមខេមរភូមិន្ទ។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រុមហ៊ុន អ៊ីដតខូ ខេមបូឌា ស្នើសុំសាងសង់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ស្ថានីយអង់តែនសង់ផ្ទាល់ដី ចំនួន១ទីតាំង ក្នុងភូមិសាស្ត្រខេត្តកោះកុង។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ស្នើសុំចេញសេចក្តីជូនដំណឹងស្តីពីការបិទការធ្វើនេសាទត្រីកាម៉ុង ក្នុងដែនជម្រកសុវត្ថិភាពត្រីកាម៉ុងនៅឃុំពាមក្រសោប ស្រុកមណ្ឌលសីមា សម្រាប់ឆ្នាំ២០២៤-២០២៥។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្នើសុំរបាយការណ៍ស្តីពីការដោះស្រាយបញ្ហាជនអនាថា ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥។

- **មជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**
  - ***សកម្មភាព និងលទ្ធផលការងារ ៖***
    - បានដោះស្រាយអាហារហូបចុកដល់កុមារកំព្រានៅក្នុងមណ្ឌលជាប្រចាំ ស្របតាមគោលការណ៍កំណត់។
    - បានសម្របសម្រួលកិច្ចការរដ្ឋបាលប្រចាំថ្ងៃ និងការមើលថែទាំកុមារក្នុងមណ្ឌល ក្នុងការឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្ត។
  - ***ការចូលរួមពីមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា***
    - លោកជំទាវ ចេង វន្នី សមាជិកក្រុមប្រឹក្សាខេត្ត និងក្រុមគ្រួសារ បានឧបត្ថម្ភអង្ករចំនួន៥០គីឡូក្រាម ប្រចាំខែដល់មជ្ឈមណ្ឌល ។
    - លោក សំ វីរៈ និងក្រុមគ្រួសារ បានឧបត្ថម្ភអង្ករចំនួន៥០គីឡូក្រាម ប្រចាំខែដល់មជ្ឈមណ្ឌល។

**១.៤.២-ការងារគ្រប់គ្រងការអនិវឌ្ឍ និងសំណង់**

- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់សមាគមអតីតយុទ្ធជនកម្ពុជាខេត្តកោះកុង ស្នើសុំដី១កន្លែង ទំហំ១ហិកតា ដើម្បីសាងសង់អគារទីស្នាក់ការសមាគមអតីតយុទ្ធជនខេត្តកោះកុង។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ឈ្មោះ មុន ម៉ន តំណាងប្រជាពលរដ្ឋក្នុងភូមិព្រែកស្វាយ ស្នើសុំឈូសឆាយផ្លូវមួយខ្សែដែលជាផ្លូវចាស់មានសភាពខូចខាតទ្រុឌទ្រោមពិបាកធ្វើដំណើរ(ស្ថិតក្នុងប្លង់គោល) នៅក្នុងភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យនៃការទន្ទ្រានដីរដ្ឋ ពីប្រជាពលរដ្ឋនៅតាមបណ្តាលរាជធានី ខេត្ត។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ប្រជាពលរដ្ឋ ស្នើសុំចុះបញ្ជីដីចំនួន៦សំណើរួមមាន៖
  - ឈ្មោះ ជា លាងហុង ដីទំហំ២៩៤.៦៦៩ម² ស្ថិតនៅភូមិកោះអណ្តែត ឃុំតាតៃក្រោម ស្រុកកោះកុង
  - ឈ្មោះ ស៊ឹម ពិសិដ្ឋ ដីទំហំ៩៩ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ឃុំសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ឈ្មោះ តាន់ យុនរតនា ដីទំហំ១.១២៥ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ឈ្មោះ សំយ៉ុត សែងថង ដីទំហំ៨០.៩៥៣ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ឈ្មោះ នួន វុត្ថា ដីទំហំ៤១១ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ឈ្មោះ នាក់ លី ដីទំហំ១០០ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។

**១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ:**

- បានសម្របសម្រួលរៀបចំវេទិកាពិគ្រោះយោបល់រដ្ឋបាលខេត្តកោះកុងជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចខេត្តប្រចាំឆមាសទី២ ឆ្នាំ២០២៤។
- បានសម្របសម្រួលរៀបចំពិធីប្រកាសក្រុមការងារ និងផ្សព្វផ្សាយផែនការអនុវត្តលេខ០០៣ ផ.ក ស្តីពីការចុះត្រួតពិនិត្យវត្តមានស្នាក់នៅរបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីការបង្វែរណើរបស់ក្រសួងមហាផ្ទៃ ស្តីពីការចុះផ្សាយខ្លឹមសារគេហទំព័រក្រុងកម្ពុជា ពាក់ព័ន្ធនឹងឈ្មោះ ខៀវ សុកាន បានជួលកម្មករឱ្យកាប់ទន្ទ្រានយកដីព្រៃកោងកាង និងព្រៃលិចទឹកប្រមាណ១០ហិកតា យកធ្វើកម្មសិទ្ធិផ្ទាល់ខ្លួន។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់វិទ្យុចក្ខុវិស័យអាស៊ី ស្នើសុំកិច្ចសហការក្នុងការចូលរួមការស្ទង់មតិ តាមរយៈប្រព័ន្ធតំណរភ្ជាប់អនឡាញ (Link) ក្នុងភូមិសាស្ត្រខេត្តកោះកុង។
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសេចក្តីជូនដំណឹង ស្តីពីការធ្វើសកម្មភាព របស់សមាគមយុវជនអ្នកបន្តវេន ក្នុងភូមិសាស្ត្រខេត្តកោះកុង។

តារាងទី១៨៖ការដោះស្រាយវិវាទ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ករណីសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខេត្ត | ១០ | ១ | ១១ |
| សរុប | | **១០** | **១** | **១១** |

### ១.៨.៨-ការងារគ្រប់គ្រងកាកសំណល់

– ពុំមាន។

### ១.៩-ការងារអង្គភាពច្រកចេញចូលតែមួយ

– បានពង្រឹងការអនុវត្តការងាររបស់មន្ត្រីជួរមុខ និងជួរក្រោយ ឱ្យយកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរតាមនីតិវិធី។

– បានផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**តារាងទី១៩៖ស្ថានភាពចំនួនសេវា និងចំណូល**

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ចំនួនថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| | | នាក់ | ស្ត្រី | | |
| ១ | នីត្យានុកូលកម្ម(ថតចម្លង) | ១ | ០ | ១០.០០០ | |
| ២ | ការងាររដ្ឋបាល | ៤៨៤ | ២៧៩ | ១១.១០៣.៥០០ | |
| | -សេវាប័ណ្ណព្រំដែន(រដ្ឋបាលខេត្ត) | ២៨៩ | ១៧៦ | ៥.៧៨០.០០០ | |
| | -សេវាបន្តសុពលភាពប័ណ្ណព្រំដែន (រដ្ឋបាលខេត្ត) | ៦៩ | ២៥ | ៦៩០.០០០ | |
| | -សេវាប័ណ្ណព្រំដែន (ក្រុង ស្រុក) | ១៨៤ | ៩៩ | ៣.៦៨០.០០០ | |
| | -សេវាចាក់បំពេញអាចម៍ដីកម្មសិទ្ធិឯកជន | ១ | ០ | ៨០.០០០ | |
| | -ដំឡើងទីតាំងបាណូអចល័ត | ១ | ០ | ៧៥៣.៥០០ | |
| ៣ | សុខាភិបាល | ២ | ០ | ៣៥០.០០០ | |
| ៤ | ទេសចរណ៍ | ២៩ | ១៦ | ៨.៨៣៥.០០០ | |
| ៥ | សាធារណការ និងដឹកជញ្ជូន | ៥៧ | ០៦ | ៧.៥១០.០០០ | |
| | -សេវាដឹកជញ្ជូនតាមផ្លូវគោក | ៥៧ | ០៦ | ៧.៥១០.០០០ | (បង់សេវាតាមវីង) |
| | -សេវាដឹកជញ្ជូនតាមផ្លូវទឹក | ០ | ០ | ០ | |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ០ | ០ | ០ | |
| ៧ | ព័ត៌មាន | ២២ | ៤ | ២២.៣៦០.០០០ | |
| ៨ | បរិស្ថាន | ០ | ០ | ០ | |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៤ | ២ | ៥២០.០០០ | |
| ១០ | រ៉ែ និងថាមពល | ៦ | ៤ | ៩០០.០០០ | |
| ១១ | ពាណិជ្ជកម្ម | ១ | ០ | ២០០.០០០ | |
| ១២ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ក)+(ខ) | ៦៣២ | ១៨០ | ១១៩.៣៧០.៤៨៦ | |
| | (ក) សំណង់ | ២ | ០ | ៦.៣៧៤.៤០០ | |
| | (ខ) សុរិយោដី | ៦៣០ | ១៨០ | ១១២.៩៩៦.០៨៦ | |
| ១៣ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧០ | ២៩ | ២.៩១៥.៩៥០ | |
| ១៤ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០ | ០ | ០ | |
| | **សរុបរួម** | **១.៣០៨** | **៥២០** | **១៧៤.០៧៤.៩៣៦** | |

## ១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

- សម្រាប់ខែធ្នូ ឆ្នាំ២០២៤នេះ ការិយាល័យប្រជាពលរដ្ឋខេត្ត មិនបានទទួលពាក្យបណ្តឹងទេ។
- បានទទួលព័ត៌មានផ្សេងៗអនាមិក តាមធ្យោបាយនានាចំនួន១២ករណី (តាមរយៈប្រអប់សំបុត្រចំនួន៨ករណី និង តាមរយៈកម្មវិធីទូរស័ព្ទដៃ "មតិយើង" ចំនួន៤ករណី)។

តារាងទី២០៖ការដោះស្រាយបណ្តឹង

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | បណ្តឹងដែលទទួលបាន(ក្នុង និងក្រៅសមត្ថកិច្ច) | ២៦ | ០ | ២៦ |
| ១.១ | បណ្តឹងស្ថិតក្នុងសមត្ថកិច្ច | ១៥ | ០ | ១៥ |
| | - បញ្ចប់ការដោះស្រាយ | ៧ | ០ | ៧ |
| | - កំពុងដោះស្រាយ (នៅសល់) | ០ | ០ | ០ |
| | - បិទសំណុំរឿង | ៨ | ០ | ៨ |
| ១.២ | បណ្តឹងក្រៅសមត្ថកិច្ច | ១១ | ០ | ១១ |
| ២ | ព័ត៌មានផ្សេងៗ | ១៩៦ | ១២ | ២០៨ |
| **សរុបរួម(១+២)** | | **២២២** | **១២** | **២៣៤** |

## ១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- ពុំមានសកម្មភាព។

## ១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

### ១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ

- មានច្រកទ្វារព្រំដែនអន្តរជាតិចំនួន១កំពុងដំណើរការ គឺទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម។

### ១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន

- បញ្ហាសន្តិសុខ៖ (ពុំមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់)។
- សណ្តាប់ធ្នាប់៖ បានរៀបចំសណ្តាប់ធ្នាប់ និងសម្អាតអនាម័យបរិស្ថាននៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមជាប្រចាំ។ ជាលទ្ធផល ពុំទាន់បានល្អនៅឡើយ មូលហេតុផ្លូវតូចចង្អៀត និងពុំទាន់មានចំណតរថយន្ត សម្រាប់រថយន្តរង់ចាំទទួលដឹកអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលឆ្លងកាត់។ បច្ចុប្បន្នរថយន្តចតបណ្តោះអាសន្ននៅលើទ្រូងផ្លូវ ជាហេតុធ្វើឱ្យមានការកកស្ទះចរាចរណ៍ខ្លះៗ។

### ១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ)

- បានពិនិត្យប្រជាពលរដ្ឋ និងជនបរទេសចេញចូលឆ្លងកាត់តាមច្រកទ្វារព្រំដែន ដូចខាងក្រោម ៖
  - ពលរដ្ឋខ្មែរចូល៖ ចំនួន៧.៥៣៤នាក់ ស្រី៣.៩៧៦នាក់
  - ជនបរទេសចូល៖ ចំនួន៧.០៣៦នាក់ ស្រី២.៣៤៥នាក់ មាន៥៤សញ្ជាតិ
  - ពលរដ្ឋខ្មែរចេញ៖ ចំនួន៧.១៧០នាក់ ស្រី៣.៧៣៣នាក់
  - ជនបរទេសចេញ៖ ចំនួន៦.៣៤៣នាក់ ស្រី២.១៤៣នាក់ មាន៥៨សញ្ជាតិ

  **ជាលទ្ធផល** ប្រជាពលរដ្ឋខ្មែរ និងជនបរទេសចេញចូលឆ្លងកាត់ព្រំដែនខាងលើមានភាពស្របច្បាប់។
- បានពិនិត្យមធ្យោបាយធ្វើដំណើរចេញចូលឆ្លងកាត់តាមច្រកទ្វារព្រំដែន ដូចខាងក្រោម ៖
  - រថយន្តចូល៖ ចំនួន២.៨០៨គ្រឿង
  - ទោចក្រយានយន្តចូល៖ ចំនួន៣៦គ្រឿង
  - រថយន្តចេញ៖ ចំនួន២.៥៧៥គ្រឿង
  - ទោចក្រយានយន្តចេញ៖ ចំនួន២៩គ្រឿង

  **ជាលទ្ធផល** រថយន្ត និងទោចក្រយានយន្តខាងលើ មានឯកសារត្រឹមត្រូវស្របច្បាប់។

### ១.៨.៤-ការផ្លាស់ប្តូរទំនិញ

- ទំនិញនាំចូល ៖ កូនឈើ កូនផ្កា ផ្លែឈើចម្រុះ ត្រី សាច់ បន្លែ ភេសជ្ជៈ ជ័រប្លាស្ទីក ម៉ូតូ គ្រឿងអេឡិចត្រូនិច និង គ្រឿងសំណង់ ។ល។
- ទំនិញនាំចេញ ៖ ផលនេសាទសមុទ្រ។

### ១.៨.៥-កិច្ចសហប្រតិបត្តិការ

- បានសហការទំនាក់ទំនងល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាការណែនាំរបស់អាជ្ញាធរខេត្ត។ ជាលទ្ធផល មន្រ្តីជំនាញប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានផ្តល់ភាពងាយស្រួលដល់ភ្ញៀវជាតិ និងអន្តរជាតិ ទាំងធ្វើដំណើរចូល និងធ្វើដំណើរចេញបានល្អប្រសើរ ។
- បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដោយឈរលើគោលជំហរគោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរក្នុងតំបន់ព្រំដែន ទទួលបានលទ្ធផល ល្អប្រសើរ។
- បានសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋប្រកបរបរស្របច្បាប់ប្រចាំថ្ងៃតាមព្រំដែន។ ជាលទ្ធផល កិច្ចសហប្រតិបត្តិការមានភាពរលូន និងល្អប្រសើរ។

## ១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១.៩.១-ការងារហិរញ្ញវត្ថុ

- ការអនុវត្តចំណូល និងចំណាយរបស់រដ្ឋបាលខេត្តប្រចាំខែធ្នូ ឆ្នាំ២០២៤ ទីចាត់ការហិរញ្ញវត្ថុ សម្រេចបានការងារប្រមូលចំណូល និងចំណាយដែលមានទឹកប្រាក់ ដូចខាងក្រោម ៖

តារាងទី២១៖ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | ច្បាប់ដើមឆ្នាំ | ច្បាប់កែតម្រូវ | អនុវត្ត | ភាគរយ |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=3/2 |
| **ផ្នែកចំណូល** | | | | | |
| 70 | ចំណូលសារពើពន្ធ | ៨.៩៩៣.000.000 | ៨.៩៩៣.000.000 | ១.១៦២.៤៦៥.៣៦៧ | ១២,៩២% |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ៣៣៨.៦00.000 | ៣៣៨.៦00.000 | ២៩.១៦៣.៣៩៤ | ៨,៦១% |
| 73 | ផលទុនលើការលក់-ជួលទ្រព្យ | ១.៩៧៧.៤00.000 | ១.៩៧៧.៤00.000 | - | 0% |
| 74 | ផលពីការពិន័យ និងការដាក់ | ៥0.000.000 | ៥0.000.000 | - | 0% |
| 75 | ការឧត្តម្ភធន(អំណោយ) | ១៣.៥00.000.000 | ១៣.៥00.000.000 | ២.៣00.000.000 | ១៧,0៣% |
| 76 | ផលហិរញ្ញវត្ថុ | - | - | - | - |
| 77 | ផលផ្សេងៗ និងផលពិសេស | - | - | - | - |
| **សរុបរួមចំណូល** | | **២៤.៨៥៩.000.000** | **២៤.៨៥៩.000.000** | **៣.៤៩១.៦២៨.៧៦១** | **១៤,0៤%** |
| **ផ្នែកចំណាយ** | | | | | |
| 60 | ការទិញ | ១.៦៨៨.000.000 | ១.៧២៨.៦00.000 | ៣0.0៧២.៥៩៥ | ១,៧៣% |
| 61 | សេវាកម្ម | ១៤.៣៦៩.២00.000 | ១៧.២៩១.៦00.000 | ១២.១៦៣.៧0៦.៦៩0 | ៧0,៣៤% |
| 62 | អត្ថប្រយោជន៍សង្គម | ៦១0.000.000 | ៥៩0.000.000 | ៤៥.៤៩៨.៥00 | ៧,៧១% |
| 63 | ពន្ធ និងអាករ | ៨00.000 | ៨00.000 | - | 0% |
| 64 | បន្ទុកបុគ្គលិក | ៣.៨៤៦.000.000 | ៣.៨៤៦.000.000 | ២១៩.0៣៣.៣១0 | ៥,៦៩% |
| 65 | ឧបត្ថម្ភធននិងជំនួយសង្គម | ២0២.000.000 | ៩៦៩.000.000 | ៥២.000.000 | ៥,៣៦% |
| 66 | បន្ទុកហិរញ្ញវត្ថុ | - | - | - | - |

| | | | | | |
|---|---|---|---|---|---|
| 67 | បន្ទុកពិសេស | - | - | - | - |
| 68 | ទាយជ្ជទានឱ្យដល់រំលស់អចលនកម្ម | - | - | - | - |
| 69 | ចំណាយមិនបានគ្រោងទុក | ៧៤៣.០០០.០០០ | - | - | 0% |
| 20 | អចលកម្មអរូបី | - | - | - | - |
| 21 | អចលកម្មរូបី | ១.៧៤០.០០០.០០០ | ១.៧៤០.០០០.០០០ | ១.៧៣៧.០០០.០០០ | ៩៩,៨២% |
| 23 | អចលកម្មកំពុងដំណើរការ | - | - | - | - |
| **សរុបចំណាយ** | | **២៣.១៩៩.០០០.០០០** | **២៦.១៦៦.០០០.០០០** | **១៤.២៤៦.៩៧៥.០៩៥** | **៥៤,៤៤%** |

### ១.៩.២-ការងារគណនេយ្យ

- បានរៀបចំអាណត្តិបើកបៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២៤ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងមន្ត្រីជាប់កិច្ចសន្យារួចរាល់។

### ១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ

តារាងទី២២៖ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ. | ការបរិយាយ | ឯកតា | ចំនួន | | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | ចុងគ្រា | |
| ១-អចលនទ្រព្យ | | | | | | |
| ១ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម² | ១៩.០៤៧ | 0 | ១៩.០៤៧ | |
| | អគារ | ខ្នង | ៣ | 0 | ៣ | |
| ២ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម² | ១១.៤០៣ | 0 | ១១.៤០៣ | |
| | អគារ | ខ្នង | ១ | 0 | ១ | |
| ៣ | ដី ភូមិ១ ស្នាច់មានជ័យ | ម² | ៤.៩៣៩ | 0 | ៤.៩៣៩ | |
| | អគារ | ខ្នង | ១ | 0 | ១ | |
| ៤ | ដី ភូមិ៣ ស្នាច់មានជ័យ | ម² | ៤.១១៧ | 0 | ៤.១១៧ | |
| | អគារ | ខ្នង | ២ | 0 | ២ | |
| ៥ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម² | ៩.៨០១ | 0 | ៩.៨០១ | |
| | អគារ | ខ្នង | ៣ | 0 | ៣ | |
| ២-ឧបករណ៍ សម្ភារ និងបរិក្ខារ(យានយន្ត ម៉ាស៊ីន តុ ...) | | | | | | |
| ១ | ម៉ាស៊ីនភ្លើង | គ្រឿង | ៣ | 0 | ៣ | |
| ២ | ទូរបញ្ជាម៉ាស៊ីនភ្លើង | គ្រឿង | ១ | 0 | ១ | |

### ១.១០-ការងារលទ្ធកម្ម

- បានរៀបចំនីតិវិធីចរចាថ្លៃលទ្ធកម្មសំណង់ចំនួន៣គម្រោង រួមមាន ៖
    - **គម្រោងទី១** ជួសជុលសួនច្បារក្រាលការ៉ូក្រានីតទំហំ២.៥០០ម² ខឿនជុំវិញបេតុងប្រវែង៤៧១ម និងដំឡើងបង្កាន់ដៃប្រឡាយប្រវែង១៥០ម ចាក់បេតុងសសរបង្គោលបង្កាន់ដៃកម្ពស់១,៣ម ជុំវិញប្រឡាយប្រវែង១៥០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ជនមានពិការភាពប្រវែង៣១៧ម ទីតាំងស្ថិតនៅមុខចំណតរថយន្តឈ្នួល ភូមិ១ សង្កាត់ស្នាច់មានជ័យ ក្រុងខេមរភូមិន្ទ
    - **គម្រោងទី២** ជួសជុលសួនច្បារចិញ្ចើមផ្លូវក្រាលការ៉ូក្រានីតចំនួន១កន្លែង ទំហំសរុប៣.៧០០ម² ខឿនបេតុងចិញ្ចើមផ្លូវប្រវែង៨៥០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ជនមានពិការភាពប្រវែង៨៥០ម ទីតាំង

ចាប់ពីកែងមុខសាលាបឋមសិក្សាទីរួមខេត្តឆ្ពោះទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង ស្ថិតក្នុងភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- **គម្រោងទី៣** ជួសជុលសួនច្បារចិញ្ចើមផ្លូវចាក់បេតុងចំនួន១កន្លែង ប្រវែង២៩៥ម ទទឹង៣៤ម កម្រាស់ ១៥០ម.ម ចាក់បេតុងខឿនប្រវែង៣៣៥ម និងរៀបជញ្ជាំងទប់ដីប្រវែង២៨០ម និងក្រាលការ៉ូថ្មើរជើងសម្រាប់ ជនមានពិការភាពប្រវែង២៩៥ម ចាប់ពីកែងចំណតរថយន្តឈ្នួលឆ្ពោះមកសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង ស្ថិតក្នុងភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

## ១.១១-ការងារសុខាភិបាល

- បានពិនិត្យ និងពិគ្រោះជំងឺក្រៅសរុបចំនួន៨.០២១ករណី (ករណីថ្មីចំនួន៧.២៣៨ករណី) ជូនប្រជាជន ដូចខាងក្រោម ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៣.៦១៥ករណី
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ២.១១៦ករណី
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ១.៣៥៧ករណី
  - ករណីលើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន៩៣៣ករណី។
- ករណីអ្នកជំងឺសម្រាកពេទ្យសរុបចំនួ១.០៤៦នាក់ រួមមាន ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៤៦៧ករណី
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ៣៧៤ករណី
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ១៨៩ករណី
  - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន១៦ករណី។
- ការសម្រាលកូនសរុបចំនួន១៩៥នាក់ (សម្រាលនៅមណ្ឌលសុខភាពចំនួន៧៨នាក់) មានដូចខាងក្រោម ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៥៧នាក់
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចំនួន៧៦នាក់
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលចំនួន៦១នាក់
  - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជដ្ឋាភិបាលមានចំនួន១នាក់។
- បានផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះសរុបចំនួ៣១៩ដូស។
- បានពិនិត្យផ្ទៃពោះជូនស្ត្រីមុនសម្រាលកូនសរុបចំនួន១.០៥៩លើក។
- បានពិនិត្យផ្ទៃពោះជូនស្ត្រីក្រោយសម្រាលកូនចំនួន២៨៩លើក។
- បានចាក់ថ្នាំបង្ការ១១មុខ ដល់កុមារចំនួន២០៨នាក់។
- បានផ្តល់សេវាពន្យារកំណើតបន្ត ដល់ស្ត្រីនៅតាមមូលដ្ឋានសុខាភិបាលសរុបចំនួន២.៤៥៨នាក់។
- បានផ្តល់សេវាពន្យារកំណើតបន្ត ដល់ស្ត្រីនៅសហគមន៍សរុបចំនួន១.៥៥៨នាក់។
- ក្រុមការងារចត្តាឡីស័កប្រចាំការនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម បានអនុវត្តការងារ គិតចាប់ពី (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤) ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖
  - បានពិនិត្យកម្តៅលើអ្នកបើកបររថយន្តដឹកទំនិញចូលខេត្តកោះកុងសរុបចំ២.០៦២នាក់ ស្រី៦២នាក់
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តដឹកទំនិញចូលខេត្តកោះកុង សរុបចំនួន២.០៦២គ្រឿង
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តទេសចរណ៍ចូលខេត្តកោះកុង សរុបចំនួន៩០៥គ្រឿង

- បានពិនិត្យកម្តៅអ្នកធ្វើដំណើរចេញពីខេត្តកោះកុង សរុបចំនួន១៣.៤១៩នាក់ ស្រី៦.១១០នាក់
- បានពិនិត្យកម្តៅអ្នកធ្វើដំណើរចូលខេត្តកោះកុង សរុបចំនួន១៣.៦០៥នាក់ ស្រី៥.៦៦០នាក់
- បានពិនិត្យកម្តៅពលករខ្មែរចូលខេត្តកោះកុង សរុបចំនួន៣៨២នាក់ ស្រី១៨៩នាក់
- បានពិនិត្យកម្តៅពលករខ្មែរចេញពីខេត្តកោះកុង សរុបចំនួន៣៤៥នាក់ ស្រី១៥៦នាក់
- បានពិនិត្យអ្នកជំងឺចូលខេត្តកោះកុង សរុបចំនួន១នាក់ភេទប្រុស
- បានពិនិត្យអ្នកជំងឺចេញពីខេត្តកោះកុង សរុបចំនួន២នាក់ភេទប្រុស។

## ១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

- ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ឯកឧត្តម លោកជំទាវ អនុប្រធាន និងសមាជិក បានអញ្ជើញចូលរួម៖
  - ពិធីសំណេះសំណាល និងប្រគល់រង្វាន់ជូនសិស្សានុសិស្សខេត្តកោះកុង ដែលទទួលបាននិទ្ទេសA ក្នុងលទ្ធផលប្រឡងមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ៨ តុលា ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
  - អមដំណើរសម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រួតពិនិត្យសមិទ្ធផលស្តូបនយោបាយឈ្នះឈ្នះខេត្តកោះកុង។

## ១.១៣-ការងារផ្សេងៗ

- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅតាមបណ្តាក្រុង ស្រុក ឆ្នាំ២០២៤ ដោយមានប្រជាពលរដ្ឋទាំង៧ក្រុង ស្រុកចូលរួមចំនួន១.៧២៣នាក់ ស្រី៥៤០នាក់។ ជាលទ្ធផល ទទួលបានសំណើ និងសំណូមពរនានាពីប្រជាពលរដ្ឋចំនួន១០៨ ក្នុងនោះ ផ្ទាល់មាត់ចំនួន១០១ និងតាមរយៈការសរសេរចំនួន៧។
- បានរៀបចំពិធីបិទស្ទឹងដើម្បីសាងសង់ទំនប់វារីអគ្គិសនីស្ទឹងថ្មកំបុត និងស្ទឹងឫស្សីជ្រុំកណ្តាល អានុភាព១៧០ មេហ្គាវ៉ាត់ ផ្គួបគ្នានៅខេត្តកោះកុង ស្ថិតនៅផ្លូវជាតិលេខ១០ ក្នុងភូមិសាស្ត្រស្រុកមណ្ឌលសីមា ចម្ងាយ៣៣គ.ម ពីក្រុងខេមរភូមិន្ទ ក្រោមអធិបតីភាព ឯកឧត្តម កែវ រតនៈ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។

# ផ្នែកទី២៖-សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ

## ២.១-ផ្នែកសេដ្ឋកិច្ច

### ២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### ក. ការងារកសិកម្ម

- ចលនាដឹកនាំសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន៣.៤៩៥ក្បាល និង ២០០គ.ក្រ ក្នុងនោះ៖
  - ជ្រូករស់នាំចេញ ចំនួន១៥០ក្បាល
  - ជ្រូកសាច់នាំចូល ចំនួន៦៩៥ក្បាល
  - មាន់រស់នាំចូល ចំនួន២.៦៥០ក្បាល
  - សាច់គ្រួចនាំចូល ចំនួន១០០គ.ក្រ
  - ប្រហិតនាំចូល ចំនួន១០០គ.ក្រ។
- ចាក់ថ្នាំការពារសត្វសរុបបានចំនួន៦.៣៥២ក្បាល ក្នុងនោះ៖
  - គោ ចំនួន២.៨២៤ក្បាល (ជំងឺ ២មុខ)
  - ក្របី ចំនួន១.៣៣៤ក្បាល (ជំងឺ ២មុខ)
  - ពពែ ចំនួន៣៩ក្បាល (សាទឹក)
  - ជ្រូក ចំនួន៣៧៤ក្បាល (ជំងឺ ២មុខ)
  - ឆ្កែ ចំនួន១៤ក្បាល (ជំងឺ ៦មុខ)
  - ឆ្មា ចំនួន៧ក្បាល (ជំងឺ ៤មុខ)
  - សត្វស្លាប ចំនួន១.៧៦០ក្បាល(ជំងឺ ៣មុខ)។

- ព្យាបាលសត្វសរុបបានចំនួន៤៩២ក្បាល ក្នុងនោះ៖
  - គោ ចំនួន១៤១ក្បាល
  - ក្របី ចំនួន៦០ក្បាល
  - ជ្រូក ចំនួន២៨ក្បាល
  - ឆ្កែ ចំនួន៣០ក្បាល
  - សត្វស្លាប ចំនួន២៣៣ក្បាល។
- សត្វងាប់ដោយជំងឺសរុបមានចំនួន២៧៩ក្បាល ក្នុងនោះ៖
  - គោ ចំនួន១ក្បាល
  - ជ្រូក ចំនួន៦ក្បាល
  - ឆ្កែ ចំនួន៨ក្បាល
  - សត្វស្លាប ចំនួន២៦៤ក្បាល។
- ស្ថិតិពិឃាដសត្វសរុបមានចំនួន៥.១០៧ក្បាល ក្នុងនោះ៖
  - គោ ចំនួន១០៩ក្បាល
  - ក្របី ចំនួន៥៥ក្បាល
  - ជ្រូក ចំនួន៩០៤ក្បាល
  - មាន់ ចំនួន៣.៦៨៩ក្បាល
  - ទា ចំនួន៣៥០ក្បាល។
- ការងារច្រូតកាត់ប្រមូលផលស្រូវ អនុវត្តបានសរុបចំនួន៥.៣៣៥ហ.ត
  - ស្រូវកណ្តាល ចំនួន៣.៣៨៦ហ.ត
  - ស្រូវធ្ងន់ ចំនួន១.៩៤៩ហ.ត
- ចលនាដឹកនាំសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន៣.០៥០៥ក្បាល និង២៤០គ.ក្រ ក្នុងនោះ៖
  - ជ្រូករស់នាំចេញ ចំនួន១៥០ក្បាល
  - ជ្រូកសាច់នាំចូល ចំនួន៧០០ក្បាល
  - មាន់រស់នាំចូល ចំនួន២.៦៥៥ក្បាល
  - សាច់គ្រួចនាំចូល ចំនួន១១៥គ.ក្រ
  - ប្រហិតនាំចូល ចំនួន១២៥គ.ក្រ។
- ចាក់ថ្នាំការពារសត្វសរុបបានចំនួន៣.១៧១ក្បាល ក្នុងនោះ៖
  - គោ ចំនួន១៥ក្បាល (សាទឹក)
  - ជ្រូក ចំនួន១.១៣៥ក្បាល (ជំងឺ ៦មុខ)
  - ឆ្កែ ចំនួន៨ក្បាល (ជំងឺ ៦មុខ)
  - ឆ្មា ចំនួន៧ក្បាល (ជំងឺ ៤មុខ)
  - សត្វស្លាប ចំនួន២.០០៦ក្បាល (ជំងឺ ៣មុខ)។
- ព្យាបាលសត្វសរុបបានចំនួន៤១៥ក្បាល ក្នុងនោះ៖
  - គោ ចំនួន១៣ក្បាល
  - ក្របី ចំនួន១២ក្បាល
  - ជ្រូក ចំនួន២១១ក្បាល
  - ឆ្កែ ចំនួន២៦ក្បាល
  - សត្វស្លាប ចំនួន១៥៣ក្បាល។
- សត្វងាប់ដោយជំងឺសរុបមានចំនួន៣២៧ក្បាល ក្នុងនោះ៖
  - គោ ចំនួន១ក្បាល

- ជ្រូក ចំនួន៣៧ក្បាល
- ឆ្កែ ចំនួន៧ក្បាល
- សត្វស្លាប ចំនួន២៨២ក្បាល។

– ស្ថិតិពិឃាដសត្វសរុបមានចំនួន៤.៩៩៥ក្បាល ក្នុងនោះ៖
  - គោ ចំនួន១២២ក្បាល
  - ក្របី ចំនួន៤១ក្បាល
  - ជ្រូក ចំនួន៩៣២ក្បាល
  - មាន់ ចំនួន៣.៥៥៨ក្បាល
  - ទា ចំនួន៣៤២ក្បាល។
– ការងារច្រូតកាត់ប្រមូលផលស្រូវ អនុវត្តបានសរុបចំនួន៤.៧១៥ហ.ត បរិមាណលផលសរុប១២.៥៩៦,៨៩តោន និងទិន្នផលមធ្យម២.៦៧២តោន/ហ.ត ក្នុងនោះ៖
  - ស្រូវកណ្តាលចំនួន៤.១២៦ហ.ត (បរិមាណលផលសរុប១០.៩៤០,៥៥តោន, ទិន្នផលមធ្យម២.៦៥២ តោន/ហ.ត)
  - ស្រូវចម្ការចំនួន៥៨៩ហ.ត (បរិមាណលផលសរុប១.៦៥៦,៣៥តោន, ទិន្នផលមធ្យម២.៨១២តោន/ហ.ត)។
– ដំណាំបន្លែអនុវត្តបានសរុបចំនួ១០ហ.ត។
– ដំណាំឈើហូបផ្លែអនុវត្តបានសរុបចំនួន៨ហ.ត។
– ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៨ហ.ត។
– បរិមាណកសិផលនាំចេញ និងប្រើប្រាស់ក្នុងខេត្តសរុបបានចំនួន៤៦៤តោន និងផ្លែដូងចំនួន១.៦០០ផ្លែ។
– ចុះណែនាំពីការប្រើប្រាស់វ៉ាក់សាំងការពារជំងឺឆ្លងសត្វគោ/ក្របី ចំនួន១លើក នៅឃុំជីផាត ស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន២១នាក់ ស្រី៩នាក់។
– ចុះផ្សព្វផ្សាយអំពីការការពារ និងព្យាបាលជំងឺអុតក្តាម ចំនួន១លើក នៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ មានអ្នកចូលរួមសរុបចំនួន២០នាក់ ស្រី៤នាក់។

**ខ.ការងារខណ្ឌរដ្ឋបាលជលផល**

– ចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែនសមត្ថកិច្ចចំនួន៥លើក ជួបប្រទះបទល្មើស៤ករណី ក្នុងនោះ៖
  - ដកហូតលបប្រើស១០០ ចំនួន៨០ខ្សែ ស្មើនឹងប្រវែង៦៤០ម៉ែត្រ ចំនួន២ករណី
  - ឃាត់ចាប់ទូកយន្តចំនួន២គ្រឿង ដកហូតដងឈិបយន្តចំនួន២គូ ស្មើនឹង៤ដង សាច់អួនចំនួន២ចូរ ចំនួន២ករណី។
– ផលនេសាទទឹកសាបអនុវត្តបានចំនួន៥តោន។
– ផលនេសាទសមុទ្រអនុវត្តបានចំនួន៤.៣១០តោន (សិប្បកម្មចំនួន៣.៩៧៤តោន)។
– ការកែច្នៃផលិតផលជលផលអនុវត្តបានចំនួន១៧០តោន និងផលិតទឹកត្រីអនុវត្តបាន៣.០០០លីត្រ។
– ផលវារីវប្បកម្មអនុវត្តបានចំនួន៣១០តោន។
– ការចរាចរផលនេសាទនាំចេញទៅតាមបណ្តារាជធានី/ខេត្តសរុបចំនួន២.៧១០តោន(ផលកែច្នៃចំនួន១៦០តោន)។
– បានទទួលអណ្តើកល្មិច ចំនួន១ក្បាល ទម្ងន់៦,៥០គីឡូក្រាម ពីលោក **ម៉ៅ វណ្ណា** អាយុ៣២ឆ្នាំ ប្រជានេសាទរស់នៅភូមិស្រែថ្មី ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង និងបានធ្វើការលែងចូលក្នុងសមុទ្រវិញ។

**គ. ការងារខណ្ឌរដ្ឋបាលព្រៃឈើ**

– បានសហការជាមួយក្រុមការងាររដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះជំរុញតាមដានត្រួតពិនិត្យការអនុវត្តការងារប្រមូលផលឈើ និងដាំឈើជាចម្ការឡើងវិញរបស់ក្រុមហ៊ុន HMM Internalional Co,.Ltd នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើជីផាត ឃុំជីផាត ស្រុកថ្មបាំង។ ក្រុមហ៊ុនបានធ្វើការកាប់ប្រមូលផលឈើអាកាស្យា លើផ្ទៃដីចំនួន១៣៦ហិកតា បានដាំឈើជាចម្ការឡើងវិញចំនួន៨ហិកតា ផ្សាំកូនឈើសម្រាប់ដាំបានចំនួន១០០.០០០ដើម និងបានធ្វើការឈូសឆាយសម្អាតដីសម្រាប់ត្រៀមដាំឈើបានចំនួន៣០ហិកតា។

- បានសហការជាមួយក្រុមការងាររដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះពិនិត្យសិក្សា និងវាយតម្លៃប្រភពឈើអាកាស្យា ស្ថិតនៅតំបន់ចម្ការឈើអាកាស្យារបស់រដ្ឋ ដែលជាប្រភពផ្គត់ផ្គង់ឈើអាកាស្យាពីខេត្តកោះកុង ទៅកាន់រោងចក្រចិញ្ច្រាំឈើ (Wood chip) ដើម្បីកែច្នៃឈើដាំ និងផលិតជាគ្រឿងសង្ហារឹមរបស់ក្រុមហ៊ុន ធី.ខេ.ផាវ៉ាត្រេឌីង ឯ.ក ក្នុងភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត។ លទ្ធផលសិក្សាបង្ហាញថា ចម្ការឈើដាំនេះមានទំហំ៤០០ហិកតា មានមាឌឈើ សរុបចំនួន៤០.៩៥៧ម៣៦០០ ឬស្មើនឹង៦១.៤៣៦.៤០០ស្ទែរ គិតជាមធ្យមមានមាឌឈើចំនួន១០២ម៣ ៣៩៤ ឬស្មើនឹង១៥៣.៥៩១ស្ទែរ ។
- បានសហការជាមួយក្រុមការងាររដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះពិនិត្យសិក្សាធនធានឈើដាំប្រេងខ្យល់របស់ឈ្មោះ យ៉ន សុខហេង លើផ្ទៃដីទំហំ២១៥,៩៣៨ហិកតា នៅភូមិជ្រោយស្វាយលិច ឃុំជ្រោយស្វាយ ស្រុកស្រែ-អំបិល។ ក្រុមការងារបានធ្វើសារពើភ័ណ្ឌដោយវាស់អង្កត់ផ្ចិត វាស់កម្ពស់ឈើ រាប់ដើមប្រេងខ្យល់ក្នុងឡូត៍គំរូ និងបានធ្វើការគណនាមាឌឈើ សរុបចំនួន១៨៤៦៨ម៣០៩៧ ឬស្មើនឹង២៧៦៨៨.២១៨ស្ទែរ គិតជាមធ្យមមានមាឌឈើ ចំនួន៨៥ម៣៥២៥ ឬស្មើនឹង១២៨.២២៣ស្ទែរ។
- បានសហការជាមួយក្រុមការងារដីរដ្ឋថ្នាក់ខេត្ត ចុះពិនិត្យទីតាំងដីស្នើសុំចុះបញ្ជីសម្គាល់ម្ចាស់អចលនវត្ថុ មានផ្ទៃដីទំហំ៦១២០០ម២ របស់ឈ្មោះ ម៉ុក ស៊ីនួន ស្ថិតនៅភូមិកោះកុងក្នុង ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង។ លទ្ធផលពិនិត្យឃើញថា ទីតាំងដីនេះជាន់លើដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហ្វ្រីន វិច គ្រុប ទំហំ២៨ ២១៨ម២ ដែលគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមួយផ្នែកទៀត ទំហំ៣២៩៨២ម២ ស្ថិតក្នុងតំបន់ការពារធម្មជាតិ គ្រប់គ្រងដោយក្រសួងបរិស្ថាន។ ក្រុមការងារបានរៀបចំឯកសារ ពាក់ព័ន្ធដាក់ជូនសមត្ថកិច្ចថ្នាក់លើ ដើម្បីអនុវត្តនីតិវិធីបន្ត។
- បានចុះត្រួតពិនិត្យ និងវាយតម្លៃ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឡចំហុយដើមចន្ទន៍ក្រស្នាចំនួន២កន្លែង របស់ឈ្មោះ ទ្រិស អ៊ូស្មាន់ ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ និងឈ្មោះ សុធី សុវិទ្យា ស្ថិតនៅភូមិអន្ទង់ឆ្មើត ឃុំដីឥក្រោម ស្រុកស្រែអំបិល។ មន្ទីរបានចេញលិខិតអនុញ្ញាតឱ្យបន្តសុពលភាពអាជីវកម្ម សម្រាប់ឆ្នាំ២០២៥។
- បានសហការជាមួយអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AfoCO) ចុះធ្វើផ្លូវការពារភ្លើងព្រៃ ក្នុងសហគមន៍ព្រៃឈើសាមគ្គីព្រែកជីក ស្ថិតភូមិឈូក ឃុំដីឥលើ ស្រុកស្រែអំបិល មានអ្នកចូលរួមសរុប ចំនួន៣១នាក់ ស្រី១៦នាក់។ ក្រុមការងារបានធ្វើផ្លូវការពារភ្លើងព្រៃប្រវែង១០០០ម៉ែត្រ ដោយបានធ្វើការសម្អាតស្មៅ និងវល្លិ៍លើដីចម្ការឈើចន្ទន៍ក្រស្នាទំហំ៧,៥០ហិកតា។
- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុនវារីអគ្គិសនីស្ទឹងមេទឹកចំនួន១ច្បាប់ លេខ០១០ ផរព.លដជ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ នូវឈើអារប្រភេទលេខ២ ចំនួន៤៨៧សន្លឹក ស្មើនឹង១៤ម៣ ០៧៩ ចេញពីរោងម៉ាស៊ីនអារកែច្នៃឈើបណ្តោះអាសន្ន ក្នុងតំបន់បាតអាងវារីអគ្គិសនីស្ទឹងមេទឹក ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ឆ្ពោះទៅគោលដៅប្រើប្រាស់ភូមិស្ថានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវរាជធានីភ្នំពេញ។

## ២.១.២-ការងារធនធានទឹក និងឧតុនិយម

- បានចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លង ស្ថិតនៅភូមិខ្លង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ។
- បានប្រមូលទិន្នន័យឧតុនិយមនៅតាមបណ្តាស្រុក ដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម។
- បានជួសជុលទំនប់ការពារទឹកប្រៃជ្រោយស្វាយ ប្រវែង៤,១៣គ.ម ស្ថិតឃុំជ្រោយស្វាយ ស្រុកស្រែអំបិល សម្រេចបាន១០០%។

## ២.១.៣-ការងារអភិវឌ្ឍជនបទ

- បានសហការជាមួយក្រុមការងារអន្តរក្រសួង រួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖
    - ចុះត្រួតពិនិត្យ វាយតម្លៃគម្រោងផ្លូវអន្តរាគមន៍ជួសជុលបន្ទាន់ជំហាន២ ចំនួន២ខ្សែប្រវែង៣គ.ម ទទឹង៤ម ស្ថិតនៅភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា លទ្ធផលសម្រេចបាន១០០%
    - ចុះត្រួតពិនិត្យ វាយតម្លៃគម្រោងផ្លូវថៃទាំខួប ១ខ្សែប្រវែង៧.៤គ.ម ទទឹង៦ម និងសាងសង់លូកាត់ផ្លូវ ចំនួន៥កន្លែង ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា លទ្ធផលសម្រេចបាន១០០%។
- បានសហការជាមួយក្រសួអភិវឌ្ឍន៍ជនបទ និងទីប្រឹក្សាគម្រោង ចុះប្រជុំផ្សព្វផ្សាយអប់រំអនាម័យ និងជ្រើសរើស ជនបង្គោលថ្នាក់ភូមិ ឃុំរបស់គម្រោងNRRPCP Batch2 នៅតាមភូមិ ឃុំគោលដៅ ស្ថិតក្នុងឃុំតានូន ស្រុកបូទុមសាគរ។
- បានចុះពិនិត្យគម្រោងសាងសង់ប្រព័ន្ធចែកចាយទឹក តាមបណ្តាញបំពង់ទុយោខ្នាតតូចសហគមន៍ នៅភូមិថ្មី ឃុំជ្រោយប្រស់ ស្រុកកោះកុង សម្រេចបាន១០០% សម្រាប់ថវិកាឆ្នាំ២០២៤។
- បានចូលរួមប្រគល់លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច(ជង)ចំនួន២ភូមិ គឺភូមិជំនាប់ ឃុំជំនាប់ និងភូមិប្រឡាយ ឃុំប្រឡាយ ស្រុកថ្មបាំង។

## ២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈ នៅស្រុកស្រែអំបិល និងស្រុកកោះកុង ចំនួន២មូលដ្ឋាន មាន ដៃបាញ់ប្រេងសរុបចំនួន១២ដៃ។ ជាលទ្ធផល ដៃបាញ់ប្រេងទាំងអស់អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលអាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបាន។
- បានចេញវិញ្ញាបនបត្រផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មពីឈ្មោះ សុខ ហុង មកឈ្មោះ សុខ ឈាងហេង របស់រោងចក្រ ធុនតូចផលិតទឹកកកដើម សុខ ហុង ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង។
- បានយកសំណាកផលិតផលទៅវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ ចំនួន៩មូលដ្ឋាន ស្មើនឹង១០ប៉ាន់គំរូ។ ជាលទ្ធផលអនុលោមតាមគុណភាពស្តង់ដាដែលបានកំណត់។

## ២.១.៥-ការងាររ៉ែ និងថាមពល

- បានចុះពិនិត្យ និងបោះពោងការពារព្រំប្រទល់នៅតាមការដ្ឋានធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់) នៅដងព្រែក ត្រពាំងរូង ស្រុកកោះកុង និងព្រែកស្រែអំបិល ស្រុកស្រែអំបិល ចំនួន២លើក ជាលទ្ធផល អនុវត្តស្របតាមយាមកា ដែលបានចែងក្នុងអាជ្ញាបណ្ណ។
- លទ្ធផលនៃការប្រមូលចំណូលមានដូចខាងក្រោម ៖
    - សួយសារផលិតផលរ៉ែចំនួន ១៤.៤៥៦,៤០$
    - ប្រាក់ពិន័យអន្តរការណ៍ចំនួន ១.០៨៤,១៦$
    - មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍មូលដ្ឋានចំនួន ២.៧២៥,១០$
    - មូលនិធិរ៉ែសម្រាប់ការគ្រប់គ្រងកសាងសមត្ថភាពចំនួន ១.៣១៦,០២$។
- បានទទួលពាក្យស្នើសុំបន្តធ្វើអាជីវកម្មបូមខ្សាច់ ចំនួន៤ទីតាំង៖
    - លោកស្រី ង៉ូវ មុំ មានទីតាំងនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
    - លោក ប៉ាង សុខ មានទីតាំងនៅភូមិ គគីរជ្រុំ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង
    - លោក កក់ សុងសេង មានទីតាំងនៅភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល
    - លោកស្រី សុខា សុខណា មានទីតាំងនៅភូមិស្ពានក្តារ ឃុំតាទៃលើ ស្រុកថ្មបាំង។
- បានចូលរួមសហការជាមួយក្រុមការងារស្នាក់ការអគ្គិសនីកោះកុង ក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប ចុះពិនិត្យខ្សែ បណ្តាញអគ្គិសនី ស្ថិតនៅភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ដើម្បីកែលម្អរសោភ័ណ្ឌភាព និងរបៀបរៀបរយ ចំនួន១លើក។

- បានបន្តចុះត្រួតពិនិត្យ ណែនាំ និងផ្សព្វផ្សាយថ្លៃប្រេងឥន្ធនៈលក់រាយដល់អាជីវករស្ថានីយប្រេងទាំងអស់ក្នុងខេត្ត ឱ្យលក់តាមសេចក្តីជូនដំណឹង របស់ក្រសួងពាណិជ្ជកម្ម ជាលទ្ធផលបានអនុវត្តតាមការណែនាំ។
- បន្តចុះពិនិត្យ និងណែនាំដល់ម្ចាស់ស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ ក្នុងកិច្ចការពារហានិភ័យផ្សេងៗដែលកើតឡើងដោយថាហេតុ នៅក្រុងខេមរភូមិន្ទចំនួន៣លើក ជាលទ្ធផលម្ចាស់ស្ថានីយបានអនុវត្តតាមការណែនាំ។

## ២.១.៦-ការងារពាណិជ្ជកម្ម

- បានបំពេញប្រតិវេទន៍ប្រចាំឆ្នាំចំនួន១ក្រុមហ៊ុន ដល់ក្រុមហ៊ុន ស៊ូន នឹង អ៊ីមផត អិចផត អាសយដ្ឋានទីស្នាក់ការ ចុះបញ្ជីនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។
- បានចុះចែកសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈចំនួន៣លើក តាមស្ថានីយ និងដេប៉ូលក់រាយប្រេងឥន្ធនៈ សរុបចំនួន៣៣ស្ថានីយ/ដេប៉ូ ក្នុងនោះមាន ៖
  - ក្រុងខេមរភូមិន្ទ ចំនួន៤ស្ថានីយ និង៧ដេប៉ូ
  - ស្រុកមណ្ឌលសីមា ចំនួន៣ដេប៉ូ
  - ស្រុកកោះកុង ចំនួន១ស្ថានីយ
  - ស្រុកបូទុមសាគរ ចំនួន៥ដេប៉ូ
  - ស្រុកថ្មបាំង ចំនួន២ដេប៉ូ
  - ស្រុកគិរីសាគរ ចំនួន១ដេប៉ូ
  - ស្រុកស្រែអំបិល ចំនួន២ស្ថានីយ និង៨ដេប៉ូ។
- បានចុះតាមដានតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូលក់ប្រេងឥន្ធនៈរៀងរាល់ថ្ងៃ ក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា។ ជាលទ្ធផល បានពិនិត្យឃើញថា ម្ចាស់ស្ថានីយ/ដេប៉ូ ពុំបានលក់លើសពីតម្លៃដែលក្រសួងបានកំណត់ឡើយ។
- បានចូលរួមព្រឹត្តិការណ៍ការកសាងសមត្ថភាព និងសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ នៃច្រករបៀងសេដ្ឋកិច្ចភាគខាងកើត ខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៏។
- បានចុះពិនិត្យសិប្បកម្មកែច្នៃ វង្ស តារា ដើម្បីពិនិត្យលើលទ្ធផលភោគផលសមុទ្រ សម្រាប់ត្រៀមយកទៅចូលរួមក្នុងការតាំងពិព័រណ៍ នៅបុណ្យសមុទ្រខេត្តកំពត និងពិព័រណ៍ពាណិជ្ជកម្មកម្ពុជានៅរាជធានីភ្នំពេញ។
- បានចុះសាកសួរ និងស្រង់ទិន្នន័យព័ត៌មានក្តាមថ្ម ដើម្បីត្រៀមចុះបញ្ជីជាទំនិញសម្គាល់ភូមិសាស្ត្រ ជាមួយប្រធានអនុប្រធានសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប អាជ្ញាធរឃុំ និងអ្នកទិញ-លក់ក្តាមថ្ម នៅសាលាឃុំពាមក្រសោប ស្រុកមណ្ឌលសីមា។
- បានចូលរួមកម្មវិធីពិព័រណ៍ផ្សេងៗសរុបចំនួន៣លើក។

## ២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

### ២.១.៧.១-ការងារហិរញ្ញវត្ថុ

- ចំណូលថវិកាពីមន្ទីរជំនាញ មានចំនួន៨៨.៨៤២.៣៩២រៀល
- ចំណាយថវិការបស់មន្ទីរជំនាញ មានចំនួន៤.០៦៤.៨៨៥.៤០៣រៀល
- ចំណូលមិនមែនសារពើពន្ធ មានចំនួន៦២.៧៤០.000រៀល
- ចំណូលថវិការបស់ក្រុង ស្រុក មានចំនួន៦.៥៤៩.២០២.៥០០រៀល
- ចំណាយថវិការបស់ក្រុង ស្រុក មានចំនួន៩.៦១៩.៨៨៩.៦៨៤រៀល
- បានពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈជាប្រចាំ
- បានរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាប្រចាំ។

### ២.១.៧.២-ការងារពន្ធដារ

- បានប្រមូលចំណូលពន្ធដើម្បីបែងចែកចូលថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ២.២៧១.១៩៥.០៧៣រៀល ស្មើនឹង១៦.២៩%នៃផែនការឆ្នាំក្នុងនោះ ៖
    - ចំណូលបង់ចូលថវិកាថ្នាក់ជាតិមានចំនួន១.០៩៨.៦១៣.៧៨៤រៀល ស្មើនឹង២២,២១%នៃផែនការឆ្នាំ
    - ចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិមានចំនួន១.១៧២.៥៨១.២៨៩រៀល ស្មើនឹង១៣,០៤%នៃផែនការឆ្នាំ។

### ២.១.៧.៣-ការងារគយ និងរដ្ឋាករ

- ប្រមូលចំណូលសរុបបានចំនួន១៧.៤៧១.៥២៨.៧០០រៀល ស្មើនឹង១២៣,៩១% នៃផែនការប្រចាំខែ ប្រៀបធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២៤ ចំនួន១៣.៧៦១.៣១២.៥០០រៀល កើនឡើង២៦,៩៦% និងបើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០២៣ ប្រមូលបាន១៥.៣៣៧.៩៩០.៧០០រៀល កើនឡើង១៣,៩១%។
- បានចុះបង្ក្រាបបទល្មើសប្រចាំខែធ្នូ ដូចខាងក្រោម ៖
    - ទោចក្រយានយន្តចំនួន១.២៨៦គ្រឿង
    - រថយន្តចង្កូតស្តាំចំនួន១គ្រឿង
    - រថយន្តចង្កូតឆ្វេងចំនួន១គ្រឿង
- បានពង្រឹងការគ្រប់គ្រងឯកសារប្រតិវេទន៍គយ គ្រប់គ្រងការបិទតែមគយ និងត្រួតពិនិត្យទំនិញបានហ្មត់ចត់។
- បានពង្រឹងការធ្វើប្រតិវេទន៍គយឱ្យបានសុក្រឹតតាមការណែនាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

## ២.១.៨-ការងារទេសចរណ៍

- បានផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តតាមរយៈសៀវភៅផ្នត់ គេហទំព័រ Mobile App (Visit Cambodia) និងហ្វេសប៊ុក ដល់ភ្ញៀវទេសចរ។
- បានចុះស្រង់ទិន្នន័យស្ថិតិភ្ញៀវទេសចរមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣៖
    - ភ្ញៀវទេសចរជាតិស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៣៧.៥៥៦នាក់ ថយចុះ ១២.៥៣៨នាក់ ស្មើនឹង-២៥ %
    - ភ្ញៀវទេសចរបរទេសស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៤.៨២១នាក់ កើនឡើង ៣.៩៤៨នាក់ ស្មើនឹង៤៥២%
    - ➢ សរុបភ្ញៀវទេសចរជាតិ និងបរទេសចំនួន៤២.៣៧៧នាក់ ថយចុះចំនួន៨.៥៩០នាក់ ស្មើនឹង-១៦%។
- ភ្ញៀវទេសចរមកកម្សាន្តតាមសហគមន៍៖
    - ភ្ញៀវទេសចរជាតិ មានចំនួន៩.៨២៥នាក់
    - ភ្ញៀវទេសចរបរទេស មានចំនួន៧៦៣នាក់។
- បានផ្តល់អាជ្ញាប័ណ្ណជូនអាជីវករចំនួន៦០កន្លែង តាមរយៈក្រសួងទេសចរណ៍ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ ស្រុកស្រែអំបិល ស្រុកថ្មបាំង និងស្រុកកោះកុង ដូចខាងក្រោម៖
    - ក្រសួងទេសចរណ៍
        - សណ្ឋាគារ — ចំនួន ២ កន្លែង (បន្ត)
    - អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត
        - ផ្ទះសំណាក់ — ចំនួន ២២ កន្លែង (បន្ត)
        - បៀហ្គាឌិន — ចំនួន ២ កន្លែង (បន្ត)
        - ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ — ចំនួន ២ កន្លែង (បន្ត)
        - សណ្ឋាគារ — ចំនួន ២ កន្លែង (បន្ត)
        - ម៉ាស្សាសុខភាព — ចំនួន ១ កន្លែង (បន្ត)

- ការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ
  - ផ្ទះជួល បន្ទប់ស្នាក់នៅ ចំនួន ៥ កន្លែង (បន្ត៤,ថ្មី១ )
  - ស្តុកឃើរ ចំនួន ១ កន្លែង (ថ្មី )
  - ផ្ទះសំណាក់ ចំនួន ៤ កន្លែង (បន្ត១,ថ្មី៣ )
  - ខារ៉ាអូខេ ចំនួន ៥ កន្លែង (បន្ត២,ថ្មី៣ )
  - ហាងម៉ាស្សា ចំនួន ៩ កន្លែង (បន្ត៥,ថ្មី៤ )
  - ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចំនួន ៤ កន្លែង (បន្ត១,ថ្មី៣ )
- ការិយាល័យច្រកចេញចូលតែមួយស្រុកស្រែអំបិល
  - ផ្ទះសំណាក់ ចំនួន១កន្លែង (បន្ត )

- បានសហការជាមួយមន្ទីរបរិស្ថានខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត រដ្ឋបាលស្រុកស្រែអំបិល រដ្ឋបាលឃុំដងពែង និងរដ្ឋបាលឃុំជ្រោយស្វាយ រៀបចំសិក្ខាសាលាស្តីពីសេចក្តីព្រាងចុងក្រោយ ផែនការអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ឆ្នាំ២០២៥-២០២៩ (សហគមន៍តំបន់ការពារធម្មជាតិភ្នំទំពជាង និងសហគមន៍នេសាទតំបន់ការពារសមុទ្រជ្រោយស្វាយ)។

## ២.១.៩-ការងារផែនការ

- បានប្រមូល និងបញ្ចូលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ នៅផ្សារស្រែអំបិល ស្ថិតក្នុងស្រុកស្រែអំបិល និងផ្សារដងទង់ ស្ថិតក្នុងក្រុងខេមរភូមិន្ទ ប្រចាំខែធ្នូ ឆ្នាំ២០២៤ រួចរាល់។
- បានទទួលតារាងរបាយការណ៍លទ្ធផលនៃការអនុវត្តគម្រោង(តារាង ១.២) ឆ្នាំ២០២៤ តាមបណ្តាឃុំ សង្កាត់ និង ក្រុង ស្រុក ទូទាំងខេត្ត ស្មើនឹង១០០%។
- បានបញ្ចូលនៃការអនុវត្តគម្រោង(តារាង ១.២) ឆ្នាំ២០២៤ ទៅក្នុងប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ (SPD) បានចំនួន២ស្រុក ៧ឃុំ។
- បានទទួលទិន្នន័យភូមិ ឃុំ/សង្កាត់ សម្រាប់ឆ្នាំ២០២៤ បានចំនួន២១ភូមិ ៨ឃុំ និងស្រុក១។
- បានផលិតបណ្ណសមធម៌ចំនួន១.៦៣៥បណ្ណ និងបានផ្តល់ជូនៈ
  - គ្រួសារដែលបានបាត់បណ្ណចំនួន១បណ្ណ
  - គ្រួសារដែលបានប្តូរពីគ្រួសារងាយរងហានិភ័យទៅជាគ្រួសារក្រីក្រចំនួន២៥បណ្ណ
  - គ្រួសារដែលជាប់សម្ភាសន៍ថ្មីចំនួន១.៦០៩បណ្ណ។

## ២.១.១០-ការងារផ្សេងៗ

### ២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- ចំណូលជាប្រាក់រៀលសរុបចំនួន៥.៩៦៤.៤៥៦.៥១៥រៀល បើប្រៀបធៀបទៅនឹងខែមុនថយចុះ៨,៨២%
- ចំណូលជាប្រាក់ដុល្លារសរុបចំនួន៥.១៧៩.៧៦០ដុល្លារ បើប្រៀបធៀបទៅនឹងខែមុនថយចុះ៥៧,៣៣%
- ចំណាយជាប្រាក់រៀលសរុបចំនួន៦.៦០០.៥២៣.៤៦៥រៀល បើប្រៀបធៀបទៅនឹងខែមុនកើនឡើង៣,៥៩%
- ចំណាយជាប្រាក់ដុល្លារចំនួន១.៩០០.០០០ដុល្លារ បើប្រៀបធៀបទៅនឹងខែមុនថយចុះ៦២,៧៥%
- បានប្តូរប្រាក់រៀល ចាស់ រហែក ទក់ សរុបចំនួន៩៣១.៥០០.០០០រៀល
- បានចេញលិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពដើមគ្រាសរុបចំនួន៥២ច្បាប់ និងចុងគ្រាសរុបចំនួន ៥២ច្បាប់។

### ២.១.១០.២-ការងាររតនាគារ

- បានពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS ជូនមន្ត្រីជំនាញជាបន្តបន្ទាប់។
- បានពង្រឹងការអនុវត្តការកត់ត្រាចំណូលចំណាយតាមប្រព័ន្ធ FMIS ជូនមន្ត្រីបានកាន់តែប្រសើរ។
- បានពង្រឹងការអនុវត្តនូវសារាចរណែនាំស្តីពីការអនុវត្តនីតិវិធីបើកផ្តល់ប្រាក់បៀវត្សរាល់២សប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការបានទាន់ពេលវេលា។

- បានពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal)ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានកាន់តែប្រសើរ។
- ចំណូលសរុបមានចំនួន៣៨.៤៤៣លានរៀល ក្នុងនោះ៖
  - ចំណូលពីអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន១៩.៤២២លានរៀល
  - ចំណូលមូលដ្ឋានមានចំនួន១៩.០២១លានរៀល។
- ចំណាយសរុបមានចំនួន៣៤.១៤៧លានរៀល ក្នុងនោះ៖
  - ផ្ទេរទៅអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន១៩.២២៣លានរៀល
  - ចំណាយមូលដ្ឋានមានចំនួន១៤.៩២៤លានរៀល។

### ២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បានចុះត្រួតពិនិត្យទំនិញតាមផ្ទះលក់ដូរ ម៉ាត និងផ្សារ ចំនួន៤លើក។
- បានធ្វើតេស្តបឋមលើបង្ការ មឹក ត្រី សរសៃគុយទាវ និងបន្លែ ចំនួន២៦គំរូ។ ជាលទ្ធផល មានអនុលោមភាពទាំង ២៦គំរូ។
- បានដកហូតទំនិញខូចគុណភាព ហួសកាលបរិច្ឆេទប្រើប្រាស់សរុប១.៩៣គីឡូក្រាម។
- បានចែកផ្ទាំងផ្សព្វផ្សាយស្តីពីសុវត្ថិភាពម្ហូបអាហារចំនួន២២សន្លឹក។
- បានចុះត្រួតពិនិត្យតម្លៃលក់រាយប្រេងឥន្ធនៈតាមបណ្តាស្ថានីយ/ដេប៉ូចំនួន៤លើក សរុបចំនួន១៦ស្ថានីយ/ដេប៉ូ ក្នុងនោះ មាន១៣ទីតាំងលក់ស្មើតម្លៃដូចសេចក្តីជូនដំណឹង និង៣ទីតាំងទៀតលក់ទាបជាងសេចក្តីជូនដំណឹង របស់ក្រសួងពាណិជ្ជកម្ម។

## ២.២-ផ្នែកសង្គមកិច្ច

### ២.២.១-ការងារអប់រំ យុវជន និងកីឡា

- បានសហការជាមួយមន្ទីរមុខងារសាធារណៈ និងរដ្ឋបាលស្រុកពាក់ព័ន្ធ ចុះជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ចំណេះទូទៅសម្រាប់ប្រើប្រាស់ឆ្នាំសិក្សា២០២៤-២០២៥។ ជាលទ្ធផល ក្រុមការងារបានសម្រេចជ្រើសរើសគ្រូកិច្ចសន្យាបានចំនួន២៧នាក់ ស្រី១៦នាក់បន្ថែម សម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានដែលមានតម្រូវការក្របខ័ណ្ឌ។
- បានអនុញ្ញាតឱ្យក្រុមហ៊ុនខេមមីស សូលូសិន បើកកិច្ចប្រជុំផ្សព្វផ្សាយដល់លោកនាយក លោកស្រីនាយិកា និងគ្រូទទួលបន្ទុកICT នៅគ្រប់គ្រឹះស្ថានសិក្សាក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ស្តីពីសារៈប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធខេមមីស នៅមន្ទីរអប់រំ យុវជននិងកីឡាខេត្ត។ ជាលទ្ធផល សមាជិកអង្គប្រជុំបានយល់ដឹងបន្ថែមពីសារប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធសម្រាប់តាមដានលទ្ធផលការសិក្សា ការដាក់ពិន្ទុ ស្រង់វត្តមានប្រចាំថ្ងៃរបស់សិស្ស និងបានផ្តល់ព័ត៌មានពីការសិក្សារបស់សិស្សដល់មាតាបិតា និងអាណាព្យាបាលសិស្សតាមប្រព័ន្ធអនឡាញផងដែរ។
- បានទទួលអំណោយកង់ចំនួន៥៥គ្រឿង តាមរយៈនាយឧត្តមសេនីយ៍ យន្ត មីន ពីមូលនិធិBeijing Ling Fang នៃប្រទេសចិន សម្រាប់បែងចែកដល់សិស្សក្រីក្រចំនួន៥៥នាក់ ដែលកំពុងសិក្សានៅតាមសាលាបឋមសិក្សាចំនួន៦ ក្នុងក្រុងខេមរភូមិន្ទ និងក្នុងស្រុកមណ្ឌលសីមា នៅមន្ទីរអប់រំយុវជន និងកីឡាខេត្ត។
- បានទទួលអំណោយសម្ភារតន្ត្រី មានដូចជា ស្គរផៃយ៉ាំឈុតតូច១ឈុត ស្គរសាំធម្មតា១ឈុត ឈុតភ្លេងកាយរិទ្ធី (ឈុតតូច)១ឈុត អកចុប១ និងព្យានីការ២០គ្រឿង សម្រាប់ចែកជូនដល់សាលាគោលដៅរបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំខេត្តកោះកុងចំនួន៤សាលា ស្ថិតក្នុងក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានចូលរួមសង្កេតការណ៍ នៃការពិនិត្យវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់ខេត្ត ជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់ជាតិ នៅវិទ្យាល័យកោះស្តេច ស្រុកគិរីសាគរ។ ជាលទ្ធផល គណៈកម្មការបានយកលទ្ធផលដើម្បីប្រជុំពិនិត្យវាយតម្លៃបន្តនៅថ្នាក់ជាតិ ក្នុងនោះសម្រាប់ខេត្តកោះកុងបានជាប់ វគ្គជំរុះចំនួន១០សាលា។

- បានប្រជុំផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ ហ៊ុន សែន ត្រពាំងរូង ក្នុងឃុំត្រពាំងរូង ស្រុកកោះកុង។ ជាលទ្ធផល លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទទួលបានចំណេះដឹងបន្ថែមពីផលប៉ះពាល់នៃការជួញដូរមនុស្ស កលល្បិចឆបោករបស់ជនខិលខូច វិធីការពារខ្លួន និងចេះរកដំណោះស្រាយក្នុងពេលជួបករណីនេះ។
- បានបើកកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការរវាងមន្ទីរអប់រំ យុវជននិងកីឡាខេត្ត ជាមួយអង្គការដៃគូ ក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ នៅសាលប្រជុំមន្ទីរអប់រំយុវជន និងកីឡា។ ជាលទ្ធផល អង្គការដៃគូបានបន្សុីសកម្មភាពគម្រោងទៅនឹងសកម្មភាពតាមផ្នែកពាក់ព័ន្ធនៃមន្ទីរអប់រំ យុវជន និងកីឡាសម្រាប់ឆ្នាំ២០២៥ បញ្ចូលក្នុងប្រព័ន្ធផែនការប្រតិបត្តិប្រចាំឆ្នាំ។
- បានចុះពិនិត្យអគារសិក្សាដើម្បីស្នើសុំជួសជុល និងសាងសង់ក្នុងស្រុកគិរីសាគរ និងក្រុងខេមរភូមិន្ទ។ ជាលទ្ធផល អគារសិក្សាដែលមានសភាពចាស់ទ្រុឌទ្រោមមានចំនួន៣ខ្នង ក្នុងនោះ មាននៅសាលាបឋមសិក្សាកោះស្តេចចំនួន១ខ្នងស្មើនឹង៥បន្ទប់ សាលាបឋមសិក្សាសម្តេចជាសុីមចំនួន១ខ្នងស្មើនឹង៦បន្ទប់ និងសាលាបឋមសិក្សាស្មាច់មានជ័យចំនួន១ខ្នងស្មើនឹង៦បន្ទប់។ ក្រុមការងារបានណែនាំឱ្យសាលារៀបចំសំណើជួសជុលសាលាគោរពជូន ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា។
- បានចុះពិនិត្យការអនុវត្តកម្មវិធីសុខភាពសិក្សាវឌ្ឍនភាពការសាងសង់បង្គន់អនាម័យ) នៅសាលាបឋមសិក្សាទឹកល្អក់ និងសាលាឧបសម្ព័ន្ធអូរកី ក្នុងស្រុកថ្មបាំង។ ជាលទ្ធផល សាលាបានសាងសង់រួចរាល់៩០% និងបានណែនាំដល់លោកនាយកពីការរៀបចំសួនផ្កាសម្រាប់លម្អខាងមុខបន្ទប់ទឹក ឬបង្គន់អនាម័យ បំពាក់ស្លាកសម្គាល់ (បន្ទប់បុរស និងស្ត្រី)។
- បានចុះពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន(SCS)របស់គម្រោងកែលម្អការអប់រំចំណេះទូទៅ(GEIP)នៅតាមសាលាបឋមសិក្សាគោលដៅ ក្នុងស្រុកកោះកុង ក្រុងខេមរភូមិន្ទ ស្រុកបូទុម-សាគរ និងស្រុកថ្មបាំង។ ជាលទ្ធផល សាលារៀនគោលដៅ បានធ្វើតេស្តចុងឆ្នាំ និងតេស្តដើមឆ្នាំសម្រាប់ថ្នាក់ទី១ ដើម្បីរៀបចំធ្វើផែនការរៀនសូត្រសិស្សម្នាក់ៗ ផែនការបង្រៀនរបស់គ្រូ ផែនការសាលារៀន និងកិច្ចព្រមព្រៀង។
- បានចូលរួមធ្វើបទបង្ហាញការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ជូនប្រតិភូទស្សនកិច្ចសិក្សា មកពីខេត្តកំពត នៅសាលប្រជុំមន្ទីរអប់រំ យុវជននិងកីឡាខេត្តកោះកុង។ ជាលទ្ធផល៖
    - ចែករំលែកបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាននាពេលកន្លងមក
    - បង្ហាញលទ្ធផលវិជ្ជមានតាមសាលារៀនដែលអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន
    - បង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយកន្លងមក។
- បានចុះពិនិត្យតាមដានការបញ្ចូលផែនការសកម្មភាពហានិភ័យទាំង៥ របស់សាលារៀនទៅក្នុងផែនការ ប្រតិបត្តិប្រចាំឆ្នាំ(AOP)របស់សាលារៀន ការសិក្សាតាមបែបស្រាវជ្រាវ និងមេរៀនបញ្ជ្រាប នៅសាលាបឋមសិក្សាជីផាត និងសាលាបឋមសិក្សាតាទៃលើ ស្រុកថ្មបាំង។ ជាលទ្ធផល
    - សកម្មភាពហានិភ័យទាំង៥ មានចំនួន៨ បានបញ្ចូលរួចរាល់ក្នុងផែនការប្រតិបត្តិ
    - គ្រូបានរៀបចំមេរៀន តាមបែបស្រាវជ្រាវសម្រាប់ថ្នាក់ទី៤ មាន២ប្រធានបទ ថ្នាក់ទី៥ មាន៨ប្រធានបទ និងថ្នាក់ទី៦ មាន៤ប្រធានបទ
    - គ្រូថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ បានជ្រើសរើសយកមេរៀនបញ្ជ្រាបតាមមុខវិជ្ជារួចរាល់។
- បានចុះពិនិត្យតាមដានការអនុវត្តផែនការឆ្លើយតបហានិភ័យទាំង៥ ការអនុវត្តការបង្រៀន និងរៀនតាមបែបស្រាវជ្រាវ នៅសាលាបឋមសិក្សាវត្តត្រពាំងរូង ស្រុកកោះកុង សាលាបឋមសិក្សានាពិសី ស្រុកស្រែអំបិល និងសាលាបឋមសិក្សាឫស្សីជ្រុំ ស្រុកថ្មបាំង ជាលទ្ធផល៖
    - សាលារៀនបានអនុវត្តសកម្មភាពដែលបានដាក់បញ្ចូលក្នុងផែនការសាលារៀនរួចរាល់មួយចំនួន
    - រៀបចំផែនការផ្សព្វផ្សាយអំពីកិច្ចការពារកុមារជាប្រចាំ
    - គ្រូទទួលបន្ទុកថ្នាក់ទី៤ ទី៥ និងថ្នាក់ទី៦ បានកំណត់មេរៀនចំនួន៤ ក្នុងមួយកម្រិតថ្នាក់បញ្ចូលក្នុងកាលវិភាគសម្រាប់អនុវត្តកម្មវិធីអប់រំបំណិនជីវិត។

- បានចូលរួមសម្របសម្រួលអង្គប្រជុំ ស្ដីពីការប្រមូលកុមារក្រៅសាលា និងឆ្លុះបញ្ចាំងកិច្ចការសាលារៀន នៅសាលប្រជុំវិទ្យាល័យ ហ៊ុនសែនត្រពាំងរូង ស្រុកកោះកុង។ ជាលទ្ធផល លោកនាយក និងគ្រូបង្រៀនថ្នាក់ទី៤ ដល់ទី៦ ចំនួន២១នាក់ បានចូលរួមកំណត់សមាសភាពកុមារក្រៅសាលារៀន និងធ្វើផែនការជ្រើសរើសប្រធានបទសម្រាប់សិក្សាតាមបែបស្រាវជ្រាវ។
- បានចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន(SCS) របស់គម្រោងកែលម្អការអប់រំចំណេះទូទៅ(GEIP) នៅសាលាបឋមសិក្សាសម្ដេចពិជ័យសេនាទៀបាញ់ថ្មស សាលាបឋមសិក្សាចម្លងគោ សាលាបឋមសិក្សាកណ្ដាល សាលាបឋមសិក្សាតាំកន់ ស្ថិតក្នុងស្រុកបូទុមសាគរ សាលាបឋមសិក្សាជីផាត ស្ថិតក្នុង ស្រុកថ្មបាំង សាលាបឋមសិក្សាភ្នំស្រឡៅ និងសាលាបឋមសិក្សាជ្រោយស្វាយ ស្ថិតក្នុងស្រុកស្រែអំបិល។ ជាលទ្ធផល
  - សាលារៀនបានបញ្ចូលកិច្ចការទាំង៥ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលារៀនបានរួចរាល់
  - សាលាបឋមសិក្សាចំនួន៧ បានធ្វើតេស្តស្តង់ដាម៉ត់ចត់ចុងឆ្នាំ និងការរៀបចំបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀន និងថ្នាក់រៀនបានរួចរាល់
  - ណែនាំពីរបៀបធ្វើផែនការសិក្សាសិស្ស និងកិច្ចព្រមព្រៀងរវាងគ្រូបង្រៀន និងអាណាព្យាបាលសិស្ស ស្ដីពីលទ្ធផលសិក្សាប្រចាំឆ្នាំ។
- បានសហការជាមួយអង្គការគីហ្សូណា ចុះវាយតម្លៃដើមគ្រា ដើម្បីបញ្ចូលគម្រោងគ្រប់គ្រងបណ្ណាល័យ នៅគ្រឹះស្ថានមធ្យមសិក្សា ក្នុងក្រុង/ស្រុកទាំង៧ ជាលទ្ធផល៖
  - អគារ និងបន្ទប់បណ្ណាល័យនៅតាមអនុវិទ្យាល័យមួយចំនួនកំពុងសាងសង់ រៀបចំក្រាលការ៉ូ ដាក់បង្អួចទ្វារ លាបថ្នាំជិតរួចរាល់ និងនៅតាមវិទ្យាល័យ អនុវិទ្យាល័យមួយចំនួនទៀតកំពុងបើកដំណើរការ
  - គ្រូបង្រៀនលោកគ្រូ អ្នកគ្រូទទួលបន្ទុកបណ្ណាល័យ ត្រូវអនុញ្ញាតឱ្យទៅចូលរួមវគ្គបំប៉នសមត្ថភាពនៅដើមខែមករា ឆ្នាំ២០២៥។
- បានដឹកនាំសិស្សនិទ្ទេសA ចំនួន១៣រូប ចូលរួមពិធីសំណេះសំណាលសិស្សនិទ្ទេសA នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ រាជធានីភ្នំពេញ។ ជាលទ្ធផល សិស្សនិទ្ទេសAក្នុង១នាក់ ទទួលបានថវិកាចំនួន២លានរៀល កុំព្យូទ័រយួរដៃ១គ្រឿង នាយកសាលាចំនួន៤នាក់ ក្នុង១នាក់ទទួលបានថវិកាចំនួន១លានរៀល និងសាលាដែលមានសិស្សជាប់និទ្ទេសA ក្នុង១សាលាថវិកាចំនួន៣លានរៀល។
- បានសហកាជាមួយក្រុមការងារនៃវិទ្យាល័យប៉ាក់ខ្លង ចុះបង្វឹកការអនុវត្តកិច្ចការគម្រោងGEIP នៅអនុវិទ្យាល័យជាស៊ីមស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល៖
  - ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលការដាក់ពិន្ទុស្វ័យវាយតម្លៃចុងឆ្នាំ២០២៤
  - ដំណើរការរៀបចំតេស្តដើមឆ្នាំ
  - ដំណើរការរៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់
  - ដំណើរការរៀបចំតេស្តស្តង់ដារប្រចាំខែ។
- បានដឹកនាំក្រុមកីឡាករ កីឡាការិនី ដែលបានបញ្ចប់ការប្រកួតកីឡាថ្នាក់ជាតិលើកទី៤ ឆ្នាំ២០២៤ ទទួលបានមេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធ សរុបចំនួន១៥គ្រឿង ចូលជួបសម្តែងការគួរសមជាមួយលោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្ត នៅសាលាខេត្ត។ ក្នុងឱកាសនោះ លោកជំទាវក៏បានផ្ដល់ថវិកាលើកទឹកចិត្តដល់ក្រុមកីឡាករ និងកីឡាការិនីដែលដណ្ដើមបានមេដាយជាកិត្តិយសជូនខេត្ត
- បានដឹកនាំក្រុមយុវជនចូលរួមប្រកួតផ្ដាច់ព្រ័ត្រកម្មវិធីការស្ម័គ្រចិត្ត ដើម្បីសហគមន៍ខ្ញុំ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ។ ជាលទ្ធផល ក្រុមយុវជនមិនទទួលបានចំណាត់ថ្នាក់ទេ ដោយកម្មវិធីនេះតម្រូវជ្រើសរើសយកតែ២ក្រុម ក្នុងចំណោម២៥រាជធានី/ខេត្ត។

## ២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានសហការជាមួយមន្ទីរកិច្ចការនារីខេត្ត ដើម្បីសម្របសម្រួលផ្តល់ប្រឹក្សាយោបល់ពីការទទួលសេវាផ្លូវច្បាប់តាមនីតិវិធី ដល់គ្រួសារកុមារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈឈ្មោះ អ.ស.ម អាយុ១៤ឆ្នាំ រស់នៅភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ក្នុងនោះរដ្ឋបាលខេត្ត បានឧបត្ថម្ភថវិកាចំនួន៨០០.០០០រៀល និងមន្ទីរបានឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគមួយចំនួន និងអង្ករចំនួន២៥គ.ក្រ។
- បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ និងអធិការក្រុងខេមរភូមិន្ទ ដើម្បីទទួលកុមារាចំនួន២នាក់ ឈ្មោះ ហ.ស.ផ អាយុ៨ឆ្នាំ និងឈ្មោះ ច.រ.ណ អាយុ៤ឆ្នាំ ដែលឪពុកម្តាយរបស់កុមារ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ពីបទប្រើប្រាស់នូវសារជាតុញៀន និងជួញដូរគ្រឿងញៀនដោយខុសច្បាប់។ ក្រុមការងារបានស្វែងរកសេវាបន្តដោយបញ្ជូនកុមារទាំង២ ឱ្យស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋខេត្តកោះកុង ក្នុងនោះមន្ទីរបានឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគមួយចំនួន និងអង្ករចំនួន២៥គ.ក្រ។
- បានចុះតាមដាន និងសួរសុខទុក្ខអនីតិជនទំនាស់នឹងច្បាប់ចំនួន១នាក់ ភេទស្រី អាយុ១៥ឆ្នាំ ជាប់ចោទ ពីបទដឹកជញ្ជូន ឬកាន់កាប់អាវុធដោយគ្មានអនុញ្ញាត បានសមាហរណកម្មទៅរស់នៅជាមួយគ្រួសារវិញ នៅភូមិ១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ បន្ទាប់ពីចុះតាមដានសង្កេតឃើញថាអនីតិជន បានផ្លាស់ប្តូរអាកប្បកិរិយា ចុះជួយការងារ ស្តាប់បង្គាប់ម្តាយ និងរកចំណូលជួយផ្គត់ផ្គង់គ្រួសារ។
- បានជួបជាមួយលោកយាយ នៅ ចន្ទី អាយុ៦៥ឆ្នាំ ដែលជាជនមានពិការភាពក្រីក្រ មានទីលំនៅមិនពិតប្រាកដ និងមានកូនប្រុស១នាក់(ករណីចាស់)។ គាត់បានស្នើសុំរទេះរុញថ្មី១គ្រឿង ហើយក្រុមការងារបាននិងកំពុងរៀបចំលិខិតស្នើសុំរទេះរុញថ្មីពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទាខេត្តកំពង់ស្ពឺ ក្នុងនោះមន្ទីរក៏បានផ្តល់អង្ករចំនួន២៥គ.ក្រ ដើម្បីជួយសម្រួលជីវភាពពួកគាត់។
- ផលបូកបន្តចំនួនគ្រួសារគោលដៅដែលបានចុះឈ្មោះតាមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ (តាំងពីកម្មវិធីចាប់ផ្តើម)សរុបចំនួន៧.៩១៣គ្រួសារ។

ក.ទិន្នន័យអ្នកទទួលផលកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

| ល.រ | ប្រភេទអ្នកទទួលផល | ចំនួនចុះឈ្មោះថ្មីក្នុងខែ | ចំនួនស្រី/កុមារី | ចំនួនការអនុវត្តលក្ខខណ្ឌ | ថវិកាចំណាយ(រៀល) |
|---|---|---|---|---|---|
| ១ | ស្ត្រីមានផ្ទៃពោះ | ២៨ | ០ | ៩២ | ២១.៧៦០.០០០ |
| ២ | កុមារអាយុ ០-២ឆ្នាំ | ៣ | ១ | ២៤០ | ១៩.៤៤០.០០០ |
| ៣ | ជនមានពិការភាព | ៩ | ០ | ០ | ២៥២.០០០ |
| សរុបរួមទឹកប្រាក់ | | | | | ៤១.៤៥២.០០០ |

- ការងារការបើកផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
  - ជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដែលយុវជនបានចុះឈ្មោះចូលរៀនមានដូចខាងក្រោម៖
    - ជំនាញការងារដំឡើងបណ្តាញអគ្គិសនីក្នុងអគារចំនួន១០៩នាក់ ស្រី២០នាក់
    - ជំនាញការងារកំបោរចំនួន៧១នាក់ ស្រី១៤នាក់
    - ជំនាញការងារថែទាំ និងជួសជុលរថយន្តចំនួន៧០នាក់ ស្រី១៨នាក់
    - ជំនាញការងារសេវាកម្មសម្អាងការចំនួន៥១នាក់ ស្រី៤៨នាក់
    - ទិន្នន័យយុវជនបានបញ្ចប់ការសិក្សាចំនួន២៣២នាក់ ស្រី៨៣នាក់។

ខ.ទិន្នន័យយុវជនចុះឈ្មោះចូលរៀនជំនាញវិជ្ជាជីវៈ និងបច្ចេកទេស

| ល.រ | ប្រភេទអ្នកទទួលផល | ទិន្នន័យចុះឈ្មោះថ្មី | ទិន្នន័យផលបូកបន្ត | ចំនួនស្រី |
|---|---|---|---|---|
| ១ | យុវជនក្នុងគ្រួសារមានបណ្ណសមធម៌ | ០០នាក់ | ៣០១នាក់ | ១១៩នាក់ |

| | | | | |
|---|---|---|---|---|
| ២ | យុវជនក្នុងគ្រួសារមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ | ០០នាក់ | ៤០នាក់ | ១៣នាក់ |
| សរុប | | ០០នាក់ | ៣៤១នាក់ | ១៣២នាក់ |

## ២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

### ២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- នៅក្នុងខែធ្នូ ឆ្នាំ២០២៤ នេះ ស្ថិតិសហគ្រាស/គ្រឹះស្ថាន ក្នុងខេត្តសរុបចំនួន៧៤ ដែលមានកម្មករនិយោជិតកំពុងបម្រើការងារសរុបចំនួន១៦.២៥៧នាក់ ស្រី៨.០៦៤នាក់ ក្នុងនោះមាន៖
  - កម្មករនិយោជិតខ្មែរចំនួន១៣.៨៩៥នាក់ ស្រី៧.៥៧២នាក់
  - ពលករបរទេសចំនួន២.៣៦៥នាក់ ស្រី៤៩២នាក់។
- បានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក (ចេញ-ចូល) ចំនួន៥សហគ្រាស/គ្រឹះស្ថាន រួមមាន៖
  - ចលនាចេញ៣២២នាក់ ស្រី១៩៤នាក់
  - ចលនាចូល២៤០នាក់ ស្រី១២៨នាក់។
- បានផ្សះផ្សារវិវាទបុគ្គល១ករណី (បានសះជា)។
- បានចុះសម្របសម្រួលការសុំព្យួរកិច្ចសន្យាការងារ របស់រោងចក្រហាណាម៉ាយក្រូអេឡិចត្រូនិក។
- បានណែនាំអំពីនីតិវិធីក្នុងការព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដល់រោងចក្រយ៉ាហ្សាគី(ខេមបូឌា) ប្រជាក់។
- បានចុះជំរុញតំណាងគណៈកម្មការអេដស៍ និងគ្រឿងញៀននៅតាមបណ្តារោងចក្រសហគ្រាសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង បានចំនួន៥រោងចក្រ រួមមាន៖
  - រោងចក្រខេខេអិន
  - រោងចក្រ ៩៩ អ៊ីមប្រយរើរី
  - រោងចក្រ ហាណា អេឡិចត្រូនិច ខូអិលធីឌី
  - រោងចក្រ យ៉ាហ្សាគិ ខេមបូឌា ប្រជាក់ ខូអិលធីឌី
  - រោងចក្រ ខេមកូ ម៉ូធ័រ ខមភេនី។

### ២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បានចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសេវាសន្តិសុខសង្គមទាំងបួនផ្នែកដូចជា៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំ ផ្នែកសោធន (បង់ភាគទានផ្នែកសោធនស្ម័គ្រចិត្ត) និងស្វ័យនិយោជន៍ មានដូចខាងក្រោម ៖
  - សហគ្រាស/គ្រឹះស្ថាន ដែលបានចុះបញ្ជីផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងស្វ័យនិយោជន៍ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ
  - បានធ្វើបច្ចុប្បន្នភាពសហគ្រាស/គ្រឹះស្ថាន ដែលបានជាប់ភាគទានក្នុងខែធ្នូ ឆ្នាំ២០២៤ មានចំនួន១២០ សហគ្រាស/គ្រឹះស្ថាន សមាជិកសរុបចំនួន១២.៧៥៦នាក់ ស្រី៧.៣៦៧នាក់
  - បានចុះបញ្ជីសមាជិកដែលជាបុគ្គលស្វ័យនិយោជន៍ និងបានបង់ភាគទានចំនួន១.៨៩៤នាក់ ស្រី១.១២២ នាក់ និងសមាជិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន៣៨នាក់ ស្រី១៩នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកហានិភ័យការងារទទួលបានតាវកាលិកចំនួន៥នាក់ ស្រី២នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកថែទាំសុខភាព ទទួលបានតាវកាលិកចំនួន៥២នាក់ ស្រី៤៥នាក់
  - បានសម្របសម្រួលដល់សមាជិកប.ស.ស.ទាំងវិស័យសាធារណៈ និងវិស័យឯកជនជាស្ត្រីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល មុនសម្រាល និងក្រោយសម្រាលកូនចំនួន៦៤០នាក់
  - បានធ្វើប័ណ្ណទុតិយតាវិស័យសាធារណៈមានចំនួន៤នាក់ វិស័យឯកជន៦៩នាក់ ស្រី៨នាក់

- បានចុះបញ្ជិកាសមាជិក ប.ស.ស វិស័យឯកជន(កម្មករ)ចំនួន១២៩នាក់ ស្រី៤១នាក់ បុគ្គលស្វ័យនិយោជន៍២១២នាក់ ស្រី១៣៤នាក់ និងអ្នកក្នុងបន្ទុក១៨នាក់ ស្រី៥នាក់
- បានចុះបញ្ជិកាសមាជិក ប.ស.ស ជាមន្ត្រីសាធារណៈមានចំនួន៨នាក់ និងអ្នកក្នុងបន្ទុក៨៥នាក់ ស្រី៦៦នាក់
- បានបោះពុម្ព និងផ្តល់ជូនបណ្ណសមាជិកប.ស.ស ដល់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់ មេភូមិ អនុភូមិ និងសមាជិកភូមិចំនួន៣នាក់ ស្រី១នាក់។

## ២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- ការតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច វត្ថុជាតិពន្ធ និងអនុផលព្រៃឈើមួយចំនួន នៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្តកោះកុង មានភ្ញៀវចូលទស្សនាចំនួន១១នាក់ ស្រី១នាក់ ។
- ភ្ញៀវចូលទស្សនាស្ថានីយអូរកីចំនួន១០១នាក់ (បរទេសទាំងអស់) និងស្ថានីយភ្នំពែលចំនួន៥នាក់។
- បានចុះសិក្សាស្រាវជ្រាវពិធីបុណ្យពូនភ្នំស្រូវ នៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង។
- បានចូលរួមសម្តែងរបាំជូនពរ នៅក្នុងកម្មវិធីមីទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៦ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (២ ធ្នូ ១៩៧៨ -២ ធ្នូ ២០២៤)។
- បានបង្ហាត់របាំទិវាប្រពៃណីដល់សិស្សថ្មីចំនួន១២នាក់(ស្រី)។
- បានចូលរួមសម្តែងរបាំខ្លារក្តាម នៅក្នុងពិធីបុណ្យសមុទ្រលើកទី១១ ឆ្នាំ២០២៤ នៅខេត្តកំពត។
- បានបង្ហាត់ក្បាច់បាតមូលដ្ឋានគ្រឹះ(របាំក្បាច់បុរាណខ្មែរ) ដល់សិស្សានុសិស្សចំនួន២០នាក់(ស្រី)។

## ២.២.៥-ការងារព័ត៌មាន

- បានពិនិត្យ និងផ្តល់សេវាបើក និងផ្តល់ថ្មី ជូនអតិថិជនដើម្បីផ្សព្វផ្សាយពាណិជ្ជកម្ម តាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន២២សេវា រួមមាន ផ្ទាំងប៉ាណូ១៣សេវា អាហ្វីស៧សេវា និងតាមប្រព័ន្ធអេឡិចត្រូនិកអនឡាញ២សេវា។
- **ការចុះដំរុញយកព័ត៌មានតាមរយៈការថតវីដេអូ បានចំនួន២៥ព័ត៌មាន និងបានផ្សាយ ៖**
  - តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) បានចំនួន១៤ព័ត៌មាន
  - តាមរយៈទូរទស្សន៍បាយ័នបានចំនួន២៣ព័ត៌មាន
  - រាយការណ៍ជូនគ្រុបព័ត៌មាន និងសាធារណមតិរបស់ក្រសួងព័ត៌មានបានចំនួន២០៥ព័ត៌មាន។
- **ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិ៖**
  - ព័ត៌មានជាតិបានចំនួន៨០ព័ត៌មាន
  - ព័ត៌មានអន្តរជាតិបានចំនួន៦០ព័ត៌មាន
  - កម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង" បានចំនួន១៩លើក។
- **ព័ត៌មានផ្សាយរបស់វិទ្យុសាគរកោះកុង៖**
  - ព្រឹត្តិការណ៍សំខាន់ៗចំនួន១៧ព័ត៌មាន
  - សារសំឡេងខ្លីសំខាន់ៗរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត ចំនួន១ព័ត៌មាន
  - ទំព័រហ្វេសប៊ុកផេកវិទ្យុសាគរកោះកុងចំនួន២៣១ព័ត៌មាន
  - ព័ត៌មានក្នុងខេត្តចំនួន២៥ព័ត៌មាន
  - ព័ត៌មានជាតិចំនួន៤១ព័ត៌មាន
  - ព័ត៌មានអន្តរជាតិចំនួន៤១ព័ត៌មាន
  - ព័ត៌មានថតផ្សាយជាសំឡេងចំនួន៨២ព័ត៌មាន
  - ព័ត៌មានពេលព្រឹករយៈពេល៣០នាទីចំនួន៧០ព័ត៌មាន
  - សេចក្តីជូនដំណឹងផ្សេងៗចំនួន១៤អត្ថបទ
  - នាទីព្រះពុទ្ធសាសនាចំនួន១៥ម៉ោង
  - នាទីកម្សាន្តមរតកដើមរួមមាន អាយ៉ៃ យីកេ ល្ខោនបាសាក់ និងល្ខោននិយាយចំនួន៣០ម៉ោង។

- **អំពីការផ្សាយតាមរយៈបណ្ដាញសង្គមនានារបស់មន្ទីរព័ត៌មានខេត្ត ៖**
  - ផ្សាយតាមរយៈផេកហ្វេសប៊ុកមន្ទីរព័ត៌មានខេត្តកោះកុងចំនួន៣១២ព័ត៌មាន
  - ផ្សាយតាមរយៈផេកហ្វេសប៊ុកទូរទស្សន៍ជាតិខេត្តកោះកុងសរុបចំនួន១៩៣ព័ត៌មាន
  - ផ្សាយប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្ដេចធិបតី ហ៊ុន ម៉ាណែត ចំនួន៤២លើក
  - ផ្សាយព័ត៌មានបន្ត សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗចំនួន១៤២លើក។
- **ឆ្លើយឆ្លងព័ត៌មានពេលព្រឹក និងរាយការណ៍គ្រឿងញៀនតាមវិទ្យុសាគរកោះកុង ៖**
  - ព័ត៌មានតាមWhatsApp ជូនលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ចំនួន២៥លើក
  - ព័ត៌មានតាមហ្វេសប៊ុកចំនួន១៤លើក
  - ព័ត៌មានទទកពេលព្រឹកចំនួន១លើក។
- **ផ្សព្វផ្សាយសារអប់រំ និងស្ប៉តៈ**
  - សារអប់រំ និងស្ប៉តស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន៦០០លើក
  - សារអប់រំ និងស្ប៉តស្តីពីពិសាគ្រឿងស្រវឹងសូមកុំបើកបរ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៦០០លើក
  - សារអប់រំអំពីបញ្ហាជំងឺអេដស៍បានចំនួន៣០០លើក
  - សារអប់រំអំពីជំងឺគ្រុនចាញ់បានចំនួន៣០០លើក
  - ស្ពតសុខភាព (ញ៉ាំសាប) បានចំនួន១៥០លើក
  - ស្ពតស្តីពី ការបញ្ឈប់អំពើហិង្សាលើស្ត្រីបានចំនួន៣០០លើក
  - ស្ពតអប់រំក៏ដូចជាវិធីការពារជំងឺកូវីដ-១៩ បានចំនួន៤៥០លើក
  - សារអប់រំស្តីពី ការជួញដូរមនុស្សជាអំពើខុសច្បាប់បានចំនួន១៨០លើក
  - ស្ពតអប់រំស្តីពី វិធានការការពារជំងឺអឹមផកបានចំនួន១៥០លើក
  - ស្ពតអប់រំស្តីពី ឆ្លាតវៃមិនប្រើប្រាស់ផលិតផលថៃទាំសុខភាពអនឡាញបានចំនួន១៥០លើក
  - ស្ពតអប់រំស្តីពី គ្រឿងស្រវឹងមិនមានកម្រិតសុវត្ថិភាពបានចំនួន១៥០លើក
  - ស្ពតអប់រំស្តីពី យើងកាត់បន្ថយការទទួលទានអំបិល ដើម្បីបង្ការជំងឺលើសសម្ពាធឈាម និងគ្រោះ ថ្នាក់សរសៃឈាមខួរក្បាលបានចំនួន១៥០លើក
  - ស្ពតអប់រំស្តីពី គិតដល់ជីវិតអ្នក និងអ្នកដទៃ ស្រវឹងសូមកុំបើកបរបានចំនួន ១៥០លើក។
- **ទីភ្នាក់ងារសារព័ត៌មានកម្ពុជាៈ**
  - បានបញ្ជូនព័ត៌មានជូនអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជានៃក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយតាម APP ចំនួន១០ព័ត៌មាន
  - បានផ្សាយព័ត៌មានតាមរយៈផេកហ្វេសប៊ុក AKP នៃមន្ទីរព័ត៌មានខេត្តចំនួន ១១៧ព័ត៌មាន។
- បានជំរុញដល់មន្ត្រីជំនាញសិក្សាស្រាវជ្រាវលើបច្ចេកទេសថ្មីៗ។
- បានជំរុញ និងពង្រឹងដល់មន្ត្រីជំនាញទទួលបន្ទុកក្នុងការកែលម្អកម្មវិធីផ្សាយឱ្យបានល្អប្រសើរ។

### ២.២.៦-ការងារកិច្ចការនារី

- បានផ្សព្វផ្សាយអំពីការផ្តល់សេវាមេធាវីស្ម័គ្រចិត្ត(សម្តេចតេជោ) ជួយដល់ស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សាធ្ងន់ធ្ងរ ដល់ការិយាល័យពាក់ព័ន្ធក្នុងស្រុក មេឃុំ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មេភូមិ អនុភូមិ និងជំនួយការភូមិ នៅសាលាស្រុកមណ្ឌលសីមា មានអ្នកចូលរួមចំនួន៥០នាក់ ស្រី២៥នាក់។
- បានប្រឹក្សាយោបល់ករណីរំលោភសេពសន្ថវៈ ជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ ១ករណី (ជនសង្ស័យ បានលួងលោមរួមភេទជាមួយជនរងគ្រោះជាច្រើនដង) នៅភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ។ លទ្ធផលជនសង្ស័យត្រូវបានប៉ូលីសប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំកោះស្តេចឃាត់ខ្លួនបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្តដំណើរការតាមនីតិវិធីច្បាប់។

- បានសម្របសម្រួលករណីអំពើហិង្សាក្នុងគ្រួសារ ១ករណី (ប្តីប្រច័ណ្ឌ ប្រើអំពើហិង្សាលើប្រពន្ធ ពេលស្រវឹង) នៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង។ ជាលទ្ធផល បានប្រឹក្សាយោបល់ សហការ សម្របសម្រួល ជាមួយអាជ្ញាធរ អប់រំ ណែនាំ ធ្វើកិច្ចសន្យាបញ្ចប់រឿងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំឬស្សីជ្រុំ។
- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ៩ខែ ឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៥ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក នៅសាលប្រជុំកាកបាទក្រហមខេត្ត មានអ្នកចូលរួមចំនួន៣៦នាក់ ស្រី២៩នាក់។
- បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែធ្នូ ឆ្នាំ២០២៤ និងបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ នៅមន្ទីរកិច្ចការនារីខេត្ត មានអ្នកចូលរួមចំនួន១៩នាក់ ស្រី១៦នាក់ គោលបំណងពិភាក្សាការងារដែលបានអនុវត្តកន្លងមក និងរួមគ្នារកដំណោះស្រាយលើបញ្ហាផ្សេងៗ ដើម្បីឱ្យការងារទទួលបានលទ្ធផលកាន់តែប្រសើរ។

### ២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បានចូលរួមក្នុងវេទិកាជាតិស្តីពី "ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច" ឆ្នាំ២០២៤ ក្រោមប្រធានបទ " ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅរដ្ឋបាលមូលដ្ឋាន" តាមប្រព័ន្ធអនឡាញ(Zoom)។
- បានចូលរួមពិធីចែកវិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុ និងមោឃភាពនៃបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន៣ភូមិ នៅភូមិ១ ភូមិ២ និងភូមិ៣ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។
- បានចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅតាមបណ្តាក្រុង ស្រុក ឆ្នាំ២០២៤។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ សេចក្តីសម្រេច កំណត់តំបន់ធ្វើការវិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធចំនួន៤ភូមិ គឺភូមិតានូន ភូមិបាក់នាស់ និងភូមិព្រែកខ្សាច់ និងភូមិទួលពោធិ៍ ឃុំតានូន ស្រុកបូទុមសាគរ។

### ២.២.៨-ការងារធម្មការនិងសាសនា

- បានចូលរួមក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា** ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និងពិធីបិទក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅសាលវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។
- បានចូលរួមចុះពិនិត្យស្ថានភាពកិច្ចការកសាងសមិទ្ធផលនានាក្នុងវត្តឧទ័យារាម (ហៅវត្តជ្រោយប្រស់) និងសាលាបឋមសិក្សាជ្រោយប្រស់ ដោយមានការនិមន្តចូលរួមពីព្រះសង្ឃ គណៈកម្មការ អាចារ្យ អាជ្ញាធភូមិ ឃុំ ស្រុក ស្ថិតក្នុងឃុំជ្រោយប្រស់ ស្រុកកោះកុង។
- បានចូលរួមកម្មវិធីរួមគ្នាដើម្បីអភិវឌ្ឍន៍មនុស្សសិលា ក្រោមប្រធានបទ "ការអប់រំ សីលធម៌ ចរិយាធម៌ សុជីវធម៌ និងគុណធម៌ ដល់សិស្សានុសិស្ស ដែលធ្វើបាឋកថា ដោយឯកឧត្តមបណ្ឌិត យុទ្ធ ភូថង អតីតអភិបាលនៃគណៈអភិបាលខេត្តកោះកុង ស្ថិតនៅសាលប្រជុំវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែនកោះកុង។

### ២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បានទទួល-បញ្ជូនបញ្ញើក្នុងប្រទេសចំនួន១៣.៧៨៤ បញ្ញើ ស្មើនឹង២០.៩៥២,០៥ គ.ក្រ។
- បានទទួល-បញ្ជូនបញ្ញើក្រៅប្រទេសចំនួន១.១៧៤ បញ្ញើ ស្មើនឹង៧៦២,០៥ គ.ក្រ។
- បានចុះពិនិត្យទីតាំងសាខាក្រុមហ៊ុន វីរៈប៊ុនថាំ បើកថ្មី១កន្លែងគ្មានលិខិតអនុញ្ញាត ស្ថិតនៅភូមិ១ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផល បានធ្វើការណែនាំ និងចែកជូនសេចក្តីជូនដំណឹងលេខ០១៣បទ.កក និងប្រកាសលេខ៤៩៨ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈដើម្បីបានជ្រាប និងអនុវត្ត។
- បានចុះត្រួតពិនិត្យក្រុមហ៊ុនអ៊ីវ៉ូលីង ថេកណូឡូជីឯក បានស្នើសុំសាងសងស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទ១ទីតាំង ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ពិនិត្យឃើញថាទីតាំងដីជួលពុំមានបញ្ហាអ្វីទេ និងមានសេវាទូរស័ព្ទរបស់ក្រុមហ៊ុនស្មាត វៀតថេល សែលខាត។

- បានសហការជាមួយម្ចាស់ដីជួល និងអាជ្ញាធរមូលដ្ឋាន ចុះពន្យល់ដល់បងប្អូនប្រជាពលរដ្ឋដែលរស់នៅជាប់ព្រំដី និងបរិវេណជុំវិញដីសាងសង់ស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទរបស់ក្រុមហ៊ុនអ៊ីវ៉ូលីង ថេកណូឡជី ឯ.ក ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ អំពីផលប្រយោជន៍ និងភាពពុំមានផលប៉ះពាល់ នៃការសាងសង់ស្ថានីយ៍បង្គោលអង់តែន។ ក្រោយពីបានស្តាប់ការពន្យល់ណែនាំ បងប្អូនប្រជាពលរដ្ឋទាំងអស់បានឯកភាពដោយមិនជំទាស់អ្វីឡើយ និងបានយល់ព្រមចូលរួមផ្តិតមេដៃទុកជាសក្ខីភាព។
- បានចុះត្រួតពិនិត្យក្រុមហ៊ុនវៀតធេលធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបទូរគមនាគមន៍ ស្ថិតនៅភូមិ២ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផលក្រុមហ៊ុនបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបទូរគមនាគមន៍រួចរាល់ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។
- បានចុះត្រួតពិនិត្យក្រុមហ៊ុនអ៊ីដតខូ ចាប់ផ្តើមសាងសង់ស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទ១ទីតាំង ស្ថិតនៅភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ក្រុមហ៊ុនសាងសង់បង្គោលអង់តែនបានប្រហែល ៣០%។
- បានចុះត្រួតពិនិត្យក្រុមហ៊ុនអ៊ីដតខូ បានស្នើសុំសាងសង់ស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទ១ទីតាំង ស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ពិនិត្យឃើញថាទីតាំងដីជួលពុំមានបញ្ហាអ្វីទេ មានសេវាទូរសព្ទ័របស់ក្រុមហ៊ុនស្មាត វៀតធេល សែលខាត។
- បានសហការជាមួយម្ចាស់ដីជួល និងអាជ្ញាធរមូលដ្ឋាន ចុះពន្យល់ដល់បងប្អូនប្រជាពលរដ្ឋ ដែលរស់នៅជាប់ព្រំដី និងបរិវេណជុំវិញដីសាងសង់ស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទរបស់ក្រុមហ៊ុន អ៊ីដតខូ ស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ អំពីផលប្រយោជន៍ និងភាពពុំមានផលប៉ះពាល់នៃការសាសង់ស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទ។ ក្រោយពីបានស្តាប់ការពន្យល់ណែនាំ បងប្អូនប្រជាពលរដ្ឋទាំងអស់បានឯកភាពដោយមិនជំទាស់អ្វីឡើយ និងបានយល់ព្រមចូលរួមផ្តិតមេដៃទុកជាសក្ខីភាព។
- បានចុះត្រួតពិនិត្យក្រុមហ៊ុនអង្គជាតា ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ខ្សែកាបទូរគមនាគមន៍ ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផល ក្រុមហ៊ុនបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាបទូរគមនាគមន៍រួចរាល់ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។
- បានទទួលលិខិតស្នើសុំសាងសង់ ថែទាំនិងជួសជុលបណ្តាញខ្សែកាបអុបទិក និងផ្លាស់ប្តូរសម្ភារដំឡើងបន្ថែមគ្រឿងបរិក្ខាវិទ្យុម៉ៃក្រូវ៉េវរបស់ក្រុមហ៊ុនទូរសព្ទចល័តពីនិយ័តករទូរគមនាគមន៍កម្ពុជាចំនួន៤០ច្បាប់។
- បានចេញលិខិតអនុញ្ញាតបើកលក់និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខាវិទ្យុគមនាគមន៍និងទូរគមនាគមន៍(ថ្មី-បន្ត) សរុបចំនួន២១ទីតាំង។
- បានចេញលិខិតអនុញ្ញាតលក់គ្រឿងសម្ភារបរិក្ខាកុំព្យូទ័រនិង/ឬឧបករណ៍អេឡិចត្រូនិច ដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និង/ឬ សូហ្វវែរ (បន្ត) ចំនួន៤ទីតាំង។
- បានផ្សព្វផ្សាយ និងចែករំលែកបន្តនូវផេករបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផេករដ្ឋបាលខេត្តកោះកុងពីសកម្មភាពការងារប្រចាំថ្ងៃអំពីសមិទ្ធផលនានា តាមប្រព័ន្ធបណ្តាញសង្គមសរុបចំនួន៨៤លើក។

## ២.២.១០-ការងារមុខងារសាធារណ:

- គិតត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ តាមតារាងទូទាត់ប្រាក់បៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២៤ មន្ត្រីរាជការស៊ីវិលនៅខេត្តកោះកុង មានចំនួន២.៧០៤នាក់ ស្រី១.០៣៨នាក់
  - ចំនួនរាយតាមប្រភេទក្របខ័ណ្ឌ៖
    - ក្របខ័ណ្ឌប្រភេទ "ក" ចំនួន៦១៥នាក់ ស្ត្រី១៦២នាក់
    - ក្របខ័ណ្ឌប្រភេទ "ខ" ចំនួន១.០១៨នាក់ ស្ត្រី៣៦៩នាក់
    - ក្របខ័ណ្ឌប្រភេទ "គ" ចំនួន១.០៧១នាក់ ស្ត្រី៥០៧នាក់។
- បានត្រួតពិនិត្យទិដ្ឋាការលើសំណើសុំឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលប្រចាំខែធ្នូ ជូនមន្ទីរ អង្គភាពជុំវិញខេត្ត ដូចខាងក្រោម ៖

| ល.រ. | បរិយាយ | ដើមគ្រា | ក្នុងគ្រា | បូក យោង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ក្របខ័ណ្ឌថ្មី | ៩០ | ០ | ៩០ | |
| ២ | តាំងស៊ប់ | ៦៤ | ២ | ៦៦ | មន្ទីរពាណិជ្ជកម្ម២ករណី |

| | | | | | |
|---|---|---|---|---|---|
| ៣ | ប្ដូរប្រភេទក្របខ័ណ្ឌ | ០ | ០ | ០ | |
| ៤ | ឡើងថ្នាក់/និយ័តកម្មថ្នាក់ | ៩៣៤ | ៦០០ | ១.៥៣៤ | -មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៩ករណី<br>-មន្ទីរអប់រំ យុវជននិងកីឡា៥៣៨ករណី<br>-រដ្ឋបាលខេត្ត១ករណី<br>-រដ្ឋបាលក្រុងខេមរភូមិន្ទ១ករណី<br>-រដ្ឋបាលស្រុកកោះកុង៣ករណី<br>-រដ្ឋបាលស្រុកបូទុមសាគរ១២១ករណី<br>-រដ្ឋបាលស្រុកថ្មបាំង៦ករណី<br>-រដ្ឋបាលស្រុកស្រែអំបិល២១ករណី |
| ៥ | តែងតាំង/ប្ដូរប្រាក់មុខងារ | ៩៤ | ៤ | ៩៨ | -មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ១ករណី<br>-មន្ទីរសាធារណការ និងដឹកជញ្ជូន ១ករណី<br>-មន្ទីរទេសចរណ៍១ករណី<br>-មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ១ករណី |
| ៦ | ឡើងឋានន្តរស័ក្តិ | ០ | ០ | ០ | |
| ៧ | បញ្ចូលកូន | ១៨៨ | ៨ | ១៩៦ | -មន្ទីរមុខងារសាធារណៈ១ករណី<br>-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ១ករណី<br>-រដ្ឋបាលស្រុកកោះកុង៦ករណី |
| ៨ | បញ្ចូលប្រពន្ធ | ៣៩ | ៣ | ៤២ | -មន្ទីរពាណិជ្ជកម្ម១ករណី<br>-រដ្ឋបាលស្រុកកោះកុង២ករណី |
| ៩ | ចូលនិវត្តន៍ | ៣០ | ១ | ៣១ | -រដ្ឋបាលស្រុកថ្មបាំង១ករណី |
| ១០ | ផ្ទេរចូល | ១៧ | ១ | ១៨ | -រដ្ឋបាលខេត្ត១ករណី |
| ១១ | ផ្ទេរចេញ | ៤៦ | ១ | ៤៧ | -រដ្ឋបាលខេត្ត១ករណី |
| ១២ | នៅក្រៅក្របខ័ណ្ឌដើម | ៥ | ១ | ៦ | -មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត១ករណី |
| ១៣ | ទំនេរគ្មានបៀវត្ស | ៧ | ០ | ៧ | |
| ១៤ | លុបឈ្មោះ | ១០ | ១ | ១១ | -រដ្ឋបាលស្រុកស្រែអំបិល១ករណី |
| ១៥ | ប្ដូរកន្លែងការងារ | ៣ | ០ | ៣ | |
| ១៦ | តំបន់ដាច់ស្រយាល | ៥៧ | ១១ | ៦៨ | -រដ្ឋបាលស្រុកបូទុមសាគរ១១ករណី |
| ១៧ | ចូលបម្រើការងារវិញ | ៣ | ១ | ៤ | -រដ្ឋបាលក្រុងខេមរភូមិន្ទ១ករណី |
| ១៨ | រំលឹកប្រាក់ | ០ | ០ | ០ | |
| ១៩ | ថ្នាក់ពីរពេល | ១៨៤ | ៦២ | ២៤៦ | -រដ្ឋបាលស្រុកមណ្ឌលសីមា២៥ករណី<br>-រដ្ឋបាលស្រុកថ្មបាំង៣៧ករណី |
| ២០ | ថ្នាក់គួបពីរកម្រិត | ០ | ០ | ០ | |
| ២១ | ថ្នាក់គួបបីកម្រិត | ០ | ០ | ០ | |
| ២២ | បញ្ចូលប្រាក់មុខងារ | ១ | ០ | ១ | |
| ២៣ | លំហែមាតុភាព | ៦២ | ១៥ | ៧៧ | -មន្ទីរមុខងារសាធារណៈ១ករណី<br>-មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត៣ករណី<br>-រដ្ឋបាលក្រុងខេមរភូមិន្ទ២ករណី<br>-រដ្ឋបាលស្រុកមណ្ឌលសីមា២ករណី<br>-រដ្ឋបាលស្រុកបូទុមសាគរ៤ករណី<br>-រដ្ឋបាលស្រុកថ្មបាំង៣ករណី |
| ២៤ | ប្ដូរប្រអប់/កែតម្រូវព័ត៌មានមន្ត្រីរាជការ | ៤២២ | ០ | ៤២២ | |
| **សរុបរួម** | | **២.២៥៦** | **៧១១** | **២.៩៦៧** | |

– បានត្រួតពិនិត្យ និងតាមដានលើការបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សា ការិយាល័យប្រជាពលរដ្ឋ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា លើកទី១ និងលើកទី២ ក្នុងខែធ្នូ។

## ២.២.១១-ការងារផ្សេងៗ

### ២.២.១១.១-ការងារសាលាដំបូង

- **ផ្នែកចៅក្រមស៊ើបសួរ**
    - សំណុំរឿងសល់ពីមុន ចំនួន៩០រឿង
    - សំណុំរឿងចូលថ្មី ចំនួន២៧រឿង
    - សំណុំរឿងចាត់ការរួច ចំនួន៥៤រឿង

- សំណុំរឿងកំពុងចាត់ការ ចំនួន៦៣រឿង។
- **ផ្នែកចៅក្រមជំនុំជម្រះ**
  - សំណុំរឿងសល់ពីមុន ចំនួន៦៤រឿង
  - សំណុំរឿងចូលថ្មី ចំនួន៣៦រឿង
  - សំណុំរឿងចាត់ការរួច ចំនួន៩១រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៩រឿង។
- **ផ្នែកតុលាការរដ្ឋប្បវេណី**
  - សំណុំរឿងសល់ពីមុន ចំនួន៦៤រឿង
  - សំណុំរឿងចូលថ្មី ចំនួន៥៩រឿង
  - សំណុំរឿងចាត់ការរួច ចំនួន៧៨រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៤៥រឿង។
- **ការងារអយ្យការអមសាលាដំបូង**
  - សំណុំរឿងសល់ពីមុន ចំនួន១រឿង
  - សំណុំរឿងចូលថ្មី ចំនួន៦៣រឿង
  - សំណុំរឿងចាត់ការរួច ចំនួន៤៤រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន២០រឿង។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បានទទួលកម្រៃសេវាសាធារណៈ (អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត) ដូចខាងក្រោម ៖
  - ការងារសំណង់ ទទួលបានកម្រៃសេវាចំនួន៦.៣៧៤.៤០០រៀល
    - ឯកសារចូលសរុប ចំនួន២ច្បាប់
    - ឯកសារចេញសរុប ចំនួន១ច្បាប់។
  - ការងារសុរិយោដី ទទួលបានកម្រៃសេវាចំនួន១១២.៩៩៦.០៨៦រៀល
    - ឯកសារចូលសរុប ចំនួន៦៣០ច្បាប់
    - ឯកសារចេញសរុប ចំនួន៦១៦ច្បាប់។
- ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖
  - ក្រុមទី១ បំពេញការងារនៅភូមិចំណារ ឃុំប្រឡាយ ស្រុកថ្មបាំង
  - ក្រុមទី២ បំពេញការងារនៅភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីមា
  - ក្រុមទី៣ បំពេញការងារនៅភូមិដីក្រោះ ភូមិប្រៃ និងភូមិតាមាឃ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
  - ក្រុមទី៤ បំពេញការងារនៅភូមិវាលជើង ឃុំស្រែអំបិល ស្រុកស្រែអំបិល។
- ការងារចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ៖
  - ដីឯកជនចំនួន៣ក្បាលដី
- ការងារចុះបញ្ជីដីបន្ត ៖
  - អចលនវត្ថុចុះបញ្ជីជាប្រព័ន្ធ
    - ចុះបញ្ជីផ្ទេរសិទ្ធិបាន ចំនួន១០៤ក្បាលដី
    - ចុះបញ្ជីប្រាតិភោគបាន ចំនួន៣៩ក្បាលដី
  - អចលនវត្ថុចុះបញ្ជីដាច់ដោយដុំ
    - ចុះបញ្ជីប្រាតិភោគបាន ចំនួន២ក្បាលដី

- ក្រុមការងាររបស់មន្ទីរបានបំពេញការងារដូចខាងក្រោម៖
  - បានបំពេញទម្រង់បែបបទចំនួន៦៨០ក្បាលដី
  - បានគូសក្រាហ្វិកចំនួន១.១១២ក្បាលដី
  - បានវាស់វែងចំនួន១.៧៨០ក្បាលដី
  - ចែកបណ្ណចំនួន១៦៣បណ្ណ។

## ២.៣.២-ការងារបរិស្ថាន

- បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកោះកុងចំនួន៤ករណី។
- បានចាប់ឃាត់ឈើអារ២.៤៧០ម³ ម៉ាស៊ីនរណារយន្ត៦គ្រឿង កាំភ្លើងកែច្នៃ១ដើម អាគុយ១ ឧបករណ៍ឆក់ត្រី១គ្រឿង អុសឈើ៤២ស្ទែរ រថយន្ត១គ្រឿង និងទូកយន្ត១គ្រឿង។
- បានរុះរើអន្ទាក់ចាប់សត្វព្រៃ១.៦៣២ខ្សែ មងចាប់សត្វព្រៃ៣៣៨៦ម៉ែត្រ លបកន្ទុយកណ្ដុរ១៨លប ផ្លែសន្ទូច៥៦៣ផ្លែ ខ្ទម៨។
- បានបោះស្លាកសញ្ញាហាមកាប់រុករានដីព្រៃធ្វើជាកម្មសិទ្ធិចំនួន៩ស្លាក។
- បានលែងសត្វព្រៃចូលក្នុងជម្រកធម្មជាតិចំនួន១៨ក្បាល។
- បានពិនិត្យ និងបញ្ជាក់បច្ចេកទេសលើគម្រោងមូលនិធិឃុំថ្មសចំនួន១គម្រោង (ពិនិត្យផលប៉ះពាល់ទៅលើតំបន់ការពារធម្មជាតិ និងតំបន់វប្បធម៌) គឺគម្រោងសាងសង់ផ្លូវបេតុងអាមេ និងដាក់ស្លាកសញ្ញាគម្រោង១កន្លែង នៅស្រុកស្រែអំបិលចំនួន១គម្រោង។
- បានចូលរួមប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ២០២៤ នៅស្រុកស្រែអំបិល។
- បានចុះពិនិត្យផ្ទៀងផ្ទាត់ការកាប់រានព្រៃឈើក្នុងតំបន់ការពារធម្មជាតិតាមផែនទីរូបភាពផ្កាយរណបរបស់ក្រសួងបរិស្ថាន នៅស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកស្រែអំបិល និងស្រុកកោះកុង សរុបបានចំនួន៩៣ទីតាំង លើ១០៦ទីតាំង។

## ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- ការងារថែទាំប្រចាំឆ្នាំ២០២៤
  - ផ្លូវក្រាលកៅស៊ូលើផ្លូវជាតិ និងផ្លូវខេត្តចំនួន៦ខ្សែ ប្រវែងសរុប៧១,៦៩គ.ម សម្រេចបាន១០០%
  - ផ្លូវក្រាលដីល្បាយថ្មលើផ្លូវខេត្តចំនួន៣ខ្សែ ប្រវែងសរុប៧៧,១០គ.ម សម្រេចបាន១០០%។
- ការងារថែទាំខួប ឆ្នាំ២០២៤
  - លើកំណាត់ផ្លូវខេត្តលេខ១៤៨៥អា ដោយក្រាលដីល្បាយថ្ម ប្រវែង៣,៥គ.ម ទទឹង១០ម និងស្ថាបនាលូមូលមុខកាត់១ម ២ជួរចំនួន២កន្លែង ចន្លោះបង្គោលគ.ម៣៣+៦០០-គ.ម៣៧+១០០ ព្រមទាំងដាំបង្គោលបង្ហាញផ្លូវចំនួន៨ដើម ស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ សម្រេចបាន៦៩,១៤%។
- ការងារដឹកជញ្ជូនផ្លូវគោក៖
  - ការងារចុះបញ្ជីយានយន្ត ប្រភេទរថយន្តដឹកទំនិញធុនធ្ងន់ ចំនួន២គ្រឿង
  - ការងារផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តគ្រួសារ ចំនួន១គ្រឿង
  - ការងារបណ្ណបើកបរ ពន្យារសុពលភាពបណ្ណប្រភេទ (យ២) ចំនួន៥បណ្ណ
  - ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចល័ត ចំនួន៤៣៦គ្រឿង។
- ការងារដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ៖
  - ការងារចុះបញ្ជីនាវានេសាទ ចំនួន១គ្រឿង
  - ការងារផ្ទេរកម្មសិទ្ធិនាវានេសាទ ចំនួន១គ្រឿង
  - ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេស នាវានេសាទចំនួន២គ្រឿង។
- ការងារសុវត្ថិភាពចរាចរណ៍៖
  - បានចុះត្រួតពិនិត្យយានយន្តធ្វើចរាចរណ៍លើដងផ្លូវចំនួន២លើក ស្មើនឹង៤៥គ្រឿង ក្នុងនោះ ៖

- រថយន្តត្រឹមត្រូវ ចំនួន៤០គ្រឿង
- ប្រើបណ្ណបើកបរខុសប្រភេទយាន ចំនួន២គ្រឿង
- រថយន្តហួសសុពលភាពត្រួតពិនិត្យលក្ខណៈបច្ចេកទេស (ឆៀក) ចំនួន៣គ្រឿង។

២.៣.៤-ការងារផ្សេងៗ

– (ពុំមាន)។

**២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

២.៤.១-ការងារអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

**១.ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ៖**

**ការពង្រឹងតួនាទី និងភារកិច្ច ៖** ការងារនេះថ្នាក់ដឹកនាំខេត្ត បានពង្រឹងតួនាទី និងភារកិច្ច តាំងពីថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក រហូតដល់ថ្នាក់មូលដ្ឋាន ពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង សំដៅឆ្លុះបញ្ចាំងពីគុណភាព ប្រសិទ្ធភាព និងតម្លាភាព។ បន្ទាប់ពីបានអនុវត្តកន្លងមកឃើញថា ប្រជាពលរដ្ឋមានការសប្បាយចិត្ត និងមានជំនឿទុកចិត្តកាន់តែច្រើនឡើង។

**២.សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ ៖** បទល្មើសព្រហ្មទណ្ឌកើតឡើង ចំនួន១៤លើក ក្នុងនោះមាន៖

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ ៖**

- បទល្មើសឧក្រិដ្ឋ ៖ កើតឡើង២លើក (បទល្មើសរំលោភសេពសន្ថវៈ)
- បទល្មើសមជ្ឈិម ៖ កើតឡើង១លើក (បទល្មើសឆបោករំលោភទំនុកចិត្ត)
- ការខូចខាតបាត់បង់ ៖ បណ្តាលឱ្យរបួសមនុស្ស១នាក់ រងគ្រោះ១០នាក់ និងប្រាក់មួយចំនួន។

**លទ្ធផលបង្ក្រាប ៖** បទល្មើសដែលបានកើតឡើងខាងលើ កម្លាំងមានសមត្ថកិច្ចបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្មបង្ក្រាបបានចំនួន៣ករណី នៃបទល្មើសដែលបានកើតឡើង។ ឃាត់ខ្លួនជនសង្ស័យបានចំនួន៣នាក់ ស្រី១នាក់ និងបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**ខ. បទល្មើសគ្រឿងញៀន៖** បានធ្វើការបង្ក្រាបបទល្មើសរក្សាទុក ជួញដូរ និងប្រើប្រាស់នូវសារធាតុញៀនខុសច្បាប់ ចំនួន១១ករណី ឃាត់ខ្លួនជនសង្ស័យបាន២៦នាក់ ស្រី១នាក់។

- ដកហូតវត្ថុតាង៖ ថ្នាំញៀនប្រភេទ ICE ទម្ងន់៨០,០៩ក្រាម ជញ្ជីងថ្លឹងថ្នាំញៀន១គ្រឿង ម៉ូតូ៣គ្រឿង ទូរស័ព្ទ ១៥គ្រឿង សម្ភារវេចខ្ចប់ និងឧបករណ៍ជក់ថ្នាំញៀនមួយចំនួន។ វត្ថុតាង និងមុខសញ្ញាជនសង្ស័យខាងលើ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**គ. ល្បែងស៊ីសងខុសច្បាប់ ៖** ពុំមានអ្វីកត់សម្គាល់។

**ឃ. បទល្មើសផ្សេងៗ ៖** ពុំមានអ្វីកត់សម្គាល់។

- *វិធានការបង្ការ ៖* កម្លាំងជំនាញនៅតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ចុះធ្វើការអប់រំណែនាំប្រជាពលរដ្ឋ ក្នុងតំបន់ណាដែលមានការសង្ស័យថាមានយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ឱ្យមានការប្រុងប្រយ័ត្ន ហើយបើបានប្រទះឃើញត្រូវរាយការណ៍ជូនកម្លាំងមានសមត្ថកិច្ច ដើម្បីមានវិធានការការពារ។

**៣. សភាពការណ៍សណ្តាប់ធ្នាប់ និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍គ្រោះថ្នាក់ចរាចរណ៍ ៖** ពុំមានអ្វីគួរកត់សម្គាល់។

- *វិធានការបង្ការ ៖* បានបញ្ចុះកម្លាំងជំនាញសហការជាមួយកម្លាំងពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ នៅតាមទីប្រជុំជន តាមដងផ្លូវកែងសំខាន់ៗ និងចុះអប់រំអាជីវករលក់ដូរជុំវិញផ្សារ លក់ដូរអមសងខាងផ្លូវឱ្យរៀបចំអីវ៉ាន់លក់ដូរឱ្យមានសណ្តាប់ធ្នាប់ល្អ សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដោយថាហេតុ។

**៤. បទល្មើសជួញដូរមនុស្ស ជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ៖** ពុំមាន។

**ខ. អំពើហិង្សាក្នុងគ្រួសារ ៖** ពុំមាន។

**គ. សកម្មភាពក្មេងទំនើង ៖** ពុំមាន។

*វិធានការការពារ៖* បានពង្រឹងកម្លាំងនៅថ្នាក់មូលដ្ឋាន ចុះល្បាតត្រួតពិនិត្យឃ្លាំមើលជាប្រចាំក្នុងមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កឡើងដោយក្មេងទំនើង ឬជនទំនើង។

**៥. ការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានខិតខំយកចិត្តទុកដាក់ពិនិត្យ សម្របសម្រួល និងដោះស្រាយជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលមានជម្លោះដីធ្លីនៅសេសសល់មួយចំនួនបន្តទៀត។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

ការងារនេះត្រូវបានពង្រឹងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់មូលដ្ឋាន សំដៅគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ បរិស្ថាន និងអនាម័យក្នុងភូមិ ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព ពិសេសយើងបានអប់រំប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានាក្នុងការថែរក្សាបរិស្ថាន សុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារ ដើម្បីធ្វើឱ្យមូលដ្ឋានខេត្តទាំងមូលមានសោភ័ណភាពស្អាត រមណីយដ្ឋានល្អ ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មកកម្សាន្តបានកាន់តែច្រើន។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖**

**ក. សភាពការណ៍គ្រោះមហន្តរាយ ៖**

- **ករណីអគ្គិភ័យ៖** កើតឡើង១លើក បណ្តាលឱ្យឆេះផ្ទះ១ខ្នងទំហំ៤មx៥ម ប្រក់ស័ង្កសី និងទ្រព្យសម្បត្តិក្នុងផ្ទះអស់ទាំងស្រុង នៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ មូលហេតុបណ្តាលមកពីឆ្លងចរន្តអគ្គិសនី
- **ករណីលង់ទឹក៖** កើតឡើងចំនួន២លើក បណ្តាលឱ្យស្លាប់៣នាក់ ស្រី១នាក់ ក្នុងនោះ នៅស្រុកស្រែអំបិល១លើក បណ្តាលឱ្យស្លាប់២នាក់ប្រុស និងក្រុងខេមរភូមិន្ទ១លើក បណ្តាលឱ្យស្លាប់១នាក់ស្រី។

**ខ. ការឆ្លើយតប៖**

– លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកា និងគ្រឿងឧបភោគបរិភោគមួយចំនួន ជូនក្រុមគ្រួសារដែលរងគ្រោះដោយករណីកូនប្រុសបានលង់ទឹកស្លាប់

– លោកស្រី អ៊ី នារីនេត អភិបាលរងនៃគណៈអភិបាលខេត្ត និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានអញ្ជើញដឹកនាំក្រុមការងារចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកា គ្រឿងឧបភោគបរិភោគមួយចំនួន ជូនក្រុមគ្រួសារដែលរងគ្រោះដោយករណីអគ្គិភ័យ

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានត្រៀមកម្លាំងជួយអន្តរាគន៍ដល់មូលដ្ឋាន និងបានបញ្ជាឱ្យកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ចេញប្រចាំការត្រៀមលក្ខណៈជួយសង្គ្រោះប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

**គ. ការត្រៀមបង្ការ៖**

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានត្រៀមលក្ខណៈជាប្រចាំ ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលមានគ្រោះមហន្តរាយកើតឡើង

– កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ បានចុះបំផុសអប់រំប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្ន ចំពោះគ្រោះថ្នាក់អគ្គិភ័យ និងខ្យល់កន្ត្រាក់ តាមរយៈវេទិកាផ្សព្វផ្សាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ក្នុងមូលដ្ឋាន។

**ឃ. ឆ្លើយតបរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖** បានត្រៀមសម្ភារ បរិក្ខារ និងកម្លាំងសមត្ថកិច្ច សហការជាមួយជំនាញ ក្នុងការចុះអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ ករណីមានការរីករាលដាលជំងឺឆ្លងកាចសាហាវណាមួយ។

**២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍**

– **សភាពការណ៍សន្តិសុខនៅតាមព្រំដែន ៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨២៧ ដើរល្បាតម្ចាស់ការចំនួន៤១លើក និងល្បាតសហការជាមួយកងយោធពលខេមរភូមិន្ទ៤លើក (ក្នុង១លើកៗ មានកម្លាំងពី៦នាក់ទៅ១២នាក់) ប្រដាប់ដោយអាវុធគ្រប់ដៃ ជាពិសេសបានដាក់កម្លាំងតាមគោលដៅសំខាន់ៗចំនួន១៣ចំណុច។

– **សកម្មភាពសហគមន៍-ពលរដ្ឋតវ៉ាផ្សេងៗ ៖** កើតឡើងចំនួន១លើក ដូចខាងក្រោម៖

○ នៅភូមិដីខ ឃុំដីខលើ ស្រុកស្រែអំបិល មានប្រជាពលរដ្ឋ២៦២នាក់ ស្រី១៤៧នាក់ ដឹកនាំដោយឈ្មោះ ហាន់ ទៀត ភេទប្រុស ឈ្មោះ ផាវ ញើង ភេទស្រី និងមានការចូលរួមពីអង្គការសមាគមនអាដហុកមកពីខេត្តកំពង់ស្ពឺ ឈ្មោះ គង់ មនី និងសហគមន៍កសិករកម្ពុជា ឈ្មោះ ញិល ភាព បានប្រារព្ធពិធីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ធ្នូ ខួបលើកទី៧៦ ឆ្នាំ២០២៤ ក្រោមប្រធានបទ ទិវាសិទ្ធិមនុស្ស១០ធ្នូ និងសូមអាជ្ញាធរជួយពន្លឿនផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋ ឱ្យបានឆាប់។

– **សកម្មភាពគណបក្សនយោបាយ ៖** ពុំមានអ្វីកត់សម្គាល់។

– **សកម្មភាពអង្គការ-សមាគម និងគ្រឹះស្ថានអប់រំ ៖** កើតឡើង៥លើក ដូចខាងក្រោម ៖

○ ក្រុមការងារអង្គការសមាគមសុវណ្ណភូមិវង្សក័ក្តបូរី ចំនួន៣នាក់ប្រុស ដឹកនាំដោយឈ្មោះ ហែម រឿន បាននាំយកអំណោយ និងសម្ភារសិក្សាមកចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន១១១នាក់ ស្រី៥០នាក់ នៅសាលាបឋមសិក្សាយាយសែន ក្នុងភូមិយាយសែន ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ

○ អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ បានរៀបចំកម្មវិធីទស្សនកិច្ច និងសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន៨៦នាក់ ស្រី៤២នាក់ នៅអនុវិទ្យាល័យជ្រោយស្វាយ ក្នុងភូមិជ្រោយស្វាយកើត ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល

○ ក្រុមការងារអង្គការ YCC ចំនួន៣នាក់ ដឹកនាំដោយលោក ឡឹក សារ៉ាត បានប្រជុំផ្សព្វផ្សាយស្តីពីបញ្ហាបរិស្ថាន នាំឱ្យមានការប្រែប្រួលអាកាសធាតុ ដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចូលរួមចំនួន៥៧នាក់ ស្រី៣២នាក់ នៅវិទ្យាល័យហ៊ុនសែនត្រពាំងរូង

○ ក្រុមការងារអង្គការ «C B N CAMBODIA» ចំនួន២នាក់ ស្រី១នាក់ ដឹកនាំដោយលោកស្រី ហ៊ី តាំងហ៊ន់ ប្រធានផ្នែកសុខភាព ដោយមានការសម្របសម្រួលពីអាជ្ញាធរភូមិ-ឃុំ បានចុះមកបើកវគ្គបណ្តុះបណ្តាលដល់ក្រុមទ្រទ្រង់សុខភាពភូមិ ស្តីពីជំងឺមិនឆ្លង (ជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែម) នៅមណ្ឌលសុខភាពកោះកាពិ ក្នុងភូមិ១ ឃុំកោះកាពិ ស្រុកកោះកុង ដោយមានលោកគ្រូ អ្នកគ្រូពេទ្យ និងប្រជាពលរដ្ឋចូលរួមចំនួន៧នាក់ ស្រី៣នាក់

○ ក្រុមការងារអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance CAMBODIA) ចំនួន៣នាក់ប្រុស ដឹកនាំដោយលោក គុណ ប៊ុនហុង មន្ត្រីគម្រោងរ៉េដបូកជួរភ្នំក្រវាញខាងត្បូង បានចុះបិទផ្ទាំង ព័ត៌មានផ្សព្វផ្សាយអំពីតំបន់រ៉េដបូក និងតំបន់សហគមន៍ តាមខ្នងផ្ទះប្រជាពលរដ្ឋ ក្នុងភូមិដីទំនាប ឃុំត្រពាំងរូង ស្រុកកោះកុង បានចំនួន១៨ខ្នង។

– **សកម្មភាពសហគមន៍ ពលរដ្ឋ និងសាសនា ៖** មានក្រុមសាសនាយេស៊ូគ្រិស្តចំនួន២នាក់ ស្រី១នាក់ បានចុះផ្សព្វផ្សាយវិស័យសាសនាព្រះយេស៊ូគ្រិស្ត និងបានចែកនំចំណីដល់ក្មេងៗ និងមនុស្សចាស់ នៅភូមិតានី ឃុំភ្ញីមាស ស្រុកគិរីសាគរ ចំនួន២លើក។

តារាងទី២៣៖ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងចរាចរណ៍

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គ្រោះថ្នាក់ចរាចរណ៍ | ៨ | ០ | ៨ |
| ២ | គ្រោះថ្នាក់ផ្សេងៗ | ៣៤ | ២ | ៣៦ |
| ៣ | បទល្មើសគ្រឿងញៀន | ៨៤ | ១១ | ៩៥ |
| ៤ | បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | ១ | ០ | ១ |
| ៥ | បទល្មើសសេដ្ឋកិច្ច | ០ | ០ | ០ |
| ៦ | ល្បែងស៊ីសង | ១ | ០ | ១ |
| ៧ | ក្មេងទំនើង | ១៤ | ០ | ១៤ |
| ៨ | បទល្មើសផ្សេងៗ | ០ | ០ | ០ |

### ២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត

– **ការគ្រប់គ្រងតាមកំពង់ផែសមុទ្រ (តាមច្រកកំពង់ផែសមុទ្រស្រែអំបិល និងប៉ាក់ខ្លង) ៖**

○ **នាវីកកម្ពុជាចូល** ចំនួន១៨០នាក់ ស្រី០០នាក់ ដោយប្រើដលយានយន្ត១១គ្រឿង
○ **នាវីកកម្ពុជាចេញ** ចំនួន១៨០នាក់ ស្រី០០នាក់ ដោយប្រើដលយានយន្ត១១គ្រឿង។

– **ការគ្រប់គ្រង ការស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ៖**
○ ជនបរទេសស្នាក់នៅរយៈពេលខ្លី សរុបមនុស្សរួមចំនួន៥៨៦នាក់ ស្រី១៥១នាក់ មាន៣៥សញ្ជាតិ
○ ជនបរទេសស្នាក់នៅរយៈពេលវែង មានចំនួន២៧៧៣នាក់ ស្រីចំនួន៨៤៥នាក់ មាន៣៧សញ្ជាតិ។

– **ការគ្រប់គ្រងប្រព័ន្ធវត្តមានជនបរទេស(FPCS)៖**

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស សហការជាមួយកម្លាំងផ្នែកអន្តោប្រវេសន៍ នៃអធិការដ្ឋាននគរបាលស្រុកមណ្ឌលសីមា និងស្រុកគិរីសាគរ បានចុះធ្វើបច្ចុប្បន្នភាពជនបរទេសក្នុងប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS) បានចំនួន៧គោលដៅ(ផ្ទះជួល) ដោយឱ្យម្ចាស់ទីតាំងដាក់ពាក្យសុំបង្កើតគណនី និងមានកិច្ចសន្យាក្នុងការរាយការណ៍វត្តមានជនបរទេសចូលមកស្នាក់នៅចាប់ពី២៤ម៉ោងឡើងទៅ ស្តេនលិខិតឆ្លងដែនចូលប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា(FPCS)។

– **ការងារអធិការកិច្ចហត្ថពលកម្មបរទេស៖** ពុំមាន។

– **ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ៖**

○ បានប្រគល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី២ ដល់ជនបរទេសអន្តោប្រវេសន្តចំនួន១គ្រួសារ មនុស្សរួមចំនួន២នាក់ ស្រី២នាក់ ស្មើនឹង២បណ្ណ មាន១សញ្ជាតិ (វៀតណាម)

○ បានទទួលបណ្ណស្នាក់នៅអចិន្ត្រៃយ៍ពីនាយកដ្ឋានជនបរទេសអន្តោប្រវេសន៍ និងជនភៀសខ្លួនចំនួន៥០បណ្ណ ស្រី៣០បណ្ណ (នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤) ដែលមានដូចខាងក្រោម៖

- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី១ ចំនួន២នាក់ ស្រី១នាក់
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី២ ចំនួន៤នាក់ ស្រី១នាក់
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី៣ ចំនួន៤៤នាក់ ស្រី២៨នាក់។

– **ជនបរទេសរងគ្រោះដោយបទល្មើសផ្សេងៗ៖** ពុំមាន។

– **ជនបរទេសល្មើសច្បាប់អន្តោប្រវេសន៍៖** នៅអធិការដ្ឋាននគរបាលស្រុកកោះកុង មានជនបរទេសមកសុំអន្តរាគមន៍ពីសមត្ថកិច្ចករណីខ្លួនត្រូវបានជនសង្ស័យជួញដូរឆ្លងដែនពីប្រទេសវៀតណាមមកកម្ពុជា ដែលមានឈ្មោះ ដូហុង សើន (Đó Hồng Sơn) ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិវៀតណាម ( គ្មានលិខិតឆ្លងដែនជាប់ខ្លួន)។ ក្រោយទទួលបានការរាយការណ៍ពីជនរងគ្រោះ កម្លាំងជំនាញអន្តោប្រវេសន៍ សហការជាមួយកម្លាំងអន្តរាគមន៍ បានចុះត្រួតពិនិត្យ និងឃាត់រថយន្តសង្ស័យ១គ្រឿង ម៉ាកLuxus RX 300 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2R.2536 ទិសដៅពីក្រុងបាវិត ខេត្តស្វាយរៀង មកខេត្តកោះកុង ចំណែកជនសង្ស័យបានរត់គេចខ្លួនបាត់។

– **ជនបរទេសបង្កបទល្មើសផ្សេងៗ៖** ពុំមាន។

– **ជនបរទេសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ៖** ពុំមាន។

– **ជនបរទេសប្រព្រឹត្តបទល្មើសផ្សេងៗ ៖** កើតឡើងចំនួន២លើក ឃាត់ខ្លួនជនសង្ស័យជនជាតិចិនចំនួន៣នាក់ប្រុស និងបង្កឱ្យមនុស្សស្លាប់ចំនួន២នាក់ប្រុស (ចិន១នាក់ ខ្មែរ១នាក់) ដូចខាងក្រោម៖

○ ករណីជនជាតិចិនចំនួន១នាក់ យកកាំបិតចិតបន្លែដងឈើចាក់ទៅលើជនរងគ្រោះជាជនជាតិចិនចំនួន១នាក់ប្រុស បណ្តាលឱ្យស្លាប់។ មូលហេតុ ជនសង្ស័យឈ្លោះប្រកែកគ្នារឿងដណ្តើមកាបូប។

○ ករណីគ្រោះថ្នាក់ចរាចរណ៍ដឹកដីក្រឡាប់រថយន្តបណ្តាលឱ្យស្លាប់ជនជាតិខ្មែរចំនួន១នាក់ប្រុស ត្រូវបានជនសង្ស័យជនជាតិចិនចំនួន២នាក់ បានយកសាកសពចេញពីកន្លែងកើតហេតុបំលាស់ទីទៅទុកនៅកន្លែងផ្សេង ជិតការដ្ឋានរបស់ខ្លួនដោយមិនបានរាយការណ៍ជូនសមត្ថកិច្ច។

– **ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុផ្សេងៗ៖** កើតឡើងចំនួន៣លើក បណ្តាលឱ្យស្លាប់២នាក់ប្រុស (ជនជាតិចិន) និងរងរបួសចំនួន៣នាក់ (ជនជាតិចិន២នាក់ និងជនជាតិវៀតណាម១នាក់) ដូចខាងក្រោម៖

○ ករណីផ្ទុះគីបតេអិនតេឃ្លងថ្ម បណ្តាលឱ្យស្លាប់១នាក់ និងរងរបួស១នាក់

- ករណីចងករធ្វើអត្តឃាតដោយខ្លួនឯងបណ្តាលឱ្យស្លាប់១នាក់
- ករណីគ្រោះថ្នាក់ចរាចរណ៍បើកបរម៉ូតូធ្លាក់ផ្លូវដោយខ្លួនឯងក្នុងស្ថានភាពស្រវឹងស្រា បណ្តាលឱ្យរងរបួសចំនួន២នាក់

– **កិច្ចប្រតិបត្តិការ ៖** បានជួយសង្គ្រោះចំនួន៩លើក មនុស្សរួម៣នាក់ ស្រី២នាក់ ស្មើនឹង២សញ្ជាតិ មានជនជាតិចិនចំនួន១នាក់ប្រុស និងឥណ្ឌូនេស៊ី២នាក់ស្រី តាមបណ្តឹងលេខ៨៣៦,៨៣៥ និង៨៦៧)។ ជនបរទេសខាងលើ ត្រូវបានកម្លាំងផែនការងារសន្តិសុខនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង កសាងសំណុំរឿងបញ្ជូនទៅកាន់ទីស្នាក់ការត្រៀមបណ្តេញចេញរាជធានីភ្នំពេញ និងទីស្នាក់ការត្រៀមបណ្តេញចេញខេត្តព្រះសីហនុ ដើម្បីបន្តនីតិវិធី។

## ២.៨.៨-ការងារគ្រប់គ្រងពន្ធនាគារ

- បានអប់រំមន្ត្រីឱ្យយល់ដឹងពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ ចំនួន១លើក
- បានអប់រំជនជាប់ឃុំឱ្យយល់ដឹងពីក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល ចំនួន២លើក
- បានបង្រៀនថ្នាក់អក្ខរកម្មដល់ទណ្ឌិត ចំនួន១៥នាក់ប្រុស (គ្រូបង្គោលជាមន្ត្រីពន្ធនាគារ) ក្រោមការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ រយៈពេល៨ខែ
- បានបណ្តុះបណ្តាលជនជាប់ឃុំឱ្យមានជំនាញកាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្ត និងដេរលបក្តាម ជារៀងរាល់ថ្ងៃ
- បានលើកគោលការណ៍ពិនិត្យ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសការអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្គត់ផ្គង់ជីវភាព សេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារចំនួន៤លើក
- បានសម្របសម្រួលជូនក្រុមគ្រូពេទ្យអង្គការលើកាដូមកពិនិត្យព្យាបាល និងផ្តល់ឱសថដល់ជនជាប់ឃុំចំនួន១លើក និងផ្តល់ប្រឹក្សាច្បាប់ដល់ជនជាប់ឃុំចំនួន៥នាក់ ចំនួន១លើក
- បានសម្របសម្រួលជូនអង្គការលើកាដូមកចែកអំណោយដល់ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនតាមម្តាយចំនួន១លើក
- គិតត្រឹមថ្ងៃទី១០/១២/២០២៤ ជនជាប់ឃុំជាក់ស្តែងមានចំនួន៧៣៣នាក់ ស្ត្រី៥១នាក់ ក្នុងនោះមាន៖
  - ជនត្រូវចោទ ចំនួន៨៦នាក់ ស្ត្រី៨នាក់
  - ជនជាប់ចោទ ចំនួន១០៦នាក់ ស្ត្រី០៧នាក់
  - ពិរុទ្ធជន ចំនួន២០៤នាក់ ស្ត្រី១៨នាក់
  - ទណ្ឌិត ចំនួន៣៣៧នាក់ ស្ត្រី១៨នាក់

  ក្នុងនោះមាន៖
    - ជនជាតិបរទេស មានចំនួន១៣នាក់ ស្ត្រី៤នាក់ (វៀតណាមចំនួន៦នាក់ ស្ត្រី៣នាក់ ថៃ២នាក់ ចិន៣នាក់ និងម៉ាឡេស៊ី២នាក់ ស្ត្រី១នាក់)
    - អនីតិជនចំនួន៤១នាក់ ស្ត្រី១នាក់
    - កូនតាមម្តាយចំនួន៣នាក់ កុមារី០០នាក់
- ជនជាប់ឃុំត្រូវបានចាប់ចូលថ្មីមានចំនួន៤៦នាក់ ស្ត្រីចំនួន៥នាក់
- ជនជាប់ឃុំត្រូវបានដោះលែងមានចំនួន៣៣នាក់ស្ត្រីចំនួន៤នាក់។

## ២.៨.៩-ការងារផ្សេងៗ

- (ពុំមាន)។

# ផ្នែកទី៣-បញ្ហាប្រឈម និងសំណើដោះស្រាយ

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| ១ | ទម្រង់បែបបទនៃការផ្តល់សេវាវិស័យសាធារណការ និងដឹកជញ្ជូន មិនទាន់បន្សីគ្នាក្នុងស្តង់ដាតែមួយ | ស្នើសុំក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន រៀបចំឱ្យមានប្រព័ន្ធស្តង់ដាតែមួយ |
| ២ | ក្រុមហ៊ុនមួយចំនួន ទទួលសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ | -ស្នើឱ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀត<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| ៣ | វិស័យព័ត៌មានៈ ជំនាញផ្នែកសារព័ត៌មាន ជំនាញបច្ចេកទេសវិទ្យុ និងទូរទស្សន៍របស់មន្ត្រីមួយចំនួននៅក្នុងមន្ទីរព័ត៌មានខេត្ត នៅមានកម្រិត | ស្នើសុំក្រសួងព័ត៌មាន បើកវគ្គបណ្តុះបណ្តាលអំពីជំនាញផ្នែកសារព័ត៌មាន ជំនាញបច្ចេកទេសវិទ្យុ និងទូរទស្សន៍ |
| ៤ | វិស័យកិច្ចការនារីៈ<br>-មន្ត្រីការិយាល័យជំនាញមន្ទីរ និងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង/ស្រុក សមត្ថភាពជំនាញសម្របសម្រួលនូវមានកម្រិត<br>-ខ្វះមន្ត្រីក្របខ័ណ្ឌ | ស្នើសុំក្រសួងកិច្ចការនារី<br>-ជួយពង្រឹងសមត្ថភាពបន្ថែមអំពីជំនាញសម្របសម្រួលដល់មន្ត្រីមន្ទីរ និងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង/ស្រុក<br>-ស្នើសុំក្រសួងបន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត |
| ៥ | **វិស័យសង្គមកិច្ចៈ**<br>-ឃុំសង្កាត់មួយចំនួនពុំទាន់យល់ជ្រួតជ្រាបច្បាស់អំពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ<br>-ការបើកផ្តល់ប្រាក់ធានារ៉ាប់រងសង្គម ប្រាក់បូជាសព និងប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារនៃសព អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល នៅមានការយឺតយ៉ាវ | -មន្ទីរផ្តល់វគ្គបណ្តុះបណ្តាលកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដល់ឃុំ សង្កាត់<br>-ស្នើសុំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ<br>សម្បទា ពន្លឿនការងារបើកប្រាក់ឧបត្ថមនានាឱ្យបានលឿន |
| ៦ | **វិស័យវប្បធម៌ និងវិចិត្រសិល្បៈ**<br>-ខ្វះមន្ត្រីក្របខ័ណ្ឌសម្រាប់បម្រើការងារនៅមន្ទីរ<br>-ខ្វះឧបករណ៍ភ្លេង ឃឹម និងទ្រសោ | **ស្នើសុំក្រសួងៈ**<br>-បន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត<br>-សម្របសម្រួលជួយដោះស្រាយឧបករណ៍ភ្លេង |
| ៧ | **វិស័យធនធានទឹក និងឧតុនិយមៈ**<br>-ខ្វះមន្ត្រីបច្ចេកទេស<br>-ខ្វះគ្រឿងចក្រ | ស្នើសុំក្រសួងៈ<br>-បន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត<br>-ជួយសម្រួលផ្តល់គ្រឿងចក្រ |
| ៨ | **វិស័យធម្មការ និងសាសនាៈ**<br>-ខ្វះមន្ត្រីជាច្រើននាក់ដើម្បីបម្រើការងារ<br>-កញ្ចប់ថវិកាចំណាយប្រចាំឆ្នាំពុំទាន់ឆ្លើយតបទៅនឹង សកម្មភាពការងារ<br>-ការអនុវត្តលិខិតបទដ្ឋានពាហិរសាសនានៅមិនទាន់មានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយនៅឡើយ<br>-គណៈសង្ឃខេត្ត ក្រុងស្រុក នៅខ្វះសមាសភាពមន្ត្រីសង្ឃជាច្រើនដើម្បីគ្រប់គ្រងអនុវត្តការងារក្នុងវិស័យព្រះពុទ្ធសាសនា | ស្នើសុំក្រសួងៈ<br>-បន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត<br>-ផ្តល់កញ្ចប់ថវិកាបន្ថែម<br><br>-ធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការអនុវត្តការងារពាហិរសាសនា<br>-ស្នើសុំគណៈសង្ឃនាយកព្រះមេគ្គា ជួយជំរុញព្រះមេគណខេត្តទាំងពីរគណៈឱ្យស្នើសុំតែងតាំងព្រះមន្ត្រីសង្ឃ ខេត្ត ក្រុង ស្រុក បន្ថែមទៀត |
| ៩ | វិស័យផែនការៈ មន្ត្រីទទួលបន្ទុកការវិភាគទិន្នន័យ ចងក្រង និងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ពុំទាន់មាន ជំនាញច្បាស់លាស់ | ស្នើសុំក្រសួង បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមតាមជំនាញបន្ថែមដល់មន្ត្រីពាក់ព័ន្ធ |
| ១០ | វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ៈ មន្ត្រីទទួលបន្ទុកបច្ចេកទេសពុំទាន់មានជំនាញច្បាស់លាស់ | ស្នើសុំក្រសួង បើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់មន្ត្រីពាក់ព័ន្ធ |
| ១១ | **វិស័យអប់រំ យុវជន និងកីឡាៈ**<br>-នៅតាមគ្រឹះស្ថានសិក្សាមួយចំនួនខ្វះគ្រូក្របខ័ណ្ឌ និងមុខវិជ្ជាឯកទេស<br>-ការចុះគាំទ្របច្ចេកទេសអនុវត្តស្តង់ដារសាលាគំរូមិនទាន់បានទូលំទូលាយតាមស្តង់ដារទាំង៥ | ស្នើក្រសួងៈ<br>-ផ្តល់ក្របខ័ណ្ឌគ្រូបង្រៀនបន្ថែម<br>-ពង្រឹង និងជំរុញការចុះគាំទ្របច្ចេកទេសឱ្យស្របតាមគោលការណ៍ណែនាំរបស់ក្រសួង |

# ផ្នែកទី៤÷ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់

## ៤.១-រដ្ឋបាលខេត្ត

### ៤.១.១-ការងាររដ្ឋបាល

- ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញលើកទី៨ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចប្រជុំគណៈអភិបាលប្រចាំខែ និងប្រចាំអឌ្ឍមាស
- ត្រៀមរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំខែមករា ឆ្នាំ២០២៥ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្ត
- បន្តស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬ ខូចខាតដោយយថាហេតុ តាមរយៈការស្នើសុំរបស់សាមីខ្លួន
- បន្តស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈរដ្ឋបាលឃុំ សង្កាត់
- ត្រៀមបញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រង ឯកសារ (www.cdepart.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋ
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់រដ្ឋបាលខេត្ត
- ត្រៀមសហការរៀបចំប្រារព្ធមីទ្ទីងខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧មករា (១៩៧៩-២០២៥)។

### ៤.១.២-ការងារគណៈកម្មាធិការនានា

**ក-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

- ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញ ក្នុងខែមករា ឆ្នាំ២០២៥
- ត្រៀមរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំខែមករា ឆ្នាំ២០២៥
- ត្រៀមរៀបចំសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញ

**ខ-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

- ត្រៀមសម្របសម្រួលជាមួយក្រុមការងារកសាងផែនការខេត្ត រៀបចំកិច្ចប្រជុំចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៥-២០២៧
- ត្រៀមសម្របសម្រួលជាមួយក្រុមការងារកសាងផែនការខេត្តលើការរៀបចំកិច្ចប្រជុំប្រមូលជាតុចូលលើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២៥-២០២៩)

**គ-គណៈកម្មាធិការលទ្ធកម្ម**

- ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងចាត់អាទិភាពផែនការលទ្ធកម្មឆ្នាំ២០២៥។

### ៤.១.៣-ការងារផែនការ និងវិនិយោគ

- ត្រៀមរៀបចំកិច្ចប្រជុំចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៥-២០២៧
- ត្រៀមរៀបចំកិច្ចប្រជុំប្រមូលជាតុចូលលើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០២៥-២០២៩)
- ត្រៀមសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងអភិវឌ្ឍន៍មូលនិធិក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ២០២៥
- បន្តចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០២៣ និងឆ្នាំ២០២៤។

### ៤.១.៤-ការគ្រប់គ្រងធនធានមនុស្ស

- ត្រៀមរៀបចំដីកាតែងតាំងជូនដល់មន្ត្រីរាជការនៃរដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត
- បន្តសហការជាមួយគ្រូបង្គោលថ្នាក់ក្រុង ស្រុក ចុះត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាព សង្គមតាមបណ្តាអង្គភាពផ្តល់សេវាទាំង៣ (រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព)។

### ៤.១.៥-ការងារអន្តរវិស័យ

- បន្តសហការជាមួយក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីនៅសេសសល់ជូនប្រជាពលរដ្ឋ
- បន្តសហការ និងសម្របសម្រួលជាមួយមន្ទីរអង្គភាពជំនាញ និងអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត លើការស្នើសុំអាជ្ញាបណ្ណអាជីវកម្ម និងសេវាកម្មនានាក្នុងភូមិសាស្ត្រខេត្តកោះកុង
- បន្តយកចិត្តទុកដាក់ការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋខេត្តកោះកុង ឱ្យបានល្អប្រសើរ
- បន្តជំរុញការរៀបចំទីលានទុកដាក់សំរាម សំណល់រឹង និងរាវ នៅតាមបណ្តាក្រុង ស្រុក
- ត្រៀមសហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងស្រង់ទិន្នន័យដីធ្លីប្រជាពលរដ្ឋរស់នៅភូមិទួលគគីរលើ និងភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ដើម្បីស្នើសុំអនុប្រយោគចេញពីតំបន់ការពារធម្មជាតិ និងតំបន់គម្របព្រៃឈើឆ្នាំ២០០២។

### ៤.១.៦-ការងារអង្គភាពច្រកចេញចូលតែមួយ

- បន្តផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរ
- បន្តតាមដាន និងជួយគាំទ្រលើការផ្តល់សេវាបណ្ណព្រំដែនកម្ពុជា-ថៃ នៅរដ្ឋបាលក្រុង ស្រុក
- បន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋឱ្យទទួលប្រើប្រាស់សេវាប្រៃសណីយ៍កម្ពុជា ដែលបានសហការជាមួយអង្គភាពច្រកចេញ ចូលតែមួយ នៃរដ្ឋបាលខេត្ត
- បន្តផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តថ្មីៗ ដល់មន្ត្រីក្នុងអង្គភាព។

### ៤.១.៧-ការងារការិយាល័យប្រជាពលរដ្ឋ

- ត្រៀមប្រចាំការនៅតុពិសេស ក្នុងអង្គភាពច្រកចេញចូលតែមួយចំនួន១២ម៉ោង ក្នុង១សប្តាហ៍
- បន្តចុះបើកប្រអប់សំបុត្រការិយាល័យប្រជាពលរដ្ឋខេត្ត នៅតាមមុខមន្ទីរមួយចំនួន និងក្រុង ស្រុក ឃុំ សង្កាត់
- ត្រៀមទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗ តាមមធ្យោបាយទាំង៥ (១.ជួបផ្ទាល់ ២.ប្រអប់សំបុត្រ ៣.ប្រព័ន្ធតេឡេក្រាម ៤.តាមទូរស័ព្ទ និង៥ កម្មវិធីទូរស័ព្ទដៃ "មតិយើង")
- បន្តចាត់វិធានការដោះស្រាយបណ្តឹងក្នុងសមត្ថកិច្ចឱ្យបានឆាប់បំផុត ដើម្បីបង្កើនទំនុកចិត្តជូនប្រជាពលរដ្ឋ
- ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំខែមករា ឆ្នាំ២០២៤
- ត្រៀមរៀបចំផែនការសកម្មភាពការងារប្រចាំខែមករា និងឆ្នាំ២០២៥។

### ៤.១.៨-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បន្តពិនិត្យ និងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- បន្តសហការរៀបចំពាក្យបណ្តឹងឱ្យរដ្ឋបាលខេត្ត និងបំពេញតួនាទីជាមេធាវីតំណាង និងការពារផលប្រយោជន៍ស្របច្បាប់ជូនរដ្ឋបាលខេត្ត។

### ៤.១.៩-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

- បន្តពង្រឹងកិច្ចសហការទប់ស្កាត់នូវរាល់អំពើរត់គេចពន្ធតាមច្រកទ្វារ ដូចជា ទំនិញគ្រប់ប្រភេទ និងការជួញដូរមនុស្សឆ្លងដែន ជួញដូរគ្រឿងញៀន អាវុធជាតិផ្ទុះ និងវត្ថុបុរាណផ្សេងៗ
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសជិតខាង ដោយឈរលើគោលជំហរ គោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរ ក្នុងតំបន់ព្រំដែន

- បន្តពង្រឹងការយាមល្បាតការពារគ្រប់គោលដៅ ដើម្បីរក្សាសុវត្ថិភាពក្នុងភូមិសាស្ត្រ ឱ្យបានល្អប្រសើរ
- បន្តពង្រឹងការអនុវត្តជាប្រចាំ នូវការងារសន្តិសុខ សណ្តាប់ធ្នាប់ និងថែរក្សាអនាម័យបរិស្ថាន
- បន្តត្រួតពិនិត្យលិខិតស្នាម មនុស្ស មធ្យោបាយ ទំនិញចេញចូល និងទប់ស្កាត់បទល្មើសជ្រៀតចូលដោយខុសច្បាប់។

### ៤.១.១០-ការគ្រប់គ្រងហិរញ្ញវត្ថុ

- បន្តរៀបចំអាណត្តិបើកបៀវត្សប្រចាំខែមករា ឆ្នាំ២០២៥ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- បន្តរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

### ៤.១.១១-ការងារលទ្ធកម្ម

- ត្រៀមរៀបចំនីតិវិធីបញ្ចប់សុពលភាពលទ្ធកម្មសំណង់ឆ្នាំ២០២៤។

### ៤.១.១២-ការងារសុខាភិបាល

- បន្តផ្តល់សេវាពិនិត្យ ពិគ្រោះព្យាបាលជំងឺ និងពង្រឹងការថែទាំ ព្យាបាលជំងឺដោយការយកចិត្តទុកដាក់នៅគ្រប់មូលដ្ឋានសុខាភិបាល
- បន្តចុះអប់រំផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ការព្យាបាល ការបង្ការជំងឺឆ្លង និងជំងឺមិនឆ្លងតាមកម្មវិធីជាយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល
- បន្តអនុវត្តតាមគោលការណ៍យុទ្ធសាស្ត្រថ្មីរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលដែលបានដាក់ចេញថ្មីៗ
- បន្តចុះអភិបាលកិច្ចការងារសុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលតាមផែនការគ្រោងទុក
- បន្តផ្តល់កិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាលក្នុងខេត្ត
- ត្រៀមប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាល (Pro.TWGH) ដែលមានអង្គការដៃគូចូលរួម
- បន្តអប់រំ ផ្សព្វផ្សាយអំពីវិធីការពារការចម្លងមេរោគអេដស៍ ធ្វើតេស្តដើម្បីស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងពង្រឹងការព្យាបាលប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តផ្តល់សេវាជូនដល់ស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះមុន-ក្រោយសម្រាល និងមកសម្រាលកូន នៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ
- បន្តផ្តល់សេវាផ្តល់ថ្នាំបង្ការ១១មុខដល់កុមារ និងផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះ នៅតាមមណ្ឌលសុខភាព
- បន្តផ្តល់សេវាពន្យារកំណើតនៅតាមមណ្ឌលសុខភាពទូទាំងខេត្ត
- បន្តចាត់ក្រុមការងារចត្តាឡីស័កប្រចាំការនៅទីស្នាក់ការច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ដើម្បីពិនិត្យកម្តៅលើអ្នកធ្វើដំណើរ អ្នកបើកបរយានយន្តចេញចូលច្រកព្រំដែនជារៀងរាល់ថ្ងៃ ព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគទៅលើរថយន្តដឹកទំនិញចេញ-ចូល
- បន្តអប់រំសុខភាព ស្តីពីវិធានការការពារជំងឺគ្រុនឈាមតាមរយៈបុគ្គលិកសុខាភិបាល នៅពេលប្រជាពលរដ្ឋមកទទួលសេវានៅមូលដ្ឋាន និងសិស្សានុសិស្សនៅតាមសាលារៀន។

### ៤.១.១៣-ការងារក្រុមការងាររាជរដ្ឋាភិបាល

- បន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីឈ្វេងយល់អំពីកង្វល់នានា នៅក្នុងមូលដ្ឋាន
- បន្តខិតខំដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង នៅតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់
- ចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងទិសដៅការងារប្រចាំឆ្នាំ២០២៥ របស់រដ្ឋបាលខេត្តកោះកុង
- ចូលរួមប្រារព្ធមីទ្ទីងខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧មករា (១៩៧៩-២០២៥)។

### ៤.១.១៤-ការងារផ្សេងៗ

- (ពុំមាន)។

## ៤.២-មន្ទីរ និងអង្គភាពជំនាញ

### ៤.២.១-ផ្នែកសេដ្ឋកិច្ច

#### ៤.២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បន្តចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមបណ្តាក្រុង/ស្រុក
- បន្តចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមបណ្តាក្រុង/ស្រុក
- ត្រៀមអន្តរាគមន៍ពីការបំផ្លាញ របស់សត្វល្អិតចង្រៃ និងជំងឺលើដំណាំតាមបណ្តាក្រុង/ស្រុក
- បន្តពង្រឹងការត្រួតពិនិត្យអនាម័យសត្វ ចលនាដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វទូទាំងខេត្ត
- បន្តត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វតាមបណ្តាក្រុង/ស្រុក
- បន្តតាមដានត្រួតពិនិត្យទីតាំងអាជីវកម្ម និងការធ្វើចរាចរណ៍ថ្នាំកសិកម្ម ជីកសិកម្មក្នុងខេត្ត
- បន្តតាមដានពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការ
- បន្តចុះពិនិត្យ និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត
- បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលដែលស្ថិតក្នុងតំបន់ ស្ថាប័នពាក់ព័ន្ធ និងកម្លាំងល្បាតរបស់សហគមន៍ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យបានទាន់ពេលវេលា
- បន្តចុះផ្សព្វផ្សាយការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ នៅតាមបណ្តាក្រុង/ស្រុកក្នុងខេត្ត
- បន្តសហការជាមួយរដ្ឋបាលជលផល ចុះប្រមូលទិន្នន័យផលនេសាទសមុទ្រតាមបណ្តាមូលដ្ឋាននានាក្នុងខេត្ត
- បន្តសហការជាមួយអង្គការ MCC ចុះទម្លាក់ប្រអប់ជម្រកត្រីសិប្បនិម្មិតនៅតាមបណ្តាសហគមន៍នេសាទក្នុងខេត្ត
- បន្តចុះតាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ករណីរំលោភទន្ទ្រានកាន់កាប់ សាងសង់ផ្ទះ ពីសំណាក់ប្រជាពលរដ្ឋនៅលើដីចម្ការឈើអាកាស្យា ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

#### ៤.២.១.២-ការងារធនធានទឹក និងឧតុនិយម

- បន្តពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ
- បន្តពង្រឹងការងារប្រមូលទិន្នន័យឧតុនិយម តាមបណ្តាស្រុកដែលមានស្ថានីយឧតុនិយមឱ្យកាន់តែឆាប់រហ័ស និងសុក្រឹតដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម
- បន្តជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃបឹងព្រាវ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល។

#### ៤.២.១.៣-ការងារអភិវឌ្ឍជនបទ

- បន្តចុះធ្វើបច្ចុប្បន្នភាពផ្លូវ និងសំណង់សិល្បៈការ្យ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទតាមបណ្តាឃុំ ស្រុក
- បន្តចុះស្រង់ទិន្នន័យសារពើភណ្ឌផ្លូវជនបទ និងរាប់ចរាចរណ៍យានយន្តលើដងផ្លូវតាមបណ្តាឃុំ និងស្រុក
- បន្តចុះធ្វើបច្ចុប្បន្នភាព អណ្តូងលូ អណ្តូងស្នប់ ស្រះទឹក និងប្រព័ន្ធចែកចាយទឹកសហគមន៍ នៅក្នុងឃុំ ស្រុកគោលដៅ។

#### ៤.២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បន្តចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ដៃបាញ់ប្រេង ទំនិញផលិត ទំនិញវេចខ្ចប់នៅក្រុងខេមរភូមិន្ទ
- បន្តជំរុញម្ចាស់សហគ្រាស/សិប្បកម្ម ឱ្យយកសំណាកផលិតផលទៅវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- បន្តពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយរបស់មន្ទីរលើការផ្តល់សេវាសាធារណៈជូនម្ចាស់សហគ្រាស/

សិប្បកម្ម។

### ៤.២.១.៥-ការងាររ៉ែ និងថាមពល

- បន្តផ្សព្វផ្សាយដល់អាជីវករឱ្យយល់ដឹងអំពីច្បាប់ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់ និងអាចម៍ដី)
- បន្តផ្សព្វផ្សាយសារាចរ និងសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ជូនដល់អាជីវករពាក់ព័ន្ធ
- បន្តជំរុញ និងគាំទ្រដល់ក្រុមហ៊ុនផលិត ផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនីទាំងអស់ឱ្យបន្តពង្រីកបណ្តាញជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់
- បន្តតាមដាន និងត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនីឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ទាំងគុណភាព ប្រសិទ្ធភាព និងសោភណ្ឌភាពនៅទីប្រជុំជន ក្នុងក្រុងខេមរភូមិន្ទ ដើម្បីជៀសវាងកើតឧបទ្ទវហេតុផ្សេងៗ
- បន្តខិតខំកៀរគរចំណូលសួយសារធនធានរ៉ែ ដើម្បីបង់ចូលថវិការដ្ឋ។

### ៤.២.១.៦-ការងារពាណិជ្ជកម្ម

- បន្តផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បន្តតាមដានស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន១១៩មុខប្រចាំថ្ងៃ
- បន្តតាមដានការផ្គត់ផ្គង់ តម្រូវការ និងតម្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រៀងរាល់២ដងក្នុងមួយសប្តាហ៍
- បន្តចុះពិនិត្យតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈក្នុងក្រុង ស្រុកទូទាំងខេត្ត
- បន្តសហការជាមួយសភាពាណិជ្ជកម្មខេត្តក្នុងការអភិវឌ្ឍពាណិជ្ជកម្ម
- បន្តចុះសិក្សាផលិតផលសក្តានុពលនៅបណ្តាក្រុង ស្រុកទូទាំងខេត្ត
- បន្តតាមដានស្ថានភាពជួញដូរទំនិញនៅតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម
- បន្តចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ដើម្បីចុះត្រួតពិនិត្យគុណភាពទំនិញ និងសុវត្ថិភាពម្ហូបអាហារ។

### ៤.២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាគារ

#### ៤.២.១.៧.១-ការងារហិរញ្ញវត្ថុ

- បន្តពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តពង្រឹងការត្រួតពិនិត្យចំណូល ចំណាយតាមបណ្តាអង្គភាព ក្រុង និងស្រុក ឱ្យបានត្រឹមត្រូវ
- ត្រៀមបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុតាមបណ្តាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ
- បន្តពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈ
- បន្តពង្រឹងការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យបានល្អប្រសើរ
- បន្តជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើបញ្ជីសារពើភណ្ឌ (ទាំងដីមានកម្មសិទ្ធិ និងដីបម្រុងរដ្ឋ)។

#### ៤.២.១.៧.២-ការងារពន្ធដារ

- បន្តកៀរគរចំណូលពន្ធ ដើម្បីសម្រេចបានតាមផែនការចំណូលពន្ធសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់សាខាពន្ធដារខេត្តកោះកុង ដែលបានកំណត់ដោយលិខិតលេខ៨៤០ អពដ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានពន្ធដារ និងបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ។

### ៤.២.១.៧.៣-ការងារគយ និងរដ្ឋាករ

- បន្តពង្រឹងការងារគ្រប់គ្រងការប្រមូលពន្ធឱ្យបានតាមផែនការកំណត់ និងពង្រឹងការអនុវត្តវិមជ្ឈការតម្លៃឱ្យបានល្អ
- បន្តធ្វើប្រតិបត្តិការបង្ក្រាបរថយន្តចង្កូតឆ្វេង និងចង្កូតស្តាំ ដែលគ្មានពន្ធ
- បន្តបង្កើនប្រសិទ្ធភាពការងារបង្ការ បង្ក្រាបអំពើរត់គេចពន្ធ និងបន្លំពន្ធ ជាពិសេសតាមរយៈការអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បន្តពង្រឹងប្រសិទ្ធភាពនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាមួយក្រុមអន្តរាគមន៍ពិសេស និងក្រុមអនុលោមភាព ដើម្បីចូលរួមប្រសិទ្ធភាពការងារនៅតាមការិយាល័យមាត់ច្រកក្រោមឱវាទ និងបន្តកែលម្អ និងខិតខំប្រមូលចំណូលពីក្រុមទំនិញចម្រុះបន្ថែមឱ្យអស់តាមសក្តានុពលជាក់ស្តែង
- បន្តសម្របសម្រួលពាណិជ្ជកម្មអន្តរជាតិឱ្យបានសមស្របតាមបទប្បញ្ញត្តិជាធរមាន និងចាត់វិធានការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនចេញ និងចូលឱ្យកាន់តែសុក្រឹត
- បន្តជំរុញសកម្មភាពគ្រប់គ្រងផលនេសាទនាំចេញនាំចូលឱ្យមកបង់ពន្ធតាមនីតិវិធីគយ
- បន្តពង្រឹងអភិបាលកិច្ច គុណភាពសេវារបស់អង្គភាពគយ និងរដ្ឋាករ និងបន្តបំពេញការងារឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពទាំងការងាររដ្ឋបាល និងការងារប្រតិបត្តិការគយ ពិសេសកែសម្រួលកម្លាំងដើម្បីបំពេញភារកិច្ចមានការទទួលខុសត្រូវច្បាស់លាស់តាមបទដ្ឋានគយ និងរដ្ឋាករ។

## ៤.២.១.៨-ការងារទេសចរណ៍

- បន្តផ្សព្វផ្សាយអំពីសក្តានុពល និងគោលដៅទេសចរណ៍ទាក់ទាញសំខាន់ៗក្នុងខេត្តដល់ភ្ញៀវទេសចរ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ សារាចរណែនាំ សេចក្តីជូនដំណឹង និងជំរុញឱ្យអាជីវករមកធ្វើ និងបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបានទាន់ពេលវេលាទូទាំងខេត្ត
- បន្តចុះជំរុញឱ្យអាជីវករមកធ្វើ និងបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបានទាន់ពេលវេលា តាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងយន្តការច្រកចេញចូលតែមួយឃុំសង្កាត់។

## ៤.២.១.៩-ការងារផែនការ

- បន្តចុះប្រមូលទិន្នន័យសន្ទស្សន៍ថ្លៃទំនិញនៅផ្សារស្រែអំបិល ស្រុកស្រែអំបិល និងផ្សារដងទង់ ក្រុងខេមរភូមិន្ទ
- បន្តផលិតឯកសារព័ត៌មានស្ថានភាពខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងឯកសារពិន្ទុវិស័យខេត្ត
- បន្តធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រ និងផលិតបណ្ណសមធម៌ជូនគ្រួសារក្រីក្រ នៅតាមបណ្តាភូមិ ឃុំ សង្កាត់
- បន្តចុះអនុវត្តការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ និងជំរុញបុគ្គលបម្រើការងារក្នុងវិស័យសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យស្នើសុំដាក់ពាក្យសម្ភាសកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

## ៤.២.១.១០-ការងារផ្សេងៗ

### ៤.២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- បន្តផ្តល់សេវាបើក និងបង់ប្រាក់ជូនអតិថិជន
- បន្តប្តូរប្រាក់ចាស់ ទក់ រហែក ជូនអតិថិជន
- បន្តស្រាស់ជ្រើសក្រដាសប្រាក់ចាស់ ទក់ រហែក
- បន្តរៀបចំកម្មវិធីផ្សព្វផ្សាយការទូទាត់ឌីជីថល (KHQR) និងប្រព័ន្ធបាគង នៅតាមទីប្រជុំជន។

### ៤.២.១.១០.២-ការងារធនាគារ

- បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធFMIS នូវដំហានបន្តបន្ទាប់
- បន្តពង្រឹងការកត់ត្រាចំណូល ចំណាយ តាមប្រព័ន្ធFMIS ឱ្យកាន់តែប្រសើរ
- បន្តអនុវត្តសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សរៀងរាល់២សប្តាហ៍ម្តង ក្នុងខែនីមួយៗ
- បន្តពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal)ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ឱ្យបានកាន់តែប្រសើរ
- បន្តពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ចំណូល ចំណាយ និងតារាងតុល្យភាពឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

៤.២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បន្តរៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយដល់អាជីវករ ពាណិជ្ជករ និងបណ្តាក្រុមហ៊ុននានា អំពីច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ
- បន្តរៀបចំ និងដំណើរការអនុវត្តកម្មវិធីចុះអង្កេតទំនិញតាមទីផ្សារនានានៅខេត្តកោះកុង
- បន្តកសាង វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីហានិភ័យមុខទំនិញដែលចរាចរលើទីផ្សារ
- បន្តបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី អំពីច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ និងអនុវត្តនីតិវិធី
- បន្តអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពម្ហូបអាហារដល់អាជីវករក្នុងផ្សារដងទង់ និងផ្សារភូមិ៤ ក្រុងខេមរភូមិន្ទ។

## ៤.២.២-ផ្នែកសង្គមកិច្ច

### ៤.២.២.១-ការងារអប់រំ យុវជន និងកីឡា

- បន្តចុះពិនិត្យតាមដាន និងចុះជួយណែនាំការងារបច្ចេកទេស ការងារគ្រប់គ្រងដល់នាយក និងគ្រូបង្រៀន នៅតាមបណ្តាគ្រឹះស្ថានសិក្សាសាធារណៈ
- ត្រៀមដឹកនាំក្រុមយុវជនរៀបចំស្រាវជ្រាវមេរៀន ដើម្បីយកមកសិក្សាត្រៀមសម្រាប់ជជែកដេញដោល
- បន្តបង្វឹកដល់ក្រុមកីឡាករ កីឡាការិនី សម្រាប់ត្រៀមចូលរួមប្រកួតកីឡានៅឆ្នាំ២០២៥។

### ៤.២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តសហការជាមួយអាជ្ញាធរសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ដើម្បីរៀបចំឯកសារក្នុងការស្នើសុំទុកដាក់កុមារ២នាក់ឱ្យបានស្នាក់នៅ និងរៀនសូត្រក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋខេត្តកោះកុង
- បន្តចូលរួមស្តាប់ចម្លើយអនីតិជនទំនាស់នឹងច្បាប់ចំនួន៣នាក់ ភេទប្រុស ក្នុងដំណាក់កាលជំនុំជម្រះ អាយុចាប់ពី១៤ឆ្នាំ ដល់១៧ឆ្នាំ ជាប់ចោទពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស (ទៅវិញទៅមក) នៅសាលាដំបូងខេត្តកោះកុង។

### ៤.២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

៤.២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តជំរុញដល់នាយកសហគ្រាស/គ្រឹះស្ថាន ដែលប្រើប្រាស់កម្មករ និយោជិតខ្មែរ និងបរទេសមុនចូលបម្រើការងារ និងកំពុងបម្រើការងារឱ្យមកធ្វើសៀវភៅ និងបណ្ណការងារឱ្យស្របតាមច្បាប់
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង
- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងាររួម និងវិវាទបុគ្គល
- បន្តពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារតាមបណ្តាសហគ្រាស/គ្រឹះស្ថានក្នុងខេត្ត
- បន្តពង្រឹងប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈរបស់មន្ទីរ

- បន្តពង្រឹងភាពសុខដុមរមនា នៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និងនិយោជកឱ្យបានល្អប្រសើរ។

### ៤.២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បន្តផ្សព្វផ្សាយគោលនយោបាយសន្តិសុខសង្គម ដល់ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យសាធារណៈ និងឯកជន
- បន្តស្រាវជ្រាវ និងចុះបញ្ជិកាសហគ្រាសថ្មីៗក្នុងខេត្តកោះកុង។

### ៤.២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- បន្តតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្តកោះកុង
- បន្តពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារស្ថានីយ ចេតិយ និងបូជនីយដ្ឋានប្រវត្តិសាស្ត្រនានា ក្នុងភូមិសាស្ត្រខេត្តកោះកុង
- បន្តបណ្តុះបណ្តាលរបាំបុរាណ និងរបាំប្រពៃណី ដល់សិស្សានុសិស្ស និស្សិត និងយុវជននានា
- ត្រៀមសហការជាមួយរដ្ឋបាលខេត្តកោះកុង រៀបចំកម្មវិធីសម្តែងសិល្បៈ ក្នុងពិធីបុណ្យជាតិ និងពិធីផ្សេងៗ ជូនសាធារណជនទស្សនាកម្សាន្ត
- បន្តយន្តការចុះត្រួតពិនិត្យការរៀបចំ និងគ្រប់គ្រងស្លាកយីហោពាណិជ្ជកម្មប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ។

### ៤.២.២.៥-ការងារព័ត៌មាន

- បន្តជំរុញការផ្សព្វផ្សាយផ្នែកឯកជននានាឱ្យគោរពច្បាប់ និងបទដ្ឋានបច្ចេកទេសវិស័យព័ត៌មាន
- បន្តផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការដាក់ពាក្យស្នើសុំបើក និងបន្តសុពលភាពអាជ្ញាបណ្ណវិស័យព័ត៌មាន ជូនដល់ម្ចាស់អាជីវកម្ម សេវាកម្មនៅក្នុងខេត្តទាំងអស់ដែលពុំទាន់មានអាជ្ញាបណ្ណ និងអាជ្ញាបណ្ណផុតសុពលភាព ត្រូវមកស្នើសុំអាជ្ញាបណ្ណរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងទាន់ពេលវេលា
- បន្តជំរុញការចុះយកព័ត៌មានតាមរយៈថតវីដេអូ និងបង្កើនទំនាក់ទំនងតាមបណ្តាក្រុង ស្រុកដើម្បីទទួលបានព័ត៌មាន
- បន្តស្រាវជ្រាវលើបច្ចេកវិទ្យា និងកម្មវិធីថ្មីៗស្របតាមកាលៈទេសៈសង្គម
- បន្តជំរុញ និងបង្កើនការផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ ទូរទស្សន៍បាយ័ន និងទូរទស្សន៍ផ្សេងៗទៀត
- បន្តជំរុញ និងបង្កើនការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម ឱ្យកាន់តែទូលំទូលាយជាងមុន
- បន្តជំរុញការយកចិត្តទុកដាក់កែលម្អកម្មវិធីផ្សាយរបស់វិទ្យុផ្សាយសំឡេង
- បន្តផ្សព្វផ្សាយព័ត៌មាន ស្ប៉តអប់រំផ្សេងៗ ពិសេសស្ប៉តស្តីពីជំងឺកូវីដ-១៩
- បន្តផ្សព្វផ្សាយរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំជាតិ និងខេត្តឱ្យកាន់តែទូលំទូលាយ។

### ៤.២.២.៦-ការងារកិច្ចការនារី

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ការបង្កើតមាតិកាផ្សព្វផ្សាយ និងការរៀបចំសេចក្តីប្រកាសព័ត៌មាន ដល់មន្ត្រីមន្ទីរកិច្ចការនារីខេត្ត
- ត្រៀមរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារបន្ទាប់។

### ៤.២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បន្តសហការជាមួយមន្ទីរជំនាញចុះតាមដានការអនុវត្តច្បាប់ របស់រាជរដ្ឋាភិបាលនៅតាមក្រុង ស្រុក ទូទាំងខេត្ត

កោះកុង

- បន្តទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងមជ្ឈដ្ឋាននានា ដើម្បីពិនិត្យដោះស្រាយតាមនីតិវិធី
- បន្តសម្របសម្រួល និងទំនាក់ទំនងរាល់ការងាររវាងអាជ្ញាធរខេត្ត និងទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តកោះកុង។

**៤.២.២.៨-ការងារធម្មការនិងសាសនា**

- ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈ និងរដ្ឋបាលខេត្ត រៀបចំពិធីបុណ្យនានាក្នុងព្រះពុទ្ធសាសនា និងពាហិរសាសនា
- ត្រៀមរៀបចំកម្មពិធីប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ត្រី ទោ ឯក សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥។

**៤.២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍**

- បន្តចុះត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងគោលនយោបាយលើការប្រើប្រាស់ និងការធ្វើសេវាលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងខេត្ត។
- បន្តផ្សព្វផ្សាយប្រកាសរួម លេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនដល់អាជីវករពាក់ព័ន្ធការបើកធ្វើសេវាអាជីវកម្មលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងខេត្ត។

**៤.២.២.១០-ការងារមុខងារសាធារណៈ**

- បន្តត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណើសុំទូទាត់ប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តពិនិត្យផ្ទៀងផ្ទាត់ រៀបចំរបាយការណ៍ និងបែងចែកតារាងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តត្រួតពិនិត្យ ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុកជុំវិញខេត្តឱ្យបានត្រឹមត្រូវ
- បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការ និងបន្តត្រួតពិនិត្យ តាមដាន និងជំរុញការបង្វែរប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលបើកមិនប្រក្រតីចូលថវិការដ្ឋវិញ។

**៤.២.២.១១-ការងារផ្សេងៗ**

**៤.២.២.១១.១-ការងារសាលាដំបូង**

- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី៥០%ទៅ៨០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងរដ្ឋប្បវេណីជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច។

**២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

**២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

- បន្តពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ និងប្រមូលចំណូលជូនរដ្ឋ
- បន្តអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ
- បន្តពង្រឹង និងយកចិត្តទុកដាក់ការងារគ្រប់គ្រងសំណង់
- បន្តចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ។

### ២.៣.២-ការងារបរិស្ថាន

- បន្តចុះល្បាតទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើស ក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋកុំឱ្យទន្ទ្រានព្រៃយកដីធ្វើកម្មសិទ្ធិ ការបរបាញ់ និងការចាប់សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះពង្រឹងការធ្វើកិច្ចសន្យាការពារបរិស្ថាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញដល់ម្ចាស់សិប្បកម្ម និងអាជីវកម្មផ្សេងៗ
- បន្តធ្វើយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងយុទ្ធនាការ "**កម្ពុជាស្អាត ខ្មែរធ្វើបាន**"។

### ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- បន្តអនុវត្តការងារថែទាំជាប្រចាំ ជួសជុលផ្លូវសំបុកមាន់ និងស្រោចកៅស៊ូលើស្នាមប្រេះសម្រាប់ឆ្នាំ២០២៤
- បន្តអនុវត្តគម្រោងថែទាំខួបផ្លូវខេត្តលេខ១៤៨៥អា ប្រវែង៣,៥គ.ម ទទឹង១០ម៉ែត្រ
- បន្តចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យយានយន្តគ្រប់ប្រភេទដែលធ្វើចរាចរណ៍តាមដងផ្លូវសាធារណៈឱ្យគោរពច្បាប់ចរាចរណ៍ ពិសេសឱ្យអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី និងរឹតបន្តឹងគ្រប់អ្នកបើកបររថយន្តទាំងអស់ត្រូវមានបណ្ណបើកបរ និងស្រង់ស្ថិតិយានដ្ឋានក្នុងក្រុង និងតាមស្រុកទូទាំងខេត្តកោះកុង
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកតាមសាលារៀន និងទីប្រជុំជន
- បន្តសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចដើម្បីធ្វើការត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសពីច្បាប់កំណត់ រថយន្តដឹកជញ្ជូន រថយន្តដឹកដី និងដឹកខ្សាច់ ដែលអាចបង្កគ្រោះថ្នាក់ចរាចរណ៍។

### ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

## ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

- បន្តផ្សព្វផ្សាយគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" លេខ ០១ គ.ន.ប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២១ របស់រាជរដ្ឋាភិបាលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់ភូមិ ឃុំ សង្កាត់ និងបណ្តាអង្គការសង្គមស៊ីវិលទូទាំងខេត្ត
- បន្តរៀបចំកសាងផែនការ និងកម្មវិធីការងារប្រចាំខែសម្រាប់ចុះអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលក្រុមនីមួយៗទទួលខុសត្រូវ
- បន្តបង្កើនកម្មវិធីធ្វើវេទិកាសាធារណៈឱ្យបានគ្រប់ភូមិ ឃុំ សង្កាត់ ទូទាំងខេត្ត ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមយោបល់ដោះស្រាយបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន និងទិតៀនកែលម្អរាល់សកម្មភាពអសកម្មរបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលមានកន្លងមក សំដៅបង្កើនសកម្មភាពអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តដឹកនាំអនុវត្តឱ្យបានទៀងទាត់នូវរបបប្រជុំប្រចាំខែដើម្បីត្រួតពិនិត្យលទ្ធផលកិច្ចប្រតិបត្តិការ និងដាក់ចេញផែនការវិធានការ អនុវត្តជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន
- បន្តយកចិត្តទុកដាក់ចាត់តាំងអនុវត្តនូវបណ្តាវិធានការស្តីពីការលុបបំបាត់បទល្មើស និងគ្រោះថ្នាក់សង្គម ពាក់ព័ន្ធ

នឹងលក្ខណៈសម្បត្តិទាំង៧យ៉ាង នៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យមានប្រសិទ្ធភាពខ្ពស់

- បន្តជំរុញចលនាប្រឡងប្រណាំងបង្កើតស្នាដៃនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានផុលផុសក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" សម្រាប់ទទួលការសរសើរ និងជូនរង្វាន់ប្រចាំឆ្នាំនីមួយៗ។

## ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

- បន្តស្រាវជ្រាវក្តាប់សភាពការណ៍ ឧបាយកលរបស់បណ្តាភាគីអមិត្ត និងចលនាប្រឆាំងផ្សេងៗចំពោះរាជរដ្ឋាភិបាល ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការងារត្រួតពិនិត្យវត្តមានជនបរទេសឆ្លងកាត់ និងស្នាក់នៅក្នុងខេត្តដើម្បីទប់ស្កាត់ការលួចជ្រៀតចូលរបស់ក្រុមភេរវជន
- បន្តក្តាប់សភាពការណ៍បាតុកម្ម កូដកម្ម និងអំពើភេរវកម្មផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- បន្តក្តាប់រាល់សភាពការណ៍ បទល្មើសព្រហ្មទណ្ឌទូទាំងខេត្ត និងធ្វើការវិភាគវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវវិធានការបង្ការ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព
- បន្តជំរុញវិធានការ និងបង្ក្រាបក្រុមក្មេងទំនើងនៅទូទាំងខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងកាត់បន្ថយបទល្មើសក្នុងសង្គម
- បន្តពង្រឹងបំប៉នជំនាញដល់មន្រ្តីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព
- បន្តសហការជាមួយអាជ្ញាធរដែនដី ដើម្បីបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមប្រឆាំងទប់ស្កាត់បទល្មើសគ្រឿងញៀន
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយភ្នាក់ងារប្រឆាំងគ្រឿងញៀនភាគីថៃ ដើម្បីដកបទពិសោធន៍ និងផ្តល់ព័ត៌មានជូនគ្នាទៅវិញទៅមក សំដៅធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនឱ្យមានប្រសិទ្ធភាព
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ដើម្បីអប់រំឱ្យស៊ីជម្រៅដល់ប្រជាពលរដ្ឋ សំដៅកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានវិធានការផាកពិន័យតាមច្បាប់កំណត់
- បន្តពង្រឹងការគ្រប់គ្រងបណ្តាគោលដៅដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច ដូចជា សណ្ឋាគារ ផ្ទះសំណាក់។ល។ ដោយធ្វើកិច្ចសន្យា និងតាមដានកុំឱ្យគោលដៅទាំងនោះ ក្លាយជាកន្លែងប្រព្រឹត្តបទល្មើស
- បន្តចុះស្រង់ទិន្នន័យ និងស្រាវជ្រាវប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់។

## ២.៤.៣-ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត

- បន្តទទួលពាក្យស្នើសុំបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំពោះអ្នកគ្រប់អាយុ និងស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ តាមនីតិវិធី
- បន្តរៀបចំបញ្ជីទទឹងជនបរទេសអន្តោប្រវេសន្ត ដែលមិនមកបន្តសុពលភាពបណ្ណស្នាក់នៅ
- បន្តសហការជាមួយបណ្តាម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ និងផ្ទះជួល ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យជនបរទេសស្នាក់នៅរយៈពេលខ្លី និងរយៈពេលវែង ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តសហការជាមួយអធិការនគរបាលក្រុង ស្រុក និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងវត្តមានជនបរទេស និងត្រួតពិនិត្យស្រាវជ្រាវរកជនបរទេសដែលលួចចូលស្នាក់នៅ និងប្រកបមុខរបរមិនស្របច្បាប់
- បន្តចែកប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត និងបណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេសអន្តោប្រវេសន្តប្រើប្រាស់តាមនីតិវិធីច្បាប់
- បន្តសហការជាមួយអង្គភាពពន្ធនាគារ ដើម្បីគ្រប់គ្រង និងប្រមូលទិន្នន័យជនបរទេសឱ្យបានជាប់ជាប្រចាំ
- បន្តជំរុញអធិការនគរបាលក្រុង ស្រុក អនុវត្តផែនការលេខ ០៩៥៨.ក របស់ស្នងការដ្ឋាននគរបាលខេត្ត ស្តីពីការ

គ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន និងធ្វើការស្រាវជ្រាវរកឯកសារលិខិតឆ្លងដែនរបស់ជនបរទេសដែលស្នាក់នៅលើសទិដ្ឋាការ ដើម្បីបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ធ្វើការផាកពិន័យ និងបន្តនីតិវិធីបណ្តេញចេញពីប្រទេស។

**២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ**

- បន្តអប់រំមន្ត្រីឱ្យយល់ដឹងអំពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ
- បន្តអប់រំជនជាប់ឃុំឱ្យយល់ដឹងពីក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល
- បន្តរៀបចំវគ្គបណ្តុះបណ្តាលជូនដល់ជនជាប់ឃុំឱ្យមានជំនាញ កាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្ត និងផលិតឥដ្ឋបុក
- បន្តពិនិត្យរៀបចំកម្មវិធីផែនការកសិកម្ម និងឧស្សាហកម្មក្នុងពន្ធនាគារ
- បន្តលើកគោលការណ៍ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្គត់ផ្គង់ជីវភាពសេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារ
- បន្តពិនិត្យ និងឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំឃាំង
- បន្តសហការជាមួយអង្គការលីកាដូ ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ ការពិនិត្យព្យាបាលជំងឺ និងផ្តល់ថ្នាំពេទ្យជូនជនជាប់ឃុំ និងចែកអំណោយជូនកូនតាមម្តាយក្នុងពន្ធនាគារខេត្ត។

របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០២៤ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៨ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥។

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ
- ឯកសារកាលប្បវត្តិ

**អភិបាល**

**មិថុនា ភួថង**

## ឧបសម្ព័ន្ធទី១៖ ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំខែធ្នូ

| ល.រ | ឈ្មោះ ក្រុង/ស្រុក | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋទូទៅ | | | | | | ចំនួនប្រជាពលរដ្ឋអាយុ ១៨ ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក្នុងនោះ | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | | |
| | | | អចិន្ត្រៃយ៍ | ប.អាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| ១ | ក្រុងខេមរភូមិន្ទ | 7,981 | 6,778 | 1,203 | 37,553 | 20,364 | 32,941 | 17,946 | 4,612 | 2,418 | 22,338 | 12,109 | 19,632 | 10,734 | 2,706 | 1,375 | 214 | 178 |
| ២ | ស្រុកមណ្ឌលសីមា | 4,520 | 4,316 | 204 | 19,002 | 9,560 | 18,357 | 9,225 | 645 | 335 | 14,400 | 7,105 | 13,970 | 6,881 | 430 | 224 | 488 | 423 |
| ៣ | ស្រុកកោះកុង | 2,459 | 2,414 | 45 | 9,409 | 4,495 | 9,224 | 4,429 | 185 | 66 | 6,257 | 3,133 | 6,109 | 3,079 | 148 | 54 | 893 | 344 |
| ៤ | ស្រុកគិរីសាគរ | 2,480 | 2,391 | 89 | 8,930 | 4,353 | 8,574 | 4,186 | 356 | 167 | 6,261 | 2,928 | 5,765 | 2,801 | 496 | 127 | 364 | 139 |
| ៥ | ស្រុកបូទុមសាគរ | 6,400 | 6,386 | 14 | 24,396 | 11,967 | 24,356 | 11,947 | 40 | 20 | 15,295 | 7,750 | 15,255 | 7,730 | 40 | 20 | 1,199 | 133 |
| ៦ | ស្រុកថ្មបាំង | 2,164 | 2,109 | 55 | 8,611 | 4,227 | 8,404 | 4,129 | 207 | 98 | 5,171 | 2,535 | 5,031 | 2,469 | 140 | 66 | 347 | 27 |
| ៧ | ស្រុកស្រែអំបិល | 10,518 | 10,470 | 48 | 47,510 | 24,268 | 47,038 | 23,954 | 472 | 314 | 29,746 | 15,328 | 29,575 | 15,215 | 171 | 113 | 1,836 | 357 |
| **សរុបទូទាំងខេត្ត** | | **36,522** | **34,864** | **1,658** | **155,411** | **79,234** | **148,894** | **75,816** | **6,517** | **3,418** | **99,468** | **50,888** | **95,337** | **48,909** | **4,131** | **1,979** | **5,341** | **1,601** |

## ឧបសម្ព័ន្ធទី២៖ ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំខែធ្នូ ឆ្នាំ២០២៤

- ថវិកាគ្រោងសម្រាប់សកម្មភាពសេវាសង្គមនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំចំនួន២៧.៦៤០.០០០រៀល ស្មើនឹង១០០% នៃថវិការសរុប
- ចំណាយជាក់ស្តែងដែលបានបូកយោងសម្រាប់សកម្មភាពសេវាសង្គមចំនួន២៧.៤៩១.០០០រៀល ស្មើនឹង១០០% (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

| ល.រ. | ឈ្មោះសកម្មភាព | ថវិកាគ្រោង | %សកម្មភាពសម្រេចបាន | អ្នកទទួលផល | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ក)-សុខភាពមាតា កុមារ និងអាហាររូបត្ថម្ភ | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ខ)-ទឹកស្អាតនិងអនាម័យ | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| គ)-ការអប់រំកុមារតូច | | | | | |
| ១.១ | | | | | |
| ១.២ | | | | | |
| ឃ)-ការអប់រំបឋមសិក្សា និងមធ្យមសិក្សា | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ង)-ការការពារស្ត្រី និងកុមារ | | | | | |
| ១.១ | | | | | |
| ១.២ | | | | | |
| ច)-កិច្ចគាំពារសង្គម | | | | | |
| ១.១ | ផ្តល់វគ្គបណ្តុះបណ្តាលដល់ គ.ក.ស.ក ក្រុង ស្រុក ចំនួន៧វគ្គ | ៨.៣៣០.០០០ | ១០០% | ២១០ | ១៣២ |
| ១.២ | | | | | |
| ឆ)-លំនៅឋាន | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |

ឧបសម្ព័ន្ធទី៣៖ វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនៃរដ្ឋបាលខេត្ត ប្រចាំខែ...(ថវិកាវិភាជន៍ពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

| ល.រ. | ឈ្មោះគម្រោង | គ្រោង/ ជាក់ស្តែង | លទ្ធផលគម្រោង | តម្លៃ (លានរៀល) | ទីតាំង អនុវត្ត | អ្នកទទួលផល | | វិធីសាស្ត្រ លទ្ធកម្ម | អ្នកទទួលការ | % អនុវត្ត | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | | | | |
| ក-ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ខ-ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| គ-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ឃ-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |

ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី.......ខែ............ឆ្នាំ២០